ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ៥ ខែឧសភា

ព.ស. ២៥០៤ គ.ស. ១៩៦១

- ភ្នំពេញ -

NATIONALE
DU CAMBODGE
P.K_1
1961_5

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ដ្រ
បេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង


ផ្នែកសាសនា — ទំព័រ

- វិបារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា (ត) លោក ឆល-ទិត្យ រៀបរៀង ៤៧៧
- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៤៩០
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក (តមក) លោក ប៊ូ-ប៉ូ រៀបរៀង . . . ៤៩៨
- មគ្គុរសភិហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះ ញ.ញ. ឈឹង ពិនិត្យ . . ៥០៧
- មហោសថជាតក(ត)លោកអ៊ុម-ភានបម្លងពីសាស្ដ្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-ត្លូរពិនិត្យ . ៥១៦

ផ្នែកអក្សរសាស្ដ្រ

- វប្បធម៌ខ្មែរ (តមក) លោក លី-ធាមតេង រៀបរៀង . . . ៥២៤
- ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ (តមក) . . . . . ៥១៨
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៥២៩
- ដើមកំណើតប្រាសាទអង្គរ លោក ល្វីហ្វីណូត៍រៀបរៀង ក្រមការ ផ្ទុំ-មៅ ប្រែ. ៥៣០
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . ៥៣៩
- រឿងមនុស្សចិត្តប្រែប្រួល (តមក) លោកប៉ូ-ប៉ូ រៀបរៀង . . ៥៤៨
- រឿងព្រេងប្រទេសស៊ីរី ភិក្ខុ ម៉ែន-រៀម ប្រែបាកភាសាអង់គ្លេស . . ៥៥៩
- រឿងមាណពមិនចេះដេកប្រជ្រៀតលោក ញូង-សឿន រៀបរៀង ៥៦៧

ផ្នែកកំណត់និងប្រវត្តិការណ៍

- បុណ្យទមត្ថភារព្រះសក្យមុនីចេតិយ លោក ស្ដើង ជួរ រៀបរៀង . . . ៥៨៤


មួយឆ្នាំ មាន១២ សៀវភៅ ជំឡើជារី ២៣០ រ០០

33e Année — No 5 — Mai 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire


### Partie religieuse

Pages

— Editorial "Les principes du Bouddhisme" (suite) par *M. PHAL-TITH* . . . 477

— La Vie du Buddha (suite) par Vèn. *PANG-KHAT* . . . . 490

— Prah Abhidhammapitaka, Kampi prah Yamaka (suite) par *M. BOU-FO* . . . . . 498

— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita *LOUIS-EM*, revu et corrigé par Vèn. *NHÉAN-CHHOEUN* . . . . 507

— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM-PHON*, revu et corrigé par Vèn. *KEM-TO* . . . . 516

### Partie littéraire

— La Culture Khmère (suite) par *M. LY-THEAM-TENG* . . 524

— Activités de la Commission Culturelle (suite) . . . . . . . . . . 528

— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 529

— Origine d'Angkor par Louis Finôt traduite par *M. CHUM-MAU* 530

— Histoire de Sam-Kok (suite) traduite par Oknha *NOU-KAN* . . . . . . 539

— L'homme au coeur changeant (suite) par *M. BOU-FO* . . . . . . 548

— Légendes de Syrie traduites de l'anglais par le bonze *MEN-RIEM*. 559

— Légende d'un jeune homme qui s'ennuit en dormant par *M. NHOUNG-SOEUNG* . . 567

### Notes et chroniques

— La fête de Namaskar Prah Sakyamuni Cettéy par *M. SDŒUNG-CHHO* . 584


Prix d'abonnement annuel (comprenant 12 numéros): 23o|oo

ផ្នែកសាសនា

វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

លោក ជល·ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ព្រះមុនីកោសល សួរ·ហាយ ពិនិត្យ

---

លើកមុន ខ្ញុំបានពណ៌នាយ៉ាងសង្ខេបអំពីរឿងកកើតឡើងនៃមនុស្ស ហើយខ្ញុំបានសូមអស់លោក-អ្នកថា ឲ្យរង់ចាំពិនិត្យគោលសំខាន់ក្នុងបញ្ហា មនោធាតុ ដែលបានមកជាមនុស្សហើយនេះតទៅទៀត ប៉ុន្តែ មុននឹងកយដំណើរទៅមុខនោះ ខ្ញុំបង្វែរមកពន្យល់ពីរឿងថា មនោធាតុ យ៉ាងតូច អាចក្លាយទៅជា មនោធាតុ យ៉ាងធំ សាឡើងជាបឋមផងទៀត ។

តើយើងគួរជឿបានឬទេ ថា មនោធាតុ មនុស្ស កើតចេញចាកមនោធាតុ សត្វតិរច្ឆានធំៗ មនោធាតុ សត្វតិរច្ឆានធំៗ កើតចេញចាកសត្វតិរច្ឆានតូចៗ មនោធាតុ សត្វតិរច្ឆានតូច កើតចេញចាកមនោធាតុ សត្វតិរច្ឆានតូចល្អិតទៅទៀត តាមលំដាប់ហូរហែ ហើយ មនោធាតុ នៃសត្វតិរច្ឆានតូចល្អិតបំផុតនោះ ក៏កើតចេញចាករុក្ខជាតិ តិណជាតិជាដើម, ឯពួក មនោធាតុ នៃរុក្ខជាតិ តិណជាតិជាដើមនោះ ក៏កើតចេញចាកធម្មជាតិដើម គឺ ដី·ទឹក·ភ្លើង·ខ្យល់·អាកាស (អវិជ្ជា)

ដែលពួកផ្គុំប្រជុំគ្នាឡើង (សង្ខារ) ។ រឿងនេះ បើបញ្ជាក់តាមឧទាហរណ៍ ឲ្យឃើញច្បាស់គឺ អ្នកណាក៏ធ្លាប់ឃើញ ឬធ្លាប់ឮដែរថា សត្វអន្ទង់ខ្លះកើតពីដើមត្រស់, ហើយមានសត្វស្ការខ្លះក្លាយពាកសត្វអន្ទង់, សត្វមមង់កើតចេញមកពីផ្លែល្វា, ដង្កូវទឹក កើតចេញមកពីទឹកភ្លៀងដែលធ្លាក់ពីលើអាកាស នាំយក មហាធាតុ ហើរហ៊ុងលើអាកាសមកផ្សំ ឬកើតពីទឹកស្អុយដែលស្រូបយក មហាធាតុ គ្រប់ទិសមកបង្កើត, ចាបចៀបកប្បាស ក្លាយមកពីដង្កូវដែលកើតចេញពីដើមកប្បាស, ដង្កូវដូង កើតចេញមកពីដើមឈើ, កណ្ដូប កើតពីស្លឹកតៀប ឬស្លឹកឈើផ្សេងទៀតជាដើម ។ ទាំងនេះ មិនបញ្ជាក់ឲ្យឃើញថា "ដើមឈើអាចក្លាយទៅជាសត្វបាន" ឬអ្វី? ។ តាមពិត វាយ៉ាងហ្នឹងឯង គឺសូម្បីក្នុងខណៈដែលដើមឈើ ឬសត្វកំពុងរស់ ក៏វាអាចក្លាយខ្លួនទៅជាអ្វីមួយផ្សេងទៀតបានដែរ មិនបាច់ចាំដាច់សិន ឬស្លាប់សិនទើបឲ្យ មហាធាតុ ហុយហើរទៅទីណាឡើយ ។ ចំពោះដើមឈើ ឬសត្វដែលស្លាប់ហើយវិញក៏វាអាចផ្សាយ មហាធាតុ របស់វាឲ្យទៅធ្វើសម្បយោគជាមួយនឹងធាតុឯទៀត បង្កើតទៅជាអ្វីមួយផ្សេងដោយកំលាំងជាងរស់នៅទៅទៀត ព្រោះឈើជាដើមដែលដាច់ វាដាច់តែដើមវាទេ ឯ មហាធាតុ របស់វាដែលផ្សំឡើងពី មហាធាតុ វាមិនរលាយក្លាយទៅវិញឡើយ គឺវានៅជាធាតុផ្សំមួយប៉ុន ចេញទៅជាធម្មតា ដូចជាសម័យសព្វថ្ងៃ ដែលគេប្រើ

វត្ថុបរមាណូជាគ្រឿងយុទ្ធភណ្ឌ សូម្បីគេល្បងនៅស្រុកដ៏ទៃមួយឯណោះសោះ ប៉ុន្តែ ធាតុបរមាណូដែលគេផ្សំហើយនោះ វាមិនរលាយអស់ភ្លាមទៅក្នុងអាកាសទេ គឺវានៅជាដុំផ្សាយប៉ុនលើអាកាស ទៅបំផ្លាញផលប្រយោជន៍ និងសុខភាពពិភពលោកបានយ៉ាងឆ្ងាយទៀត យ៉ាងណាមិញ, មូលធាតុ ដែលផ្សំគ្នាបង្កើតជា មហាធាតុ យ៉ាងនេះហើយ ក៏មហាធាតុ នោះវាមិនរលាយទៅភ្លាមយ៉ាងនោះដែរ ។ ដូច្នេះ កាលបើមហាធាតុនោះ ប៉ុនហើរទៅប៉ះជាប់នឹងធាតុអ្វីមួយទៀត ក៏វាចាប់ធ្វើសំយោគជាមួយនឹងធាតុក្រោយនេះ ក៏កើតឡើងជាអ្វីថ្មីមួយទៀត ដូចជាប៉ុនទៅជាប់នឹងទឹកក៏កើតជាដង្កូវទឹក, ប៉ុនទៅជាប់នឹងដី ក៏កើតជាដង្កូវ-ជន្លេនជាដើម ។ ប៉ុន្តែ យើងឃើញយ៉ាងជាក់ថាកាលដំបូង មូលធាតុគឺ ដី ទឹក ភ្លើង ខ្យល់ អាកាស វាជាធាតុគ្មានជីវិតអ្វីបន្តិចបន្តួចទាល់តែសោះលុះ មូលធាតុនេះ ផ្សំគ្នាកើតទៅជារុក្ខជាតិ ស្រាប់តែវាចេះគ្រាន់បើជាងមុនបន្តិច គឺចេះរស់រានមានជីវិត ចេះរុករកដីជាតិអាហារមកចិញ្ចឹមខ្លួនបាន, លុះរុក្ខជាតិនោះក្លាយទៅជាសត្វ ដូចជាអន្ទង់ ឬចាប ឬក៏ដង្កូវជាដើមក៏ឃើញថា អន្ទង់ ចាប ដង្កូវ ដង្កូវទឹកជាដើមនោះ មានដំណើរចេះជាងជាងរុក្ខជាតិនោះទៅទៀត ។ ចុះបើអន្ទង់នោះ វាក្លាយទៅជាស្ការ, ស្ការនោះ វាក្លាយទៅជាស្វា, ស្វានោះវាក្លាយជាមនុស្សព្រៃ ហើយមនុស្សព្រៃនោះ វាក្លាយទៅជាមនុស្សស្រុក តើយើងមិនហៅថា "មនុស្ស

ស្រុក មានដំណើរបេះដឹងជាងមនុស្សព្រៃ ៗ បេះដឹងជាងសត្វ ៗ បេះដឹងជាងស្ការ ៗ បេះដឹងជាងអន្ទង់ " យ៉ាងនេះទៀតឬ ?

សូមអ្នកអានពិនិត្យឲ្យល្អិតទៅចុះ ៗ ចំពោះធាតុដែលប៉ុនទៅកើតនឹងធាតុឯទៀតនោះ ក៏ដូចគ្នា គឺពេះតែកែចំរើន មនោធាតុ ក្នុងការបេះដឹងតាមលំដាប់ជាតិជាហូរហែទៅដែរ ប៉ុន្តែ សូមជ្រាបថា កាលដំបូង មនោធាតុ នៃពូជជាតិដែលប៉ុនហើរទៅនោះ ក៏ប៉ុនហើរទៅជាដុំជាកង់យ៉ាងគ្រោតគ្រាតដូច្នោះមែន ព្រោះពួកពូជជាតិមានតែ មនោធាតុ យ៉ាងទន់ល្អិត គឺពុំមិនទាន់មាន ចិត្ត វិញ្ញាណ នៅឡើយទេ តែលុះ មនោធាតុ នោះ ក៏បេះដឹងក្លាយទៅជា ចិត្ត វិញ្ញាណ បានហើយ ក៏ផ្លាស់របៀបចម្លងកំណើតពីមួយទៅមួយ យ៉ាងល្អិតសុខុមទៅវិញ គឺពចម្លងដោយការប៉ុនបង្ហើរខ្យល់ បដិសន្ធិចិត្ត ឲ្យទៅផ្គួបចាប់កំណើតជាមួយនឹងសម្បយុត្តធាតុផ្សេងទៀតកកើតជារូបថ្មីឡើង, ដូចជាសត្វចាប បើស្លាប់ហើយទៅកើតជាសត្វក្អែកឬសត្វអ្វីមួយនោះ ព្រោះតែកាលពីចាបនៅរស់ជិតនឹងស្លាប់ ក៏បានប៉ុនបង្ហើរខ្យល់ បដិសន្ធិចិត្ត ផ្ដោតទៅរកក្អែក ឬសត្វអ្វីមួយនោះឯង បានជាក៏ទៅកើតជាសត្វក្អែក ឬសត្វអ្វីមួយនោះ ៗ រួមសេចក្ដីមកថា ពួកពូជជាតិ គិតជាតិជាដើមនេះ បានជាមានដំណើរពិសេសទាបជាងមនុស្ស - សត្វ ព្រោះពួកពូជជាតិជាដើមនេះ ក៏មិនទាន់មាន ចិត្ត វិញ្ញាណ នៅឡើយទេ ក៏មានត្រឹម

តែ មនោធាតុ យ៉ាងស្ងប់ស្ងៀមណាស់នៅឡើយ ចំណែកខាងសត្វ ទោះល្អិតក្តី ទោះតូចធំក្តី ក៏ចាប់មានផ្តួចកើត ចិត្ត វិញ្ញាណ ហើយ គឺក៏មានការទទួលដឹងដំណើរឈឺចាប់ក្តៅត្រជាក់ ស្រេកឃ្លាន សុខទុក្ខ ជាដើមពិតមែនហើយ ប៉ុន្តែ មិនទាន់ដឹងច្បាស់ណាស់ជាមនុស្សទេ ព្រោះ មនុស្សយើង មានកម្លាំង ចិត្ត វិញ្ញាណ ចាស់ក្លាជាងពួកវាទាំងនោះ ។ មនោធាតុ ដែលកើតចំរើនចាកជាតិមួយទៅជាតិមួយ រហូតដល់ មានកម្លាំងការចេះដឹងពេញលេញ បានមកកើតជា មនោធាតុ របស់ មនុស្សដូចរៀបរាប់មកនេះ វាជាធម្មតាសម្រាប់ពិភពលោកយើង ដូច្នេះ បានជាមនុស្ស សត្វ ចេះតែមានការកើតឡើងជាច្រើនចំនួនក្នុងពិភពលោក យើងនេះជាលំដាប់ ព្រោះសភាពលោកនេះ មានការផ្តួចផ្តើមកំណើត ចាក មនោធាតុ ពីមួយទៅមួយ ដូចជាពី មូលធាតុ ទៅជាដើមឈើ វល្លិ ស្មៅ, ពីដើមឈើ វល្លិ ស្មៅ ទៅជាសត្វល្អិតល្អោច, ពីសត្វល្អិត ល្អោច ទៅជាសត្វកណ្តាល, ពីសត្វកណ្តាល ទៅជាសត្វធំ ៗ , ពីសត្វ ធំ ៗ ទៅជាមនុស្ស យ៉ាងនេះ គ្រប់វិនាទី ឥតមានចន្លោះម៉ោងឡើយ ។

កាលបើបានមកកើតជាមនុស្ស ដូច្នេះហើយ មនុស្សក៏ត្រូវចិញ្ចឹម ជីវិតដោយធម្មជាតិ ដូចជាបរិភោគបាយ - ទឹកជាដើម ហើយលុះដល់ មនុស្សនេះ ចាស់ជរាខ្លាំង ឬមានរោគាពាធអ្វីមួយមកញាំញីធ្វើឲ្យកម្លាំង ខ្សោយ មិនអាចរក្សាទុកស្ទួន (ភ្លើងធាតុ) ក្នុងខ្លួនបានហើយ មនុស្ស

នោះក៏ត្រូវទទួលមរណៈ គឺសេចក្ដីស្លាប់ទៅវិញ ។ ចុះ មនោ ចិត្ត វិញ្ញាណ របស់មនុស្សស្លាប់នោះ តើត្រូវទៅឯណា ? ឬក៏សូន្យ ?

ប្រស្នានេះ យើងអាចឃើញបានភ្លាមថា ជាបញ្ហា ដែលយើងប្រុងប្រៀបនឹងដោះស្រាយហ្នឹងឯង ។ រីឯអត្ថាធិប្បាយ ដែលយើងបានធ្វើមកប៉ុណ្ណេះទៀតសោត ក៏គឺដើម្បីនឹងពារកកស្ដុតាងជាក់លាក់ហ្នឹងឯង ហើយឥឡូវនេះ យើងបានក្ដិខ្លះហើយ ព្រោះអត្ថបទតាំងពីខាងដើម រហូតមកដល់ត្រឹមនេះ យើងអាចស្ដាប់យកជាគោលសង្ខេបបាន គឺ

១– អ្វីក៏ដោយ ដែលកើតមកក្នុងពិភពលោកនេះ ទោះជាមនុស្សក្ដី តិរច្ឆានក្ដី ពួករុក្ខជាតិ តិណជាតិជាដើមក្ដី សុទ្ធតែកើតចេញពីធម្មជាតិ គោលគឺ ដី ទឹក ភ្លើង ខ្យល់ អាកាស (អវិជ្ជា) ដែលធ្វើសម្បយោគនឹងគ្នា (សង្ខារ) ទាំងអស់, មិនមែនព្រះអាទិទេពណាមកសាងឲ្យឡើយ ។

២– មនុស្ស តិរច្ឆាន នឹងរុក្ខជាតិ ដែលផ្សេងប្លែកពីគ្នា, ក៏ព្រោះតែ មនោ ចិត្ត វិញ្ញាណ មានការចេះដឹងខុសគ្នា ព្រោះមនុស្សក្ដី តិរច្ឆានក្ដី រុក្ខជាតិជាដើមក្ដី កើតរូបចេញពីធម្មជាតិដូចគ្នាក៏ពិតមែន ប៉ុន្តែ មនោ ចិត្ត វិញ្ញាណ មានដំណើរផ្សេងគ្នា គឺពួករុក្ខជាតិជាដើមនោះ មិនទាន់មាន ចិត្ត នឹង វិញ្ញាណ នៅឡើយទេ មានត្រឹមតែ មនោធាតុ យ៉ាងស្អុចស្អើងដែលមិនទាន់កប់ចូលជា មនោ

ផងប៉ុណ្ណោះ, ឯសត្វតិរច្ឆាន ផ្ដើមមាន មនោ ចិត្ត វិញ្ញាណ ឡើងហើយ តែការចេះដឹងមានខ្លាំងខ្សោយជាងគ្នាតាមប្រភេទ ដូចជាសត្វឆ្មាឆ្កែមានការចេះដឹងច្រើនជាងជ្រូក - ជាទន្ទេនជាដើមដូច្នោះ ប៉ុន្តែ បើទុកជាយ៉ាងណាក៏ដោយ គង់នៅតែល្ងិតល្ងង់ជាងពួកមនុស្សយ៉ាងច្រើនទៅទៀត គឺមនុស្សមានការចេះដឹងច្រើនជាងពួកសត្វតិរច្ឆានទាំងអស់ ។

៣– មនោ ចិត្ត វិញ្ញាណ របស់មនុស្សយើង មិនមែនផុះចេញពាកធម្មជាតិតែម្ដងមកបានស្រេចភ្លាមទេ គឺត្រូវកេចេញពាកធម្មជាតិយឺតយូរបំផុតតាមលំដាប់មក លុះត្រាតែ មនោ ចិត្ត វិញ្ញាណ មានការចេះដឹងចាស់ក្លាហើយ ទើបមកកើតជា មនោ ចិត្ត វិញ្ញាណ របស់មនុស្សបាន ។ ប្រសិនជាមនុស្សយើងមាន មនោ ចិត្ត វិញ្ញាណ ផុបឡើងថ្មីតែម្ដង ដូចជាពួករុក្ខជាតិដែរនោះ សេចក្ដីវិសេសប្លែកនៃមនុស្សតិរច្ឆាន នឹងរុក្ខជាតិក៏គ្មានដែរ គឺពិតជាមនុស្ស តិរច្ឆាន រុក្ខជាតិ មានការចេះដឹងស្គាល់ប៉ុនគ្នាទៅហើយ ព្រោះសុទ្ធតែកើតពាកធម្មជាតិដូចគ្នា ។

៤– ការពង្រីង ពង្រីក មនោ ចិត្ត វិញ្ញាណ ជាការចាំបាច់នៃមនុស្ស ។ ព្រោះថា មនុស្ស បើមិនប្រឹងពង្រីង ពង្រីក មនោ ចិត្ត វិញ្ញាណ របស់ខ្លួនឲ្យនៅនឹង ឬឲ្យចំរើនឡើងទៀតទេ មនោ ចិត្ត វិញ្ញាណ របស់ខ្លួននោះ គង់នឹងថយការចេះដឹងទៅជាល្ងិតល្ងង់ទន់ខ្សោយវិញ, កាលបើថយទៅជាល្ងិតល្ងង់វិញហើយ វាក៏មិនប្លែកអ្វីពី

សត្វតិរច្ឆានដែរ គឺបើ មនោ ចិត្ត វិញ្ញាណ របស់ខ្លួន វាដូចជាសត្វតិរច្ឆានស្រេចទៅហើយ, ក៏នឹងក្លាយខ្លួនជាសត្វតិរច្ឆានទាំងរូបប្រាណទៅវិញដោយចាប់ បដិសន្ធិ កើតក្នុងកំណើតនោះមិនខាន ៗ

ចុះអ្វីដែលហៅថា មនោ-ចិត្ត-វិញ្ញាណ ?

ពាក្យថា មនោក្តី ចិត្តក្តី វិញ្ញាណក្តី ទាំង ៣ ម៉ាត់នេះ ជាពាក្យហៅរបស់តែមួយប៉ុណ្ណោះ គឺជាឈ្មោះ ធម្មជាតិ ម្យ៉ាងដែលកចេញពី មូលធាតុ (អវិជ្ជា) សម្រាប់ទទួលដឹង-ស្គាល់ដំណើរ នឹងវត្ថុក្នុងពិភពលោក ដូចជាខ្ញុំរាប់រៀបដោយហូរហែមកហើយ ប៉ុន្តែ គួរឲ្យឆ្ងល់ខ្លះដែរ ព្រោះថា បើជាឈ្មោះរបស់ ធម្មជាតិ តែមួយទេ ចុះហេតុអ្វី ក៏បានជាហៅឈ្មោះដល់ទៅ ៣ ម្ល៉េះ? សូមជម្រាបថា បានជាមានឈ្មោះដល់ទៅ ៣ នោះ ព្រោះលោកហៅទៅតាមដំណើររបស់វា គឺថាធម្មជាតិ តែមួយនេះ វាមិនចេះនៅស្ងៀមទេ វាចេះតែចង់ឃើញ-ចង់ឮ-ចង់ហិតក្លិន-ចង់ដឹងរសជាតិ-ចង់ស្ទាបប៉ះ-ចង់នឹកគិតជានិច្ច ម្ល៉េះហើយវាចេះតែរេទៅរកអារម្មណ៍ផុចចុះផុចឡើងជាអប្រមាណមិនចេះឈប់ឈរសោះ ដូច្នេះ បានជា គេហៅវាថា មនោ ដោយកំណត់យកត្រង់ដំណើរ ដែលចេះតែរេចុះរេឡើង ៗ មួយទៀត វាតែងតែនឹកគិតជាធម្មតា ដូចជាយើងតែងនឹកគិតទៅនេះទៅនោះ ឬត្រិះរិះពីអារម្មណ៍អ្វីមួយនៃរូបជាដើម ដូច្នេះ បានជាគេហៅវាថា ចិត្ត ដោយកំណត់

យកដំណើរ ដែលចេះនឹកគិត ៗ ម្យ៉ាងទៀត វាតែងទទួលឃើញទទួលឮ-ទទួលធុំក្លិន-ទទួលដឹងរសជាតិ-ទទួលដឹងសម្ផស្សដែលប៉ះត្រូវទទួលដឹងគំនិតដែលគិតឃើញជាប្រក្រតី ដូចជារូប កាលណាភ្នែកយើងមើលទៅចំ ក៏យើងឃើញភ្លាម តើឃើញដោយសារអ្វី? គឺឃើញដោយសារធម្មជាតិ មួយហ្នឹងឯង, ប្រសិនជាគ្មាន ធម្មជាតិ មួយនេះជាអ្នកទទួលឃើញទេ ទុកជារូបនោះដល់នឹងភ្នែក ក៏ភ្នែកនោះមិនអាចមើលឃើញបាន (រូបំ ចក្ខុ ន បស្សតិ អចិត្តកត្តា ចិត្តម្បិ ន បស្សតិ អចក្ខុកត្តា) ដូចជារូបតុក្កតាដែលគេឆ្លាក់ឲ្យមានភ្នែក ត្រចៀក ច្រមុះ ដូច្នោះ មកពីវាគ្មានធម្មជាតិមួយនេះនៅក្នុងខ្លួនវា បានជាវាមិនចេះឃើញ មិនចេះឮ មិនចេះដឹងអ្វីទាំងអស់ ដូច្នេះ បានជាគេហៅវាថា វិញ្ញាណ ដោយកំណត់យកត្រង់ដំណើរ ដែលឃើញ-ឮ-ដឹងក្លិន-ដឹងរស-ដឹងសម្ផស្ស-ដឹងគំនិតហ្នឹងឯង ៗ រួមសេចក្តីមកថា ធម្មជាតិ មួយបែបនេះ វាចេះតែរវៅរកអារម្មណ៍ផង ចេះត្រិះរិះគិតនូវអារម្មណ៍ផង ចេះដឹង-ស្គាល់នូវអារម្មណ៍ផង ព្រោះហេតុនោះ ទើបលោកឲ្យឈ្មោះវាថា មនោ ផង ចិត្ត ផង វិញ្ញាណ ផង ៗ ដោយដំណើរនេះ យើងយល់បានថា មនោ ចិត្ត វិញ្ញាណ ជាធម្មជាតតែមួយទេ ប៉ុន្តែមានឈ្មោះដល់ទៅ ៣ តាមដំណើររបស់វា ៗ ការហៅឈ្មោះជា ៣ យ៉ាងបែបនេះ បើប្រៀបធៀប ដូចជាមនុស្សម្នាក់ធ្វើស្រែផង ធ្វើជំនួញ

ផង ធ្វើជាងផង ។ ពិតមែនតែគួរបមនុស្សម្នាក់ តែប៉ុន្តែ គេនឹងហៅមនុស្សនោះថា កសិករ ក៏បាន, ថា ពាណិជ្ជករ ក៏បាន, ថា សិល្បករ ក៏បាន យ៉ាងណាមិញ, ធម្មជាតិតែមួយ មានឈ្មោះដល់ទៅ ៣ យ៉ាងក៏យ៉ាងនោះដែរ ។

ពួកមនុស្ស មានការប្លែកពីសត្វតិរច្ឆាន នឹងពួករុក្ខជាតិជាដើម ព្រោះពួកមនុស្ស មានរូបកាយផង មាន មនោ ចិត្ត វិញ្ញាណ យ៉ាងពេញលេញផង ។ រូបកាយ ប្រសិនជា មនោ ចិត្ត វិញ្ញាណ នេះ រលត់ចេញផុតហើយ ក៏វាមិនខុសអ្វីពីគល់ឈើដែរ ព្រោះវានៅស្ងួកស្ងឹង មិនចេះកំរើក មិនចេះដឹងស្គាល់អ្វីទាំងអស់ដូចគ្នា សុទ្ធសាធ ។ ដូច្នេះ រូបកាយ វាគ្រាន់តែជាផ្ទះលំនៅរបស់ មនោ ចិត្ត វិញ្ញាណ ប៉ុណ្ណោះ គ្មានចេះដឹងស្គាល់អ្វីឡើយ ។ ឯ មនោ ចិត្ត វិញ្ញាណ វិញ ពិតមែនតែមាននាទីទទួលចេះដឹងស្គាល់បានគ្រប់យ៉ាង ប៉ុន្តែ បើគ្មានផ្ទះលំនៅ គឺរូបកាយនេះនៅអាស្រ័យទេ ក៏វាមិនអាចសម្រេចកិច្ចការគ្រប់យ៉ាងបានដែរ ។ ហេតុនេះ របស់ទាំងពីរត្រូវពឹងអាស្រ័យនូវគ្នានឹងគ្នា ទើបមនុស្សយើងប្រព្រឹត្តទៅបានដូចសព្វថ្ងៃ ។

ឯសត្វតិរច្ឆាន បើនិយាយឲ្យឃើញច្បាស់ ថាវាមានដំណើរដូចមនុស្សសុទ្ធសាធ គឺវាកើតចេញពាកធម្មជាតិដូចគ្នា រស់នៅដោយអាហារដូចគ្នា មាន មនោ ចិត្ត វិញ្ញាណ ដូចគ្នា មាន កាម កិលេស

តណ្ហា ឧបាទាន ជាដើមដូចគ្នា ប៉ុន្តែ វាមានចំណុចប្លែកខ្លះគឺត្រង់មានការបេះដូងទន់ខ្សោយជាងពួកមនុស្សច្រើនណាស់ ៗ សត្វធំ ៗ ដូចជាដំរី ស្វា ឆ្កែជាដើម ឃើញថា វាមានដំណើរបេះដូងគ្រាន់បើក្បែរៗនឹងមនុស្សដែរ បំណែកសត្វល្អិតល្អោច ដូចជាដង្កូវ ជន្លេនជាដើមវិញ ឃើញថា វានៅល្ងិតល្ងង់ឆ្ងាយពីមនុស្សខ្លាំងណាស់ ស្ទើរតែឲ្យឈ្មោះថា “គ្មានដឹងអ្វី” ក៏បាន ៗ យ៉ាងនេះហើយ បានជាលោកពន្យល់ថា:

អាហារនិទ្រា ភយមេថុនំ ច
សាមញ្ញមេតម្បសុភិ៍នរានំ !
ធម្មោ ហិ តេសំ អធិកោ វិសេសោ
ធម្មេន ហីនះ បសុភិ៍នរានះ !!

មនុស្សនឹងតិរច្ឆាន ឥតខុសគ្នា ព្រោះចេះនិទ្រា ចេះភ័យភិត
ចេះរួមសេសេព មេថុនស្និទ្ធ ចេះស៊ីលេបលិទ្ធ គ្រប់អាត្មា ៗ
មានតែព្រះធម៌ ជាវិសេស បែកសត្វទាំងនេះ ឲ្យប្លែកគ្នា
ប្រសិនសត្វណា ប្រាសធម្មា នោះពិតឈ្មោះថា ឈាតែកប ៗ

ព្រះធម៌ក្នុងទីនេះ សំដៅការបេះដូងល្អអាក្រក់ បុណ្យ បាប ពិត មិនពិត ឬហេតុផល ជាដើមហ្នឹងឯង ៗ ព្រះធម៌ នេះ ជាសភាពទាក់ទងនឹង មនោ ចិត្ត វិញ្ញាណ គឺថា បើ មនោ ចិត្ត វិញ្ញាណ នេះ មានការបេះដូង ស្គាល់ខ្មៅ ស ល្អ អាក្រក់ បាប បុណ្យ គុណ

ទោស ហេតុផលជាដើមច្រើន, មនោ ចិត្ត វិញ្ញាណ នោះ លោកហៅថា មានធម៌, បើ មនោ ចិត្ត វិញ្ញាណ នេះនៅទន់ខ្សោយការចេះដឹង បាប បុណ្យ គុណ ទោស ហេតុ ផលជាដើមនេះ, មនោ ចិត្ត វិញ្ញាណ នោះ លោកហៅថា គ្មានធម៌ ទៅវិញ ។

ពួកមនុស្ស ជាសត្វមាន ធម៌ ព្រោះមាន មនោ ចិត្ត វិញ្ញាណ មានការចេះដឹងច្រើន ។ ឯពួកតិរច្ឆាន ជាសត្វ គ្មាន ធម៌ ព្រោះវាខ្សោយការចេះដឹងណាស់ ។ ដូច្នេះ ឃើញថា ពួកមនុស្ស និងពួកសត្វតិរច្ឆាន មានការប្លែកគ្នាត្រង់ ព្រះធម៌ គឺសេចក្តីចេះដឹងហ្នឹងឯង ។

ចំណែកខាងពួករុក្ខជាតិជាដើមវិញ ជាធម្មជាតិឥតមាន មនោ ចិត្ត វិញ្ញាណ អ្វីទេ មានតែ មនោធាតុ យ៉ាងល្អិតក្រៃលែងបន្តិចបន្តួចដូចខ្ញុំពណ៌នារួចហើយប៉ុណ្ណោះ ។ ហេតុនោះ បានជាពួករុក្ខជាតិជាដើមនេះវាមិនចេះទទួលការឈឺ-ចាប់ មិនចេះទទួលកំដៅ-ត្រជាក់ជាដើមឡើយ ទោះជាគេយកកាំបិត ពូថៅទៅកាប់ចាំង ឬយកភ្លើងទៅដុតពេលយ៉ាងណាក៏ដោយ ។ វារស់នៅមានត្រឹមតែជីវិតដោយសន្តតិប៉ុណ្ណោះ វាគ្មានការគិតសាងល្អ-អាក្រក់ ឬបុណ្យ-បាប ដូចជាមនុស្ស និងសត្វតិរច្ឆានទេ ព្រោះវាគ្មាន ចិត្ត និងគិតត្រិះរិះ, គ្មាន វិញ្ញាណ និងដឹងអ្វីឡើយ ។

ការប្លែកគ្នានៃពួកមនុស្ស, សត្វតិរច្ឆាន និងរុក្ខជាតិជាដើមនេះ លោកបានចែកយ៉ាងច្បាស់លាស់ជា ២ ចំណែក គឺជា ឧបាទិន្នកសង្ខារ ១

ជា អនុបាទិន្នកសង្ខារ ១ ។ ពួកមនុស្ស និងតិរច្ឆាន ជាឧបា-ទិន្នកសង្ខារ, ឯពួករុក្ខជាតិជាដើម ជា អនុបាទិន្នកសង្ខារ ។ បានសេចក្តីថា ពួកមនុស្ស និងតិរច្ឆាន ព្រមទាំងពួករុក្ខជាតិជាដើម លោកឲ្យឈ្មោះថា ជា សង្ខារ ទាំងអស់ ព្រោះវាទាំងនេះ ត្រូវមូលធាតុ គឺ ដី ទឹក ភ្លើង ខ្យល់ អាកាស (អវិជ្ជា) ធ្វើសំយោគគ្នា (សង្ខារ) បង្កបង្កើតឡើង ។ ពួកមនុស្ស និងពួកតិ-រច្ឆាន បានជាលោកហៅថា ជា ឧបាទិន្នកសង្ខារ ព្រោះវាទាំងនេះ មាន ចិត្ត វិញ្ញាណ នៅអាស្រ័យក្នុងរូបប្រាណ, ឯពួករុក្ខជាតិជាដើមវិញ វាគ្មាន ចិត្ត វិញ្ញាណ នៅអាស្រ័យក្នុងរូបរបស់វាទេ ទើបលោកឲ្យឈ្មោះថា ជា អនុបាទិន្នកសង្ខារ ។

ការពណ៌នាមកប៉ុណ្ណោះ ហាក់ដូចជាបញ្ជាក់សេចក្តីដដែល ៗ ក៏ប៉ុន្តែ ខ្ញុំយល់ថា អស់លោក-អ្នកអាន ប្រហែលជាបានទទួលលទ្ធផលគឺការយល់យ៉ាងច្បាស់លាស់ក្នុងរឿងនេះមិនខាន ។

ហេតុនេះ បើយល់ច្បាស់ហើយ យើងត្រូវដោះស្រាយបញ្ហាមនុស្សកើត-ស្លាប់ តាមពាក្យចោទ-ឆ្លើយ ដូចតទៅខាងក្រោមនេះ ៖

(នៅមានត)

ពុទ្ធជីវប្រវត្តិ

ព្រះមហា ប៉ាន-ខាត់ រៀបរៀង

( តមក )

# សត្តិកេតិទានធម្មបក្កកឋាទី ១១

១· ទ្រង់ប្រោសបញ្ចវគ្គិយ ២- ទ្រង់ប្រទានព្រះបឋមទេសនា ៣- ទ្រង់ប្រទានធម្មចក្រនៅឥសិបតនមិគទាយវ័ន ៤- អវសានបឋមទេសនា ៥- សេចក្តីអស្ចារ្យក្នុងពេលប្រទានធម្មចក្រ ៦- កោណ្ឌញ្ញបព្វជ្ជា ៧. ព្រះអរហន្ត ៦ អង្គមុនបង្អស់ក្នុងលោក ។

## ១ – ទ្រង់ប្រោសបញ្ចវគ្គិយ

*ព្រះបរមសាស្តាស្តេចពុទ្ធដំណើរទៅកាន់ចារិក តាមលំដាប់ ហើយចូលទៅកាន់ក្រុងពារាណសី ស្តេចដល់ហើយ សំដៅឆ្ពោះព្រះភ័ក្រ្តទៅឥសិបតនមិគទាយវ័នជាទីឋានដែលបញ្ចវគ្គិយអាស្រ័យនៅ ។ បញ្ចវគ្គិយបានឃើញព្រះអង្គពីចម្ងាយហើយ ប្រជុំគ្នាថា សមណគោតមនេះប្រតិបត្តិដើម្បីលោភ ឃ្លាតចាកព្យាយាមស្រឡះហើយ វិលត្រឡប់មកដើម្បីភាពជាអ្នកលោភវិញហើយ ឥឡូវលោកនិមន្តមកដល់ យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំទេ មិនគួរក្រោកទទួលទេ មិនគួរទទួលបាត្រចីវរលោកទេ យើងគ្រាន់តែក្រាលអាសនៈខ្លះទុកបម្រុង បើលោកត្រូវការ ក៏គង់ចុះ ។ បញ្ចវគ្គិយទាំងនោះ លុះព្រះពិជិតមារស្តេចមកដល់ហើយ ក៏ភ្លេចពាក្យប្រជុំរបស់ខ្លួនអស់ ថែរជាក្រោកឡើងស្ទុះស្ទាទៅទទួល ខ្លះ*

*ទទួលបាត្រចីវរ ខ្លះក្រាលអាសនៈ ខ្លះយកទឹកលាងព្រះបាទ; ហើយហៅព្រះអង្គចំឈ្មោះព្រះអង្គថា គោតម ផង ថា អាវុសោ ផង ដូចព្រះតម្រាស់ដែលត្រាស់ចំពោះពោធិរាជកុមារ ថា(១)*

ម្នាលរាជកុមារ! បញ្ចវគ្គិយតាបស ហៅតថាគតយ៉ាងនេះហើយ តថាគតពោលតបទៅវិញថា ម្នាលអ្នកទាំងឡាយ! អ្នករាល់គ្នាកុំហៅតថាគតចំឈ្មោះ កុំហៅតថាគត "អាវុសោ" ដូច្នេះទៀត តថាគតជាអរហន្តសម្មាសម្ពុទ្ធ ហើយអ្នកទាំងឡាយប្រុងសោតប្រសាទចុះ តថាគតនឹងប្រៀនប្រដៅអមតធម៌ ដែលតថាគត ត្រាស់ដឹងហើយ ដល់អ្នកទាំងឡាយ ដើម្បីប្រយោជន៍អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិតាមពាក្យប្រៀនប្រដៅតថាគតហើយ ពុំយូរឡើយមុខជានឹងបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។

ម្នាលរាជកុមារ! កាលតថាគត ពោលយ៉ាងនេះហើយ បញ្ចវគ្គិយតាបស ក៏ពោលពាក្យនឹងតថាគតដូចមុនជាគម្រប់

---

១- ពោធិរាជកុមារសូត្រ ម.ម. សៀវភៅ ២៥ ទំព័រ ៤០២ ( មហាវគ្គបឋមភាគ មហាខន្ធកៈ សៀវភៅ ៦ ទំព័រ ២៥ ) ។

ទី ២ គម្រប់ទី ៣ ផង ។ កាលបញ្ចវគ្គិយតាបស ពោលពាក្យយ៉ាងនេះហើយ តថាគត ក៏ពោលពាក្យតបទៅវិញទៀតថា ម្នាលអ្នកទាំងឡាយ! អ្នកទាំងឡាយចាំបានដែរឬទេ? ពាក្យមានសភាពយ៉ាងនេះ ជាពាក្យដែលតថាគតធ្លាប់បានពោលមកពីមុនដែរឬទេ? បញ្ចវគ្គិយតាបស ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន! ពាក្យហ្នឹងព្រះអង្គមិនដែលបានពោលទេ ។

ម្នាលរាជកុមារ! តថាគតញុំាងបញ្ចវគ្គិយតាបសឲ្យយល់ច្បាស់ក្នុងពេលនោះបាន ។ តថាគតបានប្រៀនប្រដៅតាបស ២ រូប តាបស ៣ រូបនាំគ្នាទៅបិណ្ឌបាត្រ បានអាហារល្មមយើង ៦ នាក់ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។

ម្នាលរាជកុមារ! បញ្ចវគ្គិយតាបស កាលបើតថាគតទូន្មានហើយ ប្រៀនប្រដៅហើយ កុលបុត្រទាំងឡាយចេញចាកផ្ទះបួសទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ពុំយូរឡើយ ក៏បានត្រាស់ដឹងដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ បាន ។

## ២- ទ្រង់ប្រទានព្រះបឋមទេសនា

*លុះគ្រាជាខាងក្រោយ បញ្ចវគ្គិយតាបស តាំងចិត្តស្តាប់ព្រះមានព្រះភាគ ផ្ទៀងនូវសោតប្រសាទហើយផ្ចង់ចិត្តដើម្បីស្តាប់នូវព្រះពុទ្ធដីកា ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា (១)*

ម្នាលភិក្ខុទាំងឡាយ ធម៌អមខាងទាំងពីរប្រការនេះបព្វជិត មិនគួរសេពគប់ទេ គឺ

១- កាមសុខល្លិកានុយោគ ការប្រកបរឿយៗ នូវសេចក្តីជាប់ជំពាក់ដោយកាមសុខទាំងឡាយណា ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ។

២- អត្តកិលមថានុយោគ ការប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក តែងនាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ ។

ម្នាលភិក្ខុទាំងឡាយ! មជ្ឈិមាបដិបទា គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល មិនប៉ះពាល់នឹងធម៌អមខាងទាំងពីរនោះ តថា-

---

១- មហាវគ្គ បឋមភាគ មហាខន្ធកៈសៀវ. ៦ ទំព័រ ៤៨ ។

គតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញា ចក្ខុ គឺធ្វើឲ្យកើតសេចក្តីចេះដឹង ប្រព្រឹត្តទៅ ដើម្បីសេចក្តីរម្ងាប់ កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយ-សច្ច ដើម្បីនិព្វាន ។

## ៣– ទ្រង់ប្រកាសធម្មចក្រនៅឥសិបតនមិគទាយវ័ន

*ព្រះមានព្រះភាគប្រកាសធម្មចក្រ ដែលឥតមាននរណាមួយក្រឡប់វិ-វត្តឡើយ ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះបញ្ចវគ្គិយភិក្ខុទាំងឡាយថា(១)*

ម្នាលអ្នកទាំងឡាយ! ធម្មចក្រដ៏ប្រសើរ ដែលតថាគត អរហន្តសម្មាសម្ពុទ្ធ ឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ជាធម្មចក្រដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តី ក្នុងលោកឲ្យ បដិវត្តទៅមិនបាន គឺការប្រាប់ ការសំដែង ការបញ្ញត្តិ ការ តែងតាំង ការបើក ការចែក និងការធ្វើឲ្យរាក់ច្បាស់នូវអរិយសច្ច ទាំង ៤, អរិយសច្ចទាំង ៤ តើដូចម្តេច?

ការប្រាប់ ការសំដែង ការបញ្ញត្តិ ការតែងតាំង ការ

---

១ សច្ចវិភង្គសូត្រ វិភង្គវគ្គ ម.ឧ. សៀវ. ២៣ ទំព័រ ៤០០ ។

បើក ការបែកនឹងការធ្វើឲ្យងាយនូវអរិយសច្ច ១ នូវទុក្ខសមុទយអរិយសច្ច ១ នូវទុក្ខនិរោធអរិយសច្ច ១ នូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

## ៤- អវសានបឋមទេសនា

*កាលចប់ព្រះបឋមទេសនា ព្រះកោណ្ឌញ្ញត្ថេរចាស់ជាងគេ បានត្រាស់ដឹងអនុត្តរធម៌មុន ដូចព្រះពុទ្ធដីកាដែលត្រាស់ចំពោះកោណ្ឌញ្ញត្ថេរថា*(១)

អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អើហ្ន៎! កោណ្ឌញ្ញបានត្រាស់ដឹងពិតហើយ អើហ្ន៎! កោណ្ឌញ្ញបានត្រាស់ដឹងហើយ ។

*អាស្រ័យហេតុនេះហើយ បានជាព្រះកោណ្ឌញ្ញត្ថេរ បាននាមប្រាកដថា អញ្ញាកោណ្ឌញ្ញ តាំងពីកាលនោះមក ។*

## ៥- សេចក្តីអស្ចារ្យក្នុងពេលប្រកាសធម្មចក្រ

ព្រហ្មទាំងឡាយក៏បន្លឺនូវសូរសំព្វថា(២) ព្រះធម្មចក្រនេះ មិនមានចក្រដទៃក្រៃលែងជាងទេ ព្រោះបើសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនណាមួយក្តីក្នុងលោក មិនអាចបដិវត្តបានឡើយ គឺឲ្យព្រះមានព្រះភាគ ទ្រង់បាន

---

១- មហាវគ្គ បឋមភាគ មហាខន្ធកៈ សៀ. ៦ ទំព័រ ៣៦ ។ ២ មហាវគ្គ បឋមភាគ មហាខន្ធកៈ សៀ. ៦ ទំព័រ ៣៦ ។

បដិវត្តបានហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ សំឡេងក៏លាន់ឮឡើងជាដរាបដល់ព្រហ្មលោកក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយប្រការដូច្នេះ ។ រីឯលោកធាតុទាំងមួយម៉ឺន ក៏កក្រើករំភើបញាប់ញ័រ ទាំងពន្លឺធំទូលាយប្រមាណមិនបាន កន្លងលើសអានុភាពនៃទេវតាទាំងឡាយ កើតប្រាកដឡើងក្នុងលោក ។

### ៦- កោណ្ឌញ្ញទទួលបព្វជ្ជា

*កាលព្រះកោណ្ឌញ្ញបានឃើញព្រះអរិយសច្ចធម៌ហើយ ទើបក្រាបទូលព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស! ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា*

“ឯហិ ភិក្ខុ អ្នកចូរមកជាភិក្ខុចុះ! ហើយមានព្រះពុទ្ធដីកាថា សាសនធម៌ តថាគតបានពោលល្អហើយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃកងទុក្ខដោយប្រពៃចុះ” ។

*ព្រះពុទ្ធដីកានេះឯងជាឧបសម្បទារបស់អញ្ញាកោណ្ឌញ្ញអង្គនោះ ។ ព្រះអញ្ញាកោណ្ឌញ្ញអង្គនេះជាបព្វជិត ទី ១ មុនដំបូងក្នុងព្រះពុទ្ធសាសនា ។*

លំដាប់តទៅ ព្រះមានព្រះភាគ ទ្រង់ពោលទូន្មានប្រដៅតាបសដ៏សេស ក្រៅពីអញ្ញាកោណ្ឌញ្ញដោយធម្មីកថា ធម្មចក្ខុប្រាសចាកធូលីប្រាសចាកមន្ទិល កើតដល់ព្រះវប្បៈនឹងព្រះភទ្ទិយៈ ។ តាបសទាំងពីររូបនេះសូមបព្វជ្ជាទៀត ។ តទៅមហានាមនឹងអស្សជិ បានធម្មចក្ខុទៀត ហើយសូមបព្វជ្ជា ។

## ៣- ព្រះអរហន្ត ៦ អង្គមុនបង្អស់ក្នុងលោក

កាលព្រះមានព្រះភាគត្រាស់ទេសនា អនត្តលក្ខណសូត្រចប់ហើយ បញ្ចវគ្គិយភិក្ខុទាំងឡាយ បានសម្រេចអរហត្តផល ជាព្រះអរហន្តក្នុងលោក ដូចសេចក្តីដែលទ្រង់ត្រាស់ទុកថា (១)

ព្រះមានព្រះភាគបានសំដែងអនត្តលក្ខណសូត្របប់ហើយ បញ្ចវគ្គិយភិក្ខុទាំងឡាយ មានចិត្តរីករាយចំពោះភាសិតនៃព្រះមានព្រះភាគ កាលដែលព្រះមានព្រះភាគកំពុងត្រាស់សំដែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង ៥ បានរួចស្រឡះហើយចាកអាសវៈទាំងឡាយព្រោះមិនប្រកាន់មាំថាអញ ថាយើងឡើយ ។

គ្រាសម័យនោះឯងមានព្រះអរហន្ត ៦ អង្គ នៅក្នុងលោកជាដំបូង (រាប់ទាំងអង្គព្រះមានព្រះភាគផង) ។

---

១ មហាវគ្គ បឋមភាគ មហាខន្ធកៈ លេ. ៦ ទំព័រ ៤៣ ។

(នៅមានត)

# ព្រះអភិធម្មបិដក

## គម្ពីរព្រះយមក

លោកប៊ូ - ប៊ូ ប្រែរៀបរៀង

(តមក)

---

វត្ថទោ វណ្ណទោ អ្នកឲ្យសំពត់ជាទាន ឈ្មោះថាឲ្យនូវវណ្ណពណ៌សម្បុរស្បែកជាទាន ព្រោះមនុស្សបានស្លៀកដណ្ដប់សំពត់ហើយ ទើបមានពណ៌សម្បុរស្រស់ថ្លាល្អ ។

ទីបទោ ចក្ខុទោ អ្នកបានឲ្យប្រទីបអគ្គី ឈ្មោះថាឲ្យចក្ខុជាទាន កើតក្នុងអនាគតកាលនឹងមានចក្ខុជាទិព្វ មានចក្ខុបរិសុទ្ធស្អាត ប្រាសចាកងងឹតអន្ធការ ។ សេចក្ដីនេះ សម្ដេចព្រះបរមទសពលប្រទានព្រះសទ្ធម្មទេសនាទុកក្នុងសុត្តនិបាតថា បុគ្គលអ្នកបំពេញទាន នឹងប្រាសចាករោគទុក្ខភ័យទាំងពួង ព្រោះហេតុទាននោះ បុគ្គលអ្នកលះបង់បាយនឹងភោជនាហារដែលខ្លួនបរិភោគ នឹងសំពត់អាវស្លៀកបំពាក់ឲ្យទៅអ្នកដទៃ ឲ្យបានសះជារោគគឺ ឃ្លានបាយ ស្រេកទឹក ។ ការឃ្លានបាយស្រេកទឹកនេះ ជារោគយ៉ាងធ្ងន់ក្រៃលែង សមតាមព្រះពុទ្ធដីកាថា ជិឃច្ឆា បរមា រោគា រោគគឺឃ្លានបាយ ស្រេកទឹក ជារោគធ្ងន់លើសរោគទាំងពួង ព្រោះថារោគឯទៀត រោគខ្លះមើលឆាប់ជា រោគខ្លះមើលយូរក្រជា ដូចជាឈឺក្អកដាក់ថ្នាំមិនជា ទាល់តែ

បែកកែកែ្លកខ្ញាក់ទៅ ចិត្តអ្នកខ្ញាក់កែ្លកនោះ ក៏ឥតអាល័យស្តាយដែរ ព្រោះបានថែរក្សាអស់ចិត្តអស់ថ្លើមហើយវាមិនជា រោគបែបនេះ មិនបាត់ជាធូនទេ ។ ឯរោគឃ្លានបាយស្រេកទឹក បាត់ជាធ្ងន់បំផុត ព្រោះត្រូវរកចាំតែបាយទឹករក្សាគ្រប់ពេលវេលា សូម្បីខ្លួនជាគ្មានជម្ងឺអ្វីសោះ ក៏ត្រូវតែដាក់ចាំថែរក្សារោគឃ្លានបាយស្រេកទឹកជានិច្ចទៅ នឹងឈប់ខានមិនបានឡើយ តែខានស៊ីខានផឹកហើយ មុខជាស្លាប់ដោយរោគស្រេកឃ្លាននោះឯង ហេតុនោះ សម្តេចព្រះបរមគ្រូត្រាស់ថា រោគស្រេកឃ្លាននេះជារោគធ្ងន់យ៉ាងក្រៃលែង គ្មានរោគឯណាធ្ងន់ស្មើឡើយ ។

អ្នកថែរក្សាជម្ងឺឈឺចាប់ឲ្យស្រះជា ព្រោះតែបានឲ្យមានភោជនាហារ ។ អ្នកថែរក្សាពិណ្ណរោគដែលកើតក្នុងខ្លួនឲ្យស្រះជា ព្រោះតែបានឲ្យមានភេ-សជ្ជៈនិងអដ្ឋបាន នឹងអាចញុំាងរូបកាយឲ្យគ្មានរោគ ។ អ្នកបរិច្ចាគមានលះកាត់សេចក្តីកំណាញ់ស្តាយ ក៏អាស្រ័យតែចិត្តមិនលោភ បើចិត្តឥតលោភហើយ ក៏រេះតែគិតឲ្យមានជានិច្ច ។ ឯអលោភចេតសិកនេះ បើកើតមានហើយ ប៉ុន្តែ មិនទាន់ចាស់ក្លា គ្រាន់តែគិតថាឲ្យៗ ប៉ុណ្ណោះ បើមិនបានឲ្យទេ ក៏គ្រាន់តែជួយធ្វើអនុមោទនាទានរបស់អ្នកដទៃ បើអលោភៈកើតចាស់ក្លាបន្តិច ក៏ហ៊ានឲ្យរបស់ដែលខ្លួនស្រឡាញ់បាន លុះអលោភៈកើតចាស់ក្លាខ្លាំងហើយ ក៏ហ៊ានឲ្យរបស់ដែលតែតែល្អប្រសើរលើសលុបទៅទៀត ។ បើរេះតែឲ្យ ទាល់តែអស់ទ្រព្យសម្បត្តិលើង

ពីខ្លួនហើយ ហ៊ានលក់បញ្ចាំរូបកាយខ្លួនឲ្យគេ យកប្រាក់កាសមកបំពេញទានទៀត ដូចជាមហាតិស្សឧបាសក យកកូនស្រីរបស់ខ្លួនទៅលក់បញ្ចាំឲ្យគេបានប្រាក់ ១២ រៀល យកមកធ្វើសង្ឃទានថ្វាយព្រះភិក្ខុសង្ឃ ហើយខ្លួនឯងទៅស៊ីឈ្នួលគេ បានប្រាក់ត្រឡប់មកផ្ទះវិញ ប្រុងនឹងលោះកូនស្រីឲ្យរួចជាអ្នកជា ដើរមកជួបនឹងព្រះមហាថេរកណ្ដាលផ្លូវ ដឹងថាលោកខ្វះខាតចង្ហាន់ ក៏ទិញចង្ហាន់ប្រគេនលោក ទាល់តែអស់ប្រាក់រលីងខានទៅលោះកូនស្រី នេះមកពីមហាតិស្សឧបាសកមានអលោភ-ចេតសិកដ៏ខ្លាំងក្លាក្នុងសន្តាន ។

ចំណែកកិរិយានឹងធីតារបស់ឧបាសក បានដឹងរឿងនោះ ក៏មានចិត្តសោមនស្សជ្រះថ្លា ទទួលអនុមោទនាការកុសល ខាងក្រោយមកព្រះមហាក្សត្រនៅប្រទេសនោះ ទ្រង់បានជ្រាបប្រព្រឹត្តិហេតុកុសលរបស់មហាតិស្សឧបាសក ទើបទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទ្រព្យធនជាច្រើនដល់ឧបាសកនោះ ក្នុងបច្ចុប្បន្នទាន់ភ្នែកឃើញ ។ ឧបាសកបំពេញទានយ៉ាងនេះបាន ក៏អាស្រ័យតែអលោភៈ គឺចិត្តឥតលោភកើតខ្លាំងក្លាក្នុងសន្តាន ។

ចំណែកខាងមហាឧបាសិកាវិញ បានដល់ព្រះឧប្បលវណ្ណាថេរី កាលដើមដំបូងនៅកំពុងអន្ទោលទៅមកក្នុងសង្សារវដ្ដ បានស៊ីឈ្នួលគេចំនួនបីឆ្នាំ បានសំពត់ពណ៌មួយផ្ទត់មក ហែកមួយកំណាត់ប្រគេនភិក្ខុ

មួយរូប ដែលចោរលួចយកស្បង់ចីពរអស់ទៅ លោកស្លៀកស្លឹកឈើ, ខាងក្រោយ នាងឃើញលោកស្លៀកសំពត់ដែលខ្លួនប្រគេននោះសមរម្យ ក៏កើតចិត្តជ្រះថ្លាខ្លាំង យកសំពត់ដែលខ្លួនហែកមួយកំណាត់ទុកប្រើនោះ ទៅប្រគេនលោកទៀត លុះនាងលះបញ្ចក្ខន្ធ បានទៅកើតក្នុងឋានសួគ៌ ច្យុតពីស្ថានសួគ៌ ចុះមកកើតជានាងឧម្មាទន្តី ។ នាងនេះបើប្រុសណាឃើញ ប្រុសនោះទៅជាវង្វេងស្មារតីឆ្កួតលីលាលែងដឹងខុសត្រូវ ព្រោះតែស្រឡាញ់នាងខ្លាំងហួស លុះដល់ព្រះពុទ្ធសាសនានៃព្រះពុទ្ធជាម្ចាស់យើងនេះ នាងបានមកកើតជានាងឧប្បលវណ្ណាថេរី អាស្រ័យអលោភៈមានក្នុងសន្តាន ហេតុនោះ អលោភៈទើបរាប់បញ្ចូលក្នុងមូលនៃកុសលក្នុងមូលយមកនេះ ។

## អទោសោ

អលោភានន្តរអទោសោតិ ឯត្ថ អត្ថោ វា បរេសំ វា ន ទុស្សតីតិ អទោសោ, អថវា បរសន្តកោ បរន្តោតិ អទោសោ, ន ទោសោ អទោសោតិ វុច្ចតិ សោ កុសលមូលន្តិ វេទិតព្វោ សោ កុសលស្ស បតិដ្ឋានំ មូលន្តិ កុសលមូលន្តិ ។

លំដាប់នេះ ពណ៌នាក្នុងមូលកុសលដែលសម្ដេចព្រះបរមទសពលត្រាស់សំដែងអទោសោ លំដាប់ពីអលោភោតទៅ មានបទវិគ្រោះដែល

ព្រះអដ្ឋកថាចារ្យពោលទុកថា ឆន្ទសម្បត្តិ សភាវៈឯណាមិនបានប្រទូស
រ៉ាយនឹងបុគ្គលទាំងឡាយដទៃ សភាវៈនោះឯងឈ្មោះថា អទោសោ ។

ន័យមួយទៀត គំនិតដែលមិនគិតប្រទូសរ៉ាយទ្រព្យរបស់ខ្លួននឹង ទ្រព្យរបស់អ្នកដទៃ ឈ្មោះថា អទោសោ ។ នោះ មានអត្ថាធិប្បាយថា ចិត្តមិនក្រោធ ឈ្មោះថា អទោសោ ។ នោះជាមូល, ជាទីតាំង, ជា ឫសគល់, ជាដើមបទនៃកុសលធម៌ទាំងពួង ។

អទោសោ នេះ មានក្នុងសន្តានចិត្តអ្នកណា ជាហេតុនឹងឲ្យអ្នក នោះរក្សាសីលបានបរិសុទ្ធល្អ សមនឹងព្រះពុទ្ធភាសិតថា អទោសោ សីលហេតុ អទោសោនេះ ជាហេតុនឹងឲ្យរក្សាបានខ្ជាប់ខ្ជួនបរិសុទ្ធ ។ កាលបើរក្សាសីលបរិសុទ្ធហើយ ជាហេតុនឹងញ៉ាំងខ្លួនឲ្យចំរើនក្នុងជាតិនេះ នឹងជាតិមុខ ហេតុនោះ បានជាថាអទោសោជាមូលនៃកុសល ។ ឯ មនុស្សជាបុថុជ្ជនតែងមានទោសោដូចគ្នាទាំងអស់ តែខ្លះម្នាក់នោះ មាន តែអ្នកប្រាជ្ញបណ្ឌិតជាតិប្រកបដោយប្រាជ្ញាល្អ សូម្បីមានទោសោកើតក្នុង ចិត្តលោកហើយ លោកខំសង្កត់សង្កិនបានបន្តិចម្តង ៗ នឹងកាត់លះឲ្យ ដាច់ស្រឡះពុំទាន់បាន ។ ឯការដែលនឹងកំចាត់ទោសោឲ្យដាច់ជ្រះស្រឡះ នោះ មានតែវិស័យព្រះអរិយបុគ្គលប៉ុណ្ណោះ ។ បុថុជ្ជនយើងលះមិនដាច់ ស្រឡះទេ បើខំណាស់ បានត្រឹមតែសង្កត់ទុក ដូចយកថ្មសង្កត់ស្មៅ ប៉ុណ្ណោះ ក៏ចាត់ថាជាការវិសេសណាស់ទៅហើយ ។ ការលះទោសោ

បាន អាស្រ័យចំរើនមេត្តានឹងដកលំខ្លួនឲ្យតាំងនៅក្នុងខន្តី ក៏អាស្រ័យចំរើនមេត្តា, លុះត្រាតែលះទោសោបានហើយស្ថិតនៅក្នុងខន្តី ទើបឈ្មោះថាដកលំខ្លួនទុកក្នុងអទោសោ មានអទោសោបរិបូណ៌ក្នុងសន្តាន បើបុគ្គលប្រកបដោយអទោសោហើយ ក៏នឹងបាននូវខន្តី លុះបានខន្តីហើយក៏ប្រកបដោយអានិសង្សច្រើនរាប់មិនអស់ កាលបានខន្តីហើយ ក៏ចាត់ថាបានតបស្នងព្រះពុទ្ធដីកា ដែលទ្រង់ប្រោសប្រទានត្រាស់ព្រះសទ្ធម្មទេសនាទុកថា ខន្តីបរមំ តបោ តីតិក្ខា ខន្តីគឺសេចក្តីអត់សង្កត់ចិត្ត ឈ្មោះថាជាតបៈយ៉ាងក្រៃលែងយ៉ាងឧត្តម តថាគតត្រាស់ហៅនូវបុគ្គលដែលបានខន្តីនោះថាជាខីណាសវព្រាហ្មណ៍ គ្មានទីពឹងអ្វីដទៃប្រសើរជាងខន្តីទេ គឺដោយសារតែអានិសង្សនៃខន្តី ហើយទើបបាននូវមេត្តា លុះបានមេត្តាហើយក៏ប្រកបដោយអានិសង្ស ១១ ប្រការ សមតាមក្រៃសព្រះពុទ្ធបរិហារ ប្រទានព្រះសទ្ធម្មទេសនាទុកក្នុងបឋមកាណ្ឌៈ ដែលព្រះអដ្ឋកថាចារ្យពោលទុកក្នុងគម្ពីរសារត្ថសមុច្ច័យថា ព្រះមានព្រះភាគត្រាស់ទេសនាថា បុគ្គលប្រកបដោយមេត្តាភាវនាមានអានិសង្ស ១១ ប្រការ គឺ

១– សុខំ សុបតិ ដេកលក់ជាសុខ មិនយល់សប្តិឃើញអាក្រក់ ដូចឃើញដីរព្រៃផ្សចោរប្រហារជាដើម ។

២– សុខំ បដិពុជ្ឈតិ ភ្ញាក់ពីលក់ក៏ជាសុខ ។

៣– ជាទីស្រឡាញ់របស់មនុស្សនិងទេវតា ។

៤– នៅក្នុងប្រទេសណាហើយចេញពីទីលំនៅរបស់ខ្លួនចូលទៅក្នុងស្រុកនិគមជនបទណា ៗ ទេពតាទាំងឡាយនឹងរក្សាការពារមិនឲ្យមានអន្តរាយដល់ខ្លួន ។

៥– បុគ្គលស្អប់ខឹងនឹងដាក់ថ្នាំពិសឲ្យផឹកឲ្យស៊ី នឹងដុតដោយភ្លើង នឹងប្រហារដោយគ្រឿងសាស្ត្រាវុធ ក៏រួចផុតចេញបាន មិនត្រូវគ្រោះថ្នាក់ទាំងនោះឡើយ ។

៦– ចិត្តតាំងមាំជាសមាធិយ៉ាងឆាប់រហ័ស ។

៧– មានពណ៌សម្បុរស្បែកជ្រះថ្លាបរិសុទ្ធ ដូចរស្មីព្រះចន្ទពេញបូណ៌មីនៃខែកត្តិក ប្រាសចាកពពក ។

៨– អសម្មុឡ្ហោ កាលំ ករោតិ អ្នកប្រកបដោយមេត្តាដល់វេលាជិតស្លាប់ មិនវង្វេងភ្លេចគុណព្រះរតនត្រ័យ ភ្លេចសីលទានឡើយ ។

៩– ស្លាប់ហើយបានទៅកើតនៅស្ថានសួគ៌ ។

១០– បើមិនទាន់បានសម្រេចមគ្គផលទេ វេលាស្លាប់ហើយតែងទៅកើតក្នុងព្រហ្មលោក ដោយអំណាចបានចំរើនមេត្តា ។

១១–អ្នកបានចំរើនមេត្តាព្រហ្មវិហារ តែងលះបង់ទោសោចេញបាន ដំកល់ខ្លួនទុកក្នុងអទោសោបាន នឹងតាំងនៅក្នុងខន្តី ។

ការចំរើនមេត្តាព្រហ្មវិហារនោះ បុគ្គលមិនងាយនឹងចំរើនបានទេ លុះតែបានពិចារណាឲ្យឃើញទោសរបស់ទោសោ នឹងចារណាឲ្យឃើញ

អានិសង្សរបស់ខន្តី ទើបអាចចំរើនមេត្តាភាវនាបាន ។

បើចំរើនមេត្តាភាវនា ត្រូវនឹករឭកដល់មនុស្សដែលជាទោស ជាសត្រូវនឹងខ្លួនយើងឲ្យឃើញថា មនុស្សនេះៗ មិនគួរអញនឹងផ្សាយមេត្តាទេ លុះឃើញមនុស្សមិនគួរផ្សាយមេត្តាហើយ ក៏កុំផ្សាយមេត្តាទៅលើអ្នកនោះ ។

បុគ្គលដែលមិនគួរផ្សាយមេត្តានោះ គឺបុគ្គលមិនជាទីស្រឡាញ់មួយពួក មិនជាទីស្រឡាញ់ជិតស្និទ្ធនឹងខ្លួនយើងមួយពួក មិត្តសំឡាញ់នៃខ្លួននៅជាកណ្តាលៗ មិនស្រឡាញ់ពេក មិនស្អប់ពេកមួយពួក បុគ្គលមានពៀរមួយពួក បុគ្គល ៤ ពួកនេះ កុំគប្បីផ្សាយមេត្តាទៅដល់មុន ។

បុគ្គលមិនគួរផ្សាយមេត្តាទៅកាន់អារម្មណ៍មិនស្មើ គឺកុំផ្សាយទៅកាន់ភេទស្រី នឹងកុំផ្សាយទៅកាន់សាកសពដែលស្លាប់ហើយ ។

មានពាក្យបុច្ឆាថា កឹ ការណា ព្រោះហេតុអ្វីបានជាមិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គល ៤ ពួកជាមុន នឹងទៅកាន់ភេទស្រ្តី នឹងកាន់សាកសពដូច្នោះ ?

មានពាក្យវិសជ្ជនាថា អប្បិយំ ហិ បិយដ្ឋានេ ឋបេន្តោ ការដែលលោកហាម មិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គលមិនជាទីស្រឡាញ់នោះ ព្រោះហេតុថាបុគ្គលនឹងតាំងបុគ្គលដែលខ្លួនមិនស្រឡាញ់ទុកកាន់ទីជាទីស្រឡាញ់នោះក្រនឹងតាំងបានណាស់ តែងលំបាកចិត្ត ។ ដែលលោកហាមមិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គលដែលខ្លួនស្រឡាញ់ខ្លាំង តែង

លំបាកនឿយព្រួយចិត្ត   កាលបើសំឡាញ់ជិតស្និទ្ធរបស់ខ្លួនទោះមានទុក្ខតែបន្តិចបន្តួច   ក៏ជួយព្រួយចិត្តយំសោក   មិនអាចនឹងតាំងចិត្តឲ្យស្ថិតនៅជាកណ្តាលបាន ។ ហេតុដូច្នោះ ទើបមិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គលដ៏ជាសហាយជាទីស្រឡាញ់មុន ។

ការដែលនឹងផ្សាយមេត្តាទៅកាន់បុគ្គលជាទីស្រឡាញ់កណ្តាលៗ គឺមិនស្រឡាញ់ពេក   មិនស្អប់ពេកនោះ   នឹងតាំងទុកកាន់ទីគោរពក៏លំបាកនឹងតាំងទុកកាន់ទីស្រឡាញ់   ក៏កម្រនឹងតាំងបាន,   ហេតុនោះ   មិនឲ្យផ្សាយមេត្តាទៅកាន់សំឡាញ់កណ្តាល ៗ ជាមុន ។

បើ អនុស្សរតោ   យោគាវចរកុលបុត្រ   កាលរឭករឿយ ៗ នូវបុគ្គលដែលមានពៀរនឹងខ្លួននោះ រមែងកើតសេចក្តីក្រោធខឹង   ហេតុនោះទើបលោកហាមមិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គលដែលមានពៀរនឹងខ្លួន ។

ភាវេន្តស្ស   កាលភិក្ខុចំរើននូវមេត្តា   កាន់អារម្មណ៍ជាវិសភាគារម្មណ៍ដោយអំណាចនៃភេទ   គឺផ្សាយមេត្តាទៅកាន់ភេទស្រី   ក៏កើតរាគៈ(សេចក្តីតម្រេក) ឡើង មេត្តាមិនចំរើន   ត្រឡប់ជាធ្លាក់ទៅខាងតម្រេកវិញដូចជាបុត្រអមាត្យម្នាក់   មានសេចក្តីដំណាលថា ៖

(នៅមានត)

មធុរសវាហិនី

សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹង ពិនិត្យ

( តមក )

---

# កាញ្ចនទេវីត្ថុកថា

សំដែងរឿងនាងកាញ្ចនទេវីតទៅទៀតដោយបាលីថា :

ជម្ពុទីបេ កិរ ទេវបុត្តំ នាម ឧស្សជីយំ ឃតំ ឆតំ អហោសិ ដូច្នេះជាដើម ។

អធិប្បាយថា: ដូចបានព្រះរៀង ៗ មកថា : មាននគរមួយគួរជាទីគយគន់មើលដល់ប្រជុំជន ឈ្មោះ "ទេវបុត្តនគរ" ក្នុងជម្ពូទ្វីបនេះឯង ។

កាលនោះ មនុស្សទាំងឡាយបានបាត្រកែវដែលជាគ្រឿងបរិភោគនៃព្រះមានព្រះភាគ ហើយចាត់ចែងលេងមហោស្រព ធ្វើពិធីបូជាបាត្រកែវរបស់ព្រះសម្មាសម្ពុទ្ធជាអនេក នឹងគណនាត្រាប់ពុំបានឡើយ ទើបពិធីនោះបានឈ្មោះថា មហាបត្តពិធីបូជាបាត្រ ដោយពិត ។

សម័យនោះឯង ព្រះបរមក្សត្រិយ៍ក្នុងទេវបុត្តនគរ ព្រះអង្គចាត់សេវកា-មាត្យទាំងឡាយ ឲ្យសំអាងរាជរថដោយគ្រឿងអលង្ការទាំងពួង ហើយស្ដេចត្រាស់បង្គាប់ឲ្យទឹមសេះសិន្ធពបួន មានសម្បុរដូចស្លឹកក្រមុទ (១)

---

១ ផ្លូវគ្របកផ្កាក្រមុទ កំបិ ។

រួចស្តេចឲ្យធ្វើប្រដាប់បាត្រកែវ ដែលព្រះបរមសាស្តាតែងប្រើប្រាស់ លើចុងឫស្សីមានកំពស់ប៉ែតសិបហត្ថ ដែលជាងអ្នកចេះស្ទាត់បានវិចិត្រ សំរេចដោយកែវទាំង ៧ ប្រការ លើកឡើងចងភ្ជាប់នឹងចុងឫស្សី ហើយឲ្យលើកឫស្សីឡើងបញ្ឈរលើរាជរថ ស្រេចស្តេចត្រាស់ឲ្យធ្វើប្រដាប់តាក់តែងព្រះនគរដ៏ល្អបីដូចជាទេវនគរ ឲ្យលើកឡើងនូវទង់ជ័យ ទង់ជ្រុងទាំងឡាយ ហើយឲ្យដម្កល់នូវក្អមទឹកអប់ទាំងឡាយផង នូវផ្កាកម្រងទាំងឡាយផង ហើយស្តេចចាត់ឲ្យសេវកាមាត្យព្រមទាំងមហាជនទាំងឡាយ ដង្ហែប្រទក្សិណជុំវិញព្រះនគរ ដោយវិធីបូជាដ៏ឧឡារិកអធិកច្រើនជាអនេក រួចដង្ហែចូលមកក្នុងព្រះនគរវិញ ឲ្យដម្កល់នូវព្រះបត្ត-ធាតុ ក្នុងមណ្ឌបកែវដែលបុគ្គលតាក់តែងដោយប្រពៃក្នុងកណ្តាលព្រះនគរ រួចហើយស្តេចត្រាស់បង្គាប់ឲ្យធ្វើមហាសទ្ធម្មស្សវនកិច្ច ឃោសនាឲ្យប្រជុំគ្នាស្តាប់ព្រះធម៌ទេសនាកំណត់ ៧ ថ្ងៃ ទើបឈប់ ។

កាលនោះ មនុស្សជាច្រើនដែលនៅក្នុងជនបទនោះក្តី ទេវតាទាំងឡាយក្តី យក្សអារក្សទឹកនាគគ្រុឌទាំងឡាយក្តី សឹងចូលមកប្រជុំគ្នាដោយច្រើនក្រៃពេក ដោយហេតុមនុស្សអ្នកក្រុងប្រជុំគ្នានោះ ។

ឯវិធីបូជាព្រះបត្តធាតុរបស់ព្រះបរមគ្រូសាស្តាចារ្យជាអម្ចាស់នៃយើង ជាអស្ចារ្យមានសភាពដូច្នេះឯង ។

គ្រានោះ មានស្តេចនាគមួយមានមហិទ្ធិរិទ្ធិ មានអានុភាពច្រើន

បានចូលមកកាន់ទីប្រជុំ ស្តាប់ព្រះធម្មទេសនាដែរ ក៏បានឃើញនាងកុមារិកាម្នាក់មកពីទិសខាងកើត មានរូបឧត្តមសមរម្យល្អ អង្គុយនៅក្នុងបំណោមបរិស័ទនោះ ស្តេចនាគក៏មានចិត្តបដិពទ្ធស្នេហាស្រឡាញ់ចង់បាននាងកុមារិកានោះធ្វើជាភរិយានៃខ្លួន បាននិយាយល្បួងលួងលោមនាងកុមារិកានោះដោយការប្រលោមផ្សេងៗ ជាច្រើនដង ច្រើនគ្រា កាលបើពុំបានសម្រេចសេចក្តីព្រមព្រៀងអំពីនាងកុមារិកានោះសោះ ក៏ដល់នូវការក្រោធខឹងយ៉ាងខ្លាំង បញ្ចេញខ្យល់ពិសពីប្រមុះ បំពុលទៅ ដោយគិតថា អាត្មាអញនឹងសម្លាប់នាងកុមារិកានេះឲ្យស្លាប់ឥឡូវនេះឯង ។

ទោះបីនាគរាជនោះខំព្យាយាមយ៉ាងណា ក៏គង់ពុំអាចនឹងធ្វើនាងកុមារិកានោះឲ្យកម្រើកបានឡើយ ដោយកម្លាំងសទ្ធារបស់នាងនោះឯង ។

លំដាប់នោះ នាគរាជខឹងខ្លាំងពន់ពេក ទើបពេនខ្លួនព័ន្ធព័ទ្ធនូវសរីរៈទាំងអស់នៃនាងកុមារិកានោះ តាំងពីបាទ ជើងដរាបដល់ក្បាលជាទីបំផុត ហើយដកពពារគ្របពីលើក្បាល ញ៉ាំងនាងកុមារិកានោះឲ្យភ័យខ្លាច ស្ងៀតនៅក្នុងទីនោះឯង ។

ឯនាងកុមារិកានោះសោត នាងមានចិត្តពុំបានភ័យខ្លាចឡើយ ដោយតេជះកម្លាំងដែលនាងប្រុងស្តាប់ព្រះធម្មទេសនា ដោយគោរពនោះ សូម្បីតែសេចក្តីទុក្ខលំបាកតិចតួចក៏ពុំមានដល់នាងឡើយ ។

លុះរាត្រីភ្លឺច្បាស់ ព្រះអរុណរះឡើង មនុស្សទាំងឡាយបាន

ឃើញហេតុគួរជាទីអស្ចារ្យនោះហើយ សួរថា ម្នាលនាងដ៏ចំរើន ! ការណ៍នេះជាហេតុដូចម្តេច ? ។

ទើបនាងកុមារិកាបានសំដែងប្រាប់ហេតុនោះ ដល់ពួកមនុស្សដែលពុំបានដឹងដោយសព្វគ្រប់ហើយ ក៏ពោលជាបទព្រះគាថាដូច្នេះថា:

ព្រហ្មចារី អហោ សាហំ សញ្ញតា ឥធ មានុសេ្ស
តេន សច្ចេន មំ ឆាតោ ខិប្បមេវ បមុញ្ចតុ ។

អធិប្បាយថា: ខ្ញុំគួរអស្ចារ្យណាស់ ខ្ញុំព្រះករុណាបានកើតក្នុងជាតិជាមនុស្ស ហើយបានប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺបានស្តាប់ធម្មទេសនាដោយគោរព, ដោយតេជះសច្ចធម៌នោះ សូមនាគពជដែលមានពិសដ៏ពន្ទឹកលែងខ្ញុំឲ្យបានរួចឆាប់ដោយពិត ។

កាមតុរស្ស ឆាតស្ស នោភាសមការិយតោ
តេន សច្ចេន មំ ឆាតោ ខិប្បមេវ បមុញ្ចតុ ។

ខ្ញុំព្រះករុណាពុំបានធ្វើនូវឱកាស (គឺការស្នេហា) ដល់នាគពជអ្នកក្តៅក្រហាយដោយកាមគុណ, ដោយតេជះសច្ចធម៌នោះ សូមនាគពជដែលមានពិសដ៏ពន្ទឹកលែងខ្ញុំឲ្យបានរួចឆាប់ដោយពិត ។

ទិស្វាន កុប្បិតំ ឆាតំ កុប្បិតស្ស តេសុហំ
អកុទ្ធា តេន សច្ចេន សោ មំ ខិប្បំ បមុញ្ចតុ ។

ខ្ញុំព្រះករុណាបានឃើញនាគពជ ក្រោធខឹងហើយ ពុំបានខឹងតប

ដល់ពស់នាគរាជដែលក្រោធខឹងខ្លាំងវិញឡើយ ,   ដោយតេជះសច្ចធម៌នោះ  នាគរាជនោះ  សូមលែងខ្ញុំឲ្យឆាប់ ។

សទ្ធម្មំ សុណមានាហំ   គរុការំ សមាចិយំ
អស្សោសឹ តេន សច្ចេន   ខិប្បមេវ បមុញ្ចតុ ។

ខ្ញុំព្រះករុណាកំពុងប្រុងស្តាប់ព្រះសទ្ធម្មហើយ  អាចអត់ធន់នូវការជាមុន  បានស្តាប់ដរាបដល់ចប់,  ដោយតេជះសច្ចធម៌នោះ  សូមនាគរាជដែលមានពិសដ៏ពន្លឹកលែងខ្ញុំឲ្យរួចដោយឆាប់ ។

ន អក្ខរំ ធានំ វាបិ   វិនាសេត្តិ យតោហំ
អស្សោសឹ តេន សច្ចេន   ខិប្បំ នាគោ បមុញ្ចតុ ។

ខ្ញុំព្រះករុណាពុំបានញុំាងអក្ខរៈនឹងបាទឲ្យវិនាសបាត់បង់ឡើយ  ខ្ញុំប្រុងស្តាប់ព្រះសទ្ធម្មដោយគោរព,  ដោយសតេជះសច្ចធម៌នោះ  សូមនាគរាជដែលមានពិសដ៏ពន្លឹកលែងខ្ញុំឲ្យឆាប់រហ័ស ។

សច្ចកិរិយាវសានេ  កាលបើនាងកុមារិកាបានធ្វើសច្ចកិរិយាចប់ស្រេចហើយ  នាគរាជក៏មានចិត្តជ្រះថ្លាពន់ពេកដល់នាងកុមារិកានោះ  ទើបរំសាយភ្លេនដែលពេនព័ទ្ធនាងកុមារិកាចេញមួយរំពេច  ហើយនិម្មិតជាពពារមួយឲ្យនាងកុមារិកាអង្គុយលើពពារនោះ  ហើយធ្វើនូវកិរិយាបូជាលើខ្នងទឹកជាមួយនឹងនាគមាណពទាំងឡាយ  មានប្រមាណច្រើនក្នុងកាលនោះឯង ។

ឯមនុស្សជាច្រើនដែលនៅក្នុងនគរ លុះបានឃើញហេតុនោះហើយ កំកើតសេចក្ដីស្ញើបអស្ចារ្យក្នុងចិត្តដ៏ក្រៃលែង បានបូជានាងកុមារិកានោះ ដោយទ្រព្យចំនួន ១៨ កោដិក្នុងវេលានោះហោង ។

សេចក្ដីពិតដូច្នោះ បានជាព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាថា :

ឥត្ថិ សទ្ធា សមោ លោកេ សុរត៌ សព្វកាមទោ
បស្សថស្ស ពលិ សទ្ធា បូជេន្តិ (ក) ឥធ ជាតោ ។

អធិប្បាយថា: សភាពគ្រឿងអប់ដែលមានក្លិនក្រអូប អាចឲ្យនូវសម្បត្តិទាំងពួង ប្រាកដស្មើដោយសទ្ធាក្នុងលោកពុំមានឡើយ ។ អ្នកទាំងឡាយចូរមើលនូវកម្លាំងសទ្ធារបស់នាងកុមារិកានោះចុះ ពោះនរជនក្ដី នាគកពក្ដី បានបូជាសម្បត្តិទាំងពួង (ដល់នាងកុមារិកានោះ) ។

នហ លោកេ វិស្សា លទ្ធំ អវកោកមព បច្ចតិ
តស្មា សទ្ធេន ភាគត្វំ រតនត្តយការិ ។

គោតសម្បត្តិក្នុងកពដ៏ច្រើនកប់ពុំបានឮដ៏មនុស្សលោកនេះ ដែលនាងកុមារិកានោះបានហើយដោយពិត ។

ព្រោះហេតុដូច្នោះ បុគ្គលអ្នកមានសទ្ធា គួរធ្វើសេចក្ដីគោរពក្នុងគុណព្រះរតនត្រ័យសព្វ១ កាល ។

លុះនាងកុមារិកាបានសម្បត្តិច្រើនយ៉ាងនេះហើយ កំបានប្រព្រឹត្ត

នូវកុសលធម៌ដ៏ប្រសើរដែលបានបំពេញអស់កាលយូរ ហើយធ្វើមរណកាលទៅចាប់បដិសន្ធិក្នុងផ្ទៃព្រះអគ្គមហេសីនៃព្រះបរមក្សត្រិយ៍ក្នុងនគរនោះឯង ។

លុះនៅក្នុងព្រះឧទរគ្រប់ ១០ ខែបរិបូណ៌ហើយ ក៏បានប្រសូតិចេញចាកព្រះឧទរនៃព្រះមាតានោះដោយសួស្តីភាព ។

ខណៈដែលនាងធីតាបានប្រសូតិចេញចាកព្រះឧទរ នៃព្រះមាតាមកនោះក៏បង្កើតជាអស្ចារ្យ បណ្តាលឲ្យមានភ្លៀងកែវ ៧ ប្រការបង្អុរធ្លាក់ចុះមកក្នុងទេវបុត្តនគរទាំងមូល ព្រោះហេតុដូច្នោះ បានជាព្រះរាជបិតាព្រះរាជជននីនាថ ព្រមទាំងព្រះរាជវង្សានុវង្ស បានសន្មតព្រះនាមធីតានោះថា "កាញ្ចនទេវី" ដោយពិត ។

ឯនាងកាញ្ចនទេវីនោះ នាងមានរូបឆោមលោមពណ៌ល្អប្រៀបដូចស្រីទេពអប្សរជាទីនាំមកនូវសេចក្តីជ្រះថ្លា គ្រប់គេដែលប្រទះជួប នាងមានក្លិនក្រអូបដូចផ្កាឧប្បល ផ្សាយចេញអំពីមាត់ផង មានក្លិនក្រអូបដូចខ្លឹមចន្ទន៍ផ្សាយចេញអំពីសរីរៈផង និងមានពន្លឺរស្មីភ្លឺស្វាងរុងរឿង ដូចពន្លឺព្រះអាទិត្យពេញកម្លាំងផ្សាយចេញអំពីសរីរៈទាំងអស់ផង ។

កិច្ចដែលត្រូវអុជគោមប្រទីបផ្កាលក្នុងល្វែងប្រមាណបួនហត្ថ នៅវេលាយប់ពុំមានសោះឡើយ ឯល្វែងទាំងពួងសឹងមានពន្លឺស្វាងរុងរឿងតែមួយដោយពន្លឺរស្មីនៃនាងកាញ្ចនទេវីនោះឯង ។

ទាំងរូបសម្បត្តិរបស់នាងកាញ្ចនទេវីនោះទៀត ក៏ល្បីខ្ចរខ្ចាយ

សាយសព្ទទៅប្រាកដក្នុងជម្ពូទ្វីបទាំងអស់ ដោយផលានិសង្សដែលនាង
មានសទ្ធាមាំបានស្តាប់ព្រះធម្មទេសនាដោយគោរពនោះឯង ។

គ្រានោះ ព្រះរាជាទាំងឡាយ ដែលសោយរាជ្យនៅក្នុងជម្ពូទ្វីប បានជ្រាបពតិមាននោះ ហើយក៏បញ្ជូននូវគ្រឿងបណ្ណាការជាច្រើន ទៅថ្វាយព្រះបរមក្សត្រិយ៍ជាព្រះវររាជបិតា ដើម្បីប្រយោជន៍នឹងដណ្តឹងយកនាងកាញ្ចនទេវីនោះមកអភិសេកជាព្រះអគ្គមហេសីនៃខ្លួនទីទៃ ៗ ដោយលោកតណ្ហានោះឯង ។

ចំណែកឯនាងកាញ្ចនទេវីនោះសោត នាងពុំមានចិត្តជាប់ជំពាក់ក្នុងកាមគុណទាំងប្រាំឡើយ ហើយនាងសូមអង្វរព្រះវររាជបិតា សូមព្រះរាជានុញ្ញាត ថ្វាយបង្គំលាចេញទៅកាន់សំណាក់នាងភិក្ខុនី ហើយសូមផ្នួសបួសជាភិក្ខុនី បានចំរើននូវវិបស្សនាកម្មដ្ឋានដរាបដល់បានសម្រេចព្រះអរហត្ត កំចាត់បង់នូវកិលេសទាំងពួង ព្រមទាំងបដិសម្ភិទាញាណទាំងបួន មាននាមប្រាកដថា "កាញ្ចនថេរី" លុះអស់ព្រះជន្មាយុក៏បានចូលព្រះនិព្វានទៅហោង ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយអ្នកតែងគម្ពីរនេះ លោកពោលជាបទព្រះគាថាដូច្នេះថា :

សុត្វាន សាទរវេន កុមារិកា
ធម្មំ ហិ សីលមមលម្បិ ចារយន្តី

លទ្ធាននេកវិភវំ វិភវំ បយាតា
មា ខោ បមជ្ជថ សរោ កុសលប្បយោគេ ។

អធិប្បាយថា: នាងកុមារិកានោះឯង នាងបានស្តាប់ធម្មទេសនាដោយសេចក្តីគោរពល្អ ហើយបានរក្សានូវសីលប្រាំសីលប្រាំបីដ៏ស្អាតល្អបរិសុទ្ធ មិនមានសៅហ្មងឡើយ នាងបាននូវសម្បត្តិច្រើនជាអនេកទឹងគណនាគ្រាប់ពុំបាន ព្រមទាំងបានសម្រេចនូវសម្បត្តិព្រះនិព្វានទៀត ព្រោះលះបង់អំពើអកុសលដោយពិត ។

បពិត្រអ្នកទាំងឡាយដ៏ចំរើន ! អ្នកទាំងឡាយមិនត្រូវប្រមាទប្រហែសធ្វេសក្នុងការប្រកបព្យាយាមសន្សំនូវកុសលធម៌ឡើយ ត្រូវតែខំស្អាងទានសីលភាវនាឲ្យមាំមួនសព្វ ៗ កាលតទៅជាដរាប ។

សំដែងរឿងនិទាននាងកាញ្ចនទេវី ជាគំរប់បួន ក្នុងវគ្គទីពីរ ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង ។

(នៅមានត)

# មហោសថជាតក

## លោក អ៊ុម-ភង បម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គិម-គួរ ពិនិត្យ

(តមក)

ស្ដេចស្ដាប់ពាក្យអាចារ្យសេនកស្រដីដូច្នោះហើយ ស្ដេចមានព្រះបន្ទូលទៅនឹងពោធិសត្វថា តាត មហោសថ ម្នាលបាមហោសថអើយ រីអាចារ្យសេនកស្រដីថាដូច្នេះ តើបាយល់ដូចម្ដេច ? ពោធិសត្វទូលថា បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ! រីអាចារ្យសេនកពោះកំប៉ោងនេះ តើគាត់ចេះដឹងអ្វីព្រះអង្គ! សូមអញ្ជើញស្ដេចស្ដាប់ខ្ញុំនឹងសំដែងថ្វាយ ទើបពោធិសត្វសូត្រនូវព្រះគាថាដូច្នេះថា :

ន សាធុ ពលវា ពាលោ
សាហសំ វិន្ទតេ ធនំ
កន្ទន្តមេតំ ទុម្មេធំ
កឌ្ឍន្តិ និរយំ ភុសំ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះមហារាជអើយ! រីអ្នកកំឡៅប្រកបដោយកំឡាំងច្រើននោះ ពុំប្រពៃទេឡើយ ; រីអំពើនឹងបង្កើតទ្រព្យនោះ សឹងធ្វើដោយនូវអំណាច

សោះសា កាលណាបើស្លាប់ទៅហើយ, រីយមបាលជានាយនរក ក៏នឹងយកខ្លួសនៃអ្នកកំឡៅនោះ បោះទៅលទៅក្នុងភ្លើងនរក នឹងយំជាទុក្ខពន្លឹកមហិមា, ហេតុនោះ ខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញានោះប្រសើរ, ឯអ្នកកំឡៅមានយសនោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ហើយ មានព្រះបន្ទូលទៅនឹងអាចារ្យសេនកថា ម្តេចទៅអាចារ្យ ឥឡូវនេះចៅមហោសថថាដូច្នេះ, អាចារ្យឯងតើថាដូចម្តេច? អាចារ្យសេនកស្តាប់ហើយទូលព្រះមហាក្សត្រសូត្រនូវបទគាថាដូច្នេះថា :

យា កាចិ នជ្ជោ អភិសវន្តិ គង្គំ
សព្វា តា នាមគោត្តំ ជហន្តិ
គង្គា សមុទ្ទំ បដិបជ្ជមានា
ន ខាយតេ ឥទ្ធិវរេ ហិ លោកេ
ឯតម្បិ និស្វាន អហំ វទាមិ
បញ្ញា វិហីនោ សិរិមាវ សេយ្យាតិ ។

បពិត្រព្រះមហារាជអើយ! រីស្ទឹងទាំងឡាយ សឹងហូរទៅកាន់គង្គានទី ស្ទឹងតូចផងនោះ ក៏លះបង់ឈ្មោះកំណើត ហៅជាស្ទឹងធំវិញ, រីស្ទឹងធំនោះក៏ហូរទៅកាន់សមុទ្ទ សឹងលះបង់ឈ្មោះកំណើត ហៅថាសមុទ្ទវិញ មានប្រការដូចម្តេចមិញ, រីអ្នកមានប្រាជ្ញាប្រសើរ តែឥតសម្បត្តិឮដ៏ពេកនេះ, បើកាលណាទៅជាអ្នកមានសម្បត្តិហើយ ពុំយល់ប្រាកដ

ឡើយ; ឧបមាដូចស្ទឹងបឹងហូរទៅកាន់សមុទ្រនោះហោង, ហេតុនោះ ខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញ តែឥតសម្បត្តិពុំប្រសើរឡើយ, រីឯ អ្នកមានប្រាជ្ញាហើយប្រកបដោយសម្បត្តិផង នោះទើបប្រសើរ ។

ស្តេចស្តាប់ហើយ មានព្រះបន្ទូលដណ្តឹងទៅពោធិសត្វវិញថា ម្នាល ប៉ាមហោសថអើយ! ប៉ានឹងឆ្លើយដូចម្តេច? រីព្រះមហោសថស្តាប់ហើយ ទូលថា បពិត្រក្សត្រថ្លៃប្រសើរអើយ! សូមអញ្ជើញស្តេចស្តាប់ ទើប ពោធិសត្វសូត្រនូវគាថានេះថា :

យមេតមត្ថា ឧទធឹ មហន្តំ
បវន្តិ នជ្ជោ សព្វកាលំ អសំខ្យំ
សោ សាគរោ និច្ចមុឡារវេគោ
វេលំ នាច្ចេតិ សោ មហាសមុទ្ទោ ។
ឯវម្បិ ពាលស្ស បជប្បិតានិ
បញ្ញំ នាច្ចេតិ សិរី កទាចិ
ឯតម្បិ ញត្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ! រីអាចារ្យសេនកស្រដី ថា ទឹកសមុទ្រនោះធំហើយ, ស្ទឹងតូចទាំងឡាយសឹងហូរទៅកាន់សមុទ្រឥត ឈប់ពុំបានឡើយ, បពិត្រមហារាជអើយ! រីសមុទ្រនោះសោតទោះបីន

រលកបែកខ្ចរខ្ចាយយ៉ាងណាក្តី ក៏ពុំដែលកន្លងច្រាំងនោះបានឡើយ, មាន ប្រការម្តេចមិញ, អ្នកពាលទាំងឡាយ មានសម្បត្តិច្រើនអម្បាលមាណក្តី ក៏ពុំអាចដើម្បីនឹងកន្លងអ្នកប្រាជ្ញនោះបាន មានសភាពដូចរលកពុំដែលកន្លងច្រាំងបានដូច្នោះ ខ្ញុំយល់ហេតុនោះហើយបានជាខ្ញុំថា អ្នកប្រាជ្ញនោះប្រសើរ, អ្នកខ្លៅមានយសសម្បត្តិនោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ពាក្យនោះហើយ មានព្រះបន្ទូលដណ្តឹងទៅថា សេនកអាចារ្យសេនកអើយ ! អ្នកថាដូចម្តេចទៀត ? ។ អាចារ្យសេនកទូលព្រះមហាក្សត្រ សូត្រជាបទគាថាដូច្នេះថា:

អសញ្ញតោ ចេបិ បរេសមត្តំ
ភណាតិ សណ្ឋានគតោ យសស្សី
តស្សេតំ រូហតិ ញាតិមជ្ឈេ
សិរីហិ នំ ការយតេ ន បញ្ញា
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រព្រះមហារាជអើយ! អ្នកខ្លៅហើយមានយសបរិវារ បើអង្គុយនាឋានទីណា ទោះយោបល់ស្រដីពីអាថ៌សេចក្តីអ្វីមួយនឹងអ្នកដទៃក្រៅនៃមណ្ឌលក្រុមជំនុំ, ពាក្យអ្នកនោះយល់ថ្កើងរុងរឿងប្រពៃពេញដំកណ្តាលជំនុំនៃញាតិផង, អ្នកមានប្រាជ្ញាថយលែងទទឹងឥស្សរសម្បត្តិ ក៏ធ្វើការយល់

ជាពុំថ្កើនរុងរឿងក្នុងកណ្ដាលជំនុំញាតិផងឡើយ ខ្ញុំយល់នូវហេតុនោះ ហើយបានជាខ្ញុំថា អ្នកមានសិរីសម្បត្តិនោះប្រសើរ, រីអ្នកមានប្រាជ្ញា ថយវៃលងសម្បត្តិនោះពុំប្រសើរឡើយ ។

ស្ដេចស្ដាប់ហើយ ដណ្ដឹងទៅពោធិសត្វថា បាមហោសថអើយ! អ្នកទឹងថាដូចម្ដេច? ពោធិសត្វទូលថា បពិត្រក្សត្រប្រសើរអើយ! រីអាចារ្យសេនកកំឡៅនេះ ទឹងដឹងអ្វី សូមអញ្ជើញស្ដេចស្ដាប់ខ្ញុំ ទើបពោធិសត្វសូត្រនូវគាថានេះថា:

បរស្ស វា អត្តនោ វាបិ ហេតុ
ពាលោ មុសា ភាសតិ អប្បបញ្ញោ
សោ និន្ទិតោ ហោតិ សភាយ មជ្ឈេ
បច្ឆាបិ សោ ទុគ្គតិគាមី ហោតិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះមហាក្សត្រប្រសើរអើយ! រីអ្នកកំឡៅឥតប្រាជ្ញា ស្រដីនូវពាក្យមុសាវាទ ហេតុចង់បានប្រយោជន៍នៃអាត្មាឯងក្ដី ហេតុប្រយោជន៍អ្នកដទៃនោះក្ដី, អ្នកដ៏មានធម៌សប្បុរសផងទាំងឡាយ សឹងតិះដៀលក្នុងកណ្ដាលជំនុំ, លុះចំណេរទៅឯខាងមុខ ទឹងនាំអាត្មាទៅក្នុងចតុរា-បាយ មាននរកជាដើម, ខ្ញុំយល់ហេតុនោះហើយបានជាខ្ញុំ អ្នកមាន

ប្រាជ្ញានោះប្រសើរ រីឯអ្នកកំឡៅមានយសសម្បត្តិនោះពុំប្រសើរឡើយ ។

លំដាប់នោះ, អាចារ្យសេនកស្ដាប់ហើយ ទូលព្រះមហាក្សត្រ សូត្រនូវបទគាថាដូច្នេះថា :

អត្ថម្បិ យេ ភាសតិ ភូរិបញ្ញោ
អនាលយោ អប្បធនោ ទលិទ្ទោ
ន តស្ស តំ រូហតិ ញាតិមជ្ឈេ
សិរីញ្ញាណាវតោ ច ន ហោតិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រព្រះមហាពជអើយ ! រីអ្នកមានប្រាជ្ញាច្រើន ហើយឥតសម្បត្តិទ្រព្យ ខ្សត់ទុគ៌ត កាលណាបើស្រដីនូវអាថ៌សេចក្ដីជាប្រយោជន៍ក្ដី កណ្ដាលពពួកញាតិផងទាំងឡាយក្ដី ក៏ពុំចំរើនរុងរឿងឡើយ, មួយទៀតពោះឃាប៉ីអ្នកនោះនឹងទៅកាន់អ្នកដ៏មានឥស្សរសម្បត្តិនោះក្ដី ក៏ពុំយល់ប្រាកដ, ឧបមាបីដូចអំពិលអំពែកត្រូវពន្លឺព្រះអាទិត្យដែលឧទ័យឡើងនោះហោង; ខ្ញុំយល់ហេតុនោះហើយបានជាខ្ញុំថា អ្នកមានសម្បត្តិនោះប្រសើរ, រីអ្នកប្រាជ្ញាចយលែងសម្បត្តិនោះពុំប្រសើរឡើយ ។

ស្ដេចស្ដាប់ហើយ ទ្រង់ដណ្ដឹងពោធិសត្វថា ម្ដេចទៅបាមហោសថ ? ពោធិសត្វពោលតបថា បពិត្រព្រះមហាពជអើយ! រីសេនកនេះ

ជាអ្នកកំឡៅនឹងដឹងអ្វី ? គាត់មើលយល់តែលោកិយនេះឯង, គាត់មើលបរលោកពុំយល់ឡើយ ហើយពោធិសត្វសូត្រនូវគាថានេះថា :

បរស្ស វា អត្តនោ វាបិ ហេតុ
ន ភាសតិ អលិកំ ភូរិបញ្ញោ
សោ បូជិតោ ហោតិ សភាយ មជ្ឈេ
បច្ឆាបិ សោ សុគតិគាមី ហោតិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញាវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រមហារាជអើយ ! អ្នកមានប្រាជ្ញាច្រើន មិនដែលស្រដីនូវពាក្យកុហកលេះលោះ ដ្បិតនឹងហេតុបង់បានជាប្រយោជន៍អាត្មា នឹងជាប្រយោជន៍អ្នកដទៃ, អ្នកមានប្រាជ្ញាច្រើននោះ លោកផងសឹងបូជាក្នុងកណ្តាលជំនុំ, លុះបំណោរទៅសោត នឹងបានទៅសោយសុខកិរម្យក្នុងសួគ៌ទេវលោកនាយ, ហេតុនោះ ខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញានោះប្រសើរ, អ្នកកំឡៅអន្ធពាលឥតប្រាជ្ញានោះពុំប្រសើរឡើយ ។

លំដាប់នោះ; អាចារ្យសេនកស្តាប់ពាក្យពោធិសត្វហើយ ទូលព្រះមហាក្សត្រ សូត្រជាបទគាថា ដូច្នេះថា :

ហត្ថី គវស្សា មណិកុណ្ឌលា ច
នារិយោ ច ឥទ្ធេសុ កុលេសុ ជាតា

សព្វាវ តា ឧបកោតា ករន្តិ
ឥន្ទស្ស ទោសស្ស អធិទ្ធិមន្តោ
ឃតម្បិ ធិស្វាន អហំ វទាមិ
បញ្ញា វិហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រព្រះមហារាជអើយ! រីដំរី សេះ គោ ក្របី ផងទាំងឡាយក្តី ស្រីទាំងឡាយមានរូបល្អក្តី មណិរ័តន៍មកុដកុណ្ឌទាំងឡាយក្តី សឹងកើតមានក្នុងត្រកូលទាំងឡាយ ដ៏មានសម្បត្តិច្រើន, រីអ្នកផងទាំងឡាយដ៏ឥតសម្បត្តិ សឹងទៅបំរើអ្នកដ៏មានសម្បត្តិនោះ, ហេតុនោះហើយខ្ញុំថា អ្នកដ៏មានសម្បត្តិប្រសើរ, រីអ្នកមានប្រាជ្ញាឥតសម្បត្តិពុំប្រសើរឡើយ ។

លំដាប់នោះ, ពោធិសត្វស្តាប់ហើយ ទូលព្រះមហាក្សត្រថា រីអាចារ្យសេនកនោះដឹងអ្វីព្រះអង្គ ហើយពោធិសត្វនាំនូវហេតុមួយមក សំដែងសូត្រជាបទគាថាដូច្នេះថា :

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

### វប្បធម៌ខ្មែរ

# អក្សរសាស្ត្រជាសាខាសំខាន់នៃវប្បធម៌

លោក លី · ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

---

ដូចបានរាប់រៀបក្នុងអត្ថបទមុន ៗ រួចមកហើយថា "អក្សរសាស្ត្រជាសាខាសំខាន់ជាងគេក្នុងវប្បធម៌" ព្រោះអក្សរសាស្ត្រជាមេគំនិតបង្កបង្កើតនូវបញ្ហាត្រិះរិះគ្រប់បែបទាំងអស់ ។ ដើម្បីបកស្រាយបញ្ហានេះឲ្យបានច្បាស់លាស់ យើងល្បងធ្វើសេចក្តីវែកញែករកហេតុផលឲ្យល្អិតល្អន់បន្តិចដូចតទៅ ៖

១– អក្សរសាស្ត្រជាមេប្រាជ្ញា.– គ្រប់តែប្រទេស គេតែងទុកជាក់ការសិក្សាពីអក្សរសាស្ត្រជាចំបងគេបំផុត ព្រោះថាបើកាលណាគេជ្រួតជ្រាបសព្វសព្ទានចិត្តទៅក្នុងអក្សរសាស្ត្រហើយ នោះគេនឹងមានស្មារតីប្លែកមួយ គឺស្មារតីពនឺរ ឆ្លៀវឆ្លាស ប៉ិនប្រសប់គ្រប់វិធីដោះស្រាយបញ្ហាអ្វី ៗ សព្វបែបសព្វយ៉ាងគ្មានសល់ចន្លោះ ។ ហេតុដែលនាំឲ្យដូចនេះ ដ្បិតនៅក្នុងស្នាដៃនិមួយ ៗ ដែលប្រឌិតឡើងដោយសារ

អ្នកនិពន្ធណាមួយ អ្នកនិពន្ធនោះរមែងផ្តិតក្តាប់នូវគោលគំនិត, សេចក្តីយល់ឃើញជានិក្ខេបបទរបស់ខ្លួនឲ្យនៅជាប់ក្នុងនោះ សំរាប់ជូនជាបញ្ហាដល់អ្នកអានជួយត្រិះរិះពិចារណារកហេតុផល និងជួយដោះស្រាយបញ្ហានោះតាមវិធីគ្រប់បែបគ្រប់យ៉ាងមានគតិបណ្ឌិតជាដើម ។ អាស្រ័យហេតុនេះ ឃើញថាអ្នកអក្សរសាស្ត្រ ពិតជាមគ្គុទ្ទេសក៍យ៉ាងសំខាន់ ក្នុងការរៀបចំដោះស្រាយសង្គមជាតិនីមួយ ៗ, បានសេចក្តីថា បើអ្នកអក្សរ-សាស្ត្របណ្តុះគំនិតអាក្រក់ មានរឿងស៊ីផឹក, លួចប្លន់ឬកាប់សម្លាប់គ្នាជាដើមអ្នកអានចំនួនច្រើនដែលមាននិស្ស័យនៅទន់ខ្ចី ប្រាកដជានឹងយល់ថាអំពើលាមកទាំងនោះជាការចាំបាច់ដែរ ហើយគេនឹងក្លាត់ស្ទៀតប្រព្រឹត្តតាមនោះខ្លះ ៗ ជាហេតុនាំឲ្យមានការល្អក់ខ្វល់ក្នុងសង្គមជាតិជាពុំខាន ។ ផ្ទុយទៅវិញ បើអ្នកអក្សរសាស្ត្រស្គាល់ឆាទិស្គាល់ការៈខ្លួនច្បាស់ ដឹងប្រាកដថាខ្លួនជាអ្នកដឹកនាំមតិមហាជនឲ្យត្រាច់ទៅកាន់ផ្លូវល្អប្រពៃ ដើម្បីកសាងសង្គមជាតិខ្លួននោះ សេចក្តីចំរើនក៏រមែងតែមានទ្វេឡើង ៗ ជាលំ-ដាប់ ទុតិយមគតិយ៉ាងត្រកាល ។ ក៏រមែងតែដុះពន្លកក្នុងខួរក្បាលនៃពល-រដ្ឋរួមជាតិគ្រប់ ៗ រូបទៅដែរ ។ ដូចនេះ ឃើញថា សូម្បីតែគ្រោះថ្នាក់ផ្សេង ៗ ដែលនឹងកើតមានឡើងក្នុងដំណើរជីវិតអ្នកស្រុកអ្នកភូមិ ក៏អាចប្រែក្លាយទៅជាសេចក្តីសុខវិញបានជាពុំខាន ព្រោះដោយសារតែអ្នកស្រុកអ្នកភូមិគ្រប់គ្នាដុះដាលបញ្ញាស្មារតី រមែងនាំគ្នាទុកដាក់ប្រាជ្ញាជាធំក្នុងការ

ប្រព្រឹត្តទៅនៃជីវិតរបស់រៀង ៗ ខ្លួន ៗ ។ សំខាន់ម្យ៉ាងទៀត ត្រង់ដែលអំពើល្អកើតឡើងអំពីផលនៃការណែនាំរបស់អ្នកអក្សរសាស្ត្រនេះ អាចទុកទៅបានជាមតិកដ៏គាប់ប្រសើរ ដល់កូនចៅជាជំណាន់ទៅមុខឆ្ងាយ ៗ ទៀត ។

២– **អក្សរសាស្ត្រជាមេការសិក្សា** – ចំពោះចំណុចនេះ យើងគេឃើញថា ចំណេះវិជ្ជាអ្វីផងទាំងពួង ដែលនឹងកើតមានឡើងបាន គឺអាស្រ័យដោយអក្សរសាស្ត្រជាអ្នកបើកផ្លូវ ។ បានសេចក្ដីថា មុននឹងអ្នកប្រាជ្ញការរកកសានវិជ្ជាចំឡែកអ្វីមួយបាន អ្នកប្រាជ្ញត្រូវយកវិជ្ជាអក្សរ-សាស្ត្រ ជាស្ពានសំរាប់ឆ្លងទៅកាន់គោលបំណងរបស់ខ្លួនឲ្យបានសម្រេចតាមប្រាថ្នា ។ បើយើងពោលមួយផ្នែកទៀតថា អក្សរសាស្ត្រជាបឋម-វិជ្ជា ឬមេវិជ្ជាដែលត្រូវសិក្សាជាដំបូងគេបំផុតក៏បាន ដ្បិតអ្វី ៗ ផងទាំងពួងសុទ្ធតែចារឹកជាអក្សរធ្វើជាលក្ខណ៍ទុកសំរាប់កេងកកាពក្នុងការសិក្សា ។ តែមានវិជ្ជាបច្ចេកទេសខ្លះដែរ ដែលពុំបាច់ឆ្លងតាមស្ពានអក្សរសាស្ត្រ ព្រោះគេបង្កើតបានដោយការសំកិតិសោធរឿយ ៗ ក្នុងការងារផ្ទាល់របស់គេ ក៏ប៉ុន្តែជាករណីពិសេសហួស ដែលកម្រនឹងចែកចាយឲ្យសាយភាយវិជ្ជានោះឲ្យសុសសាយទៅបានដូចជាគេយកស្ពានអក្សរសាស្ត្រទៅប្រើ ។

៣– **អក្សរសាស្ត្រជាមេនៃសិល្បៈ** – បើយើងពោលថា អក្សរសាស្ត្រជាសិល្បៈវិញក៏បាន ព្រោះវិជ្ជាទាំងនេះ រមែងនៅរួមជាប់ជាមួយគ្នាជានិច្ច ប៉ុន្តែ យើងចាត់ទុកអក្សរសាស្ត្រជាមេ ព្រោះអក្សរសាស្ត្រ

មាននាទីដឹកនាំ  ឬកត់ត្រាដៅសំគាល់ជានិច្ចនូវក្បួនខ្នាត  នូវផ្លូវរឿងរ៉ាវ នូវសម្រស់លំអនៃសិល្បៈនិមួយ ៗ ចាប់តាំងពីការរំព្រៀង  ចម្លាក់រចនាឡើងទៅ ៗ បើកាលណាគេសិក្សាពីសិល្បៈ  ក៏ត្រូវសិក្សាពីអក្សរសាស្ត្រផងដែរ  គេពុំអាចបំបែកឲ្យឃ្លាតចេញពីគ្នាដាច់ស្រឡះបានទេ ៗ ហេតុផលដែលពោលមកត្រួស ៗ  នេះហើយ  ដែលយើងសំគាល់បានថា "អក្សរសាស្ត្រជាមេនៃសិល្បៈ" ៗ

សរុបសេចក្តីទៅ  អក្សរសាស្ត្ររបស់ជាតិណា  ប្រាកដជាសាខាយ៉ាងធំរបស់វប្បធម៌ជាតិនោះ ៗ ឯខ្មែរយើង ដែលជាជាតិច្បងមួយធ្លាប់មានវប្បធម៌ឆើតឆាយដាច់គេក្នុងចំណោមជនជាតិនៅលើជ្រោយសុវណ្ណ-ភូមិតាំងពីបុរាណកាលមកនោះ  យើងនៅគង់ទ្រង់ច្បាស់ក្រឡៅខាងលក្ខគោលអក្សរសាស្ត្រសម្រាប់ទុកជាមេគំនិត  មេបញ្ញា  មេវិជ្ជាទាំងពួងដល់ជនជាតិយើងតាំងពីព្រេងនាយរៀងរាបមកដល់បច្ចុប្បន្ន  ៗ  ហេតុនេះយើងជាកុលបុត្រខ្មែរ  ដែលបានស្គាល់នូវតម្លៃមុខវិជ្ជានេះច្បាស់លាស់ហើយ  គប្បីតែយើងនាំគ្នារក្សាកេរ្តិ៍មរតកនេះឲ្យគង់វង្ស  ព្រមទាំងនាំគ្នាជួយពង្រីក  ឲ្យបានសាយភាយសមតាមឋានៈ  នៃប្រទេសយើងឯករាជ្យប៉ុព្វើងផង  ៗ

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Chef de quart | | នាយវេន |
| Médecin de garde en chirurgie | | គ្រូពេទ្យយាមខាងសល្យសាស្ត្រ |
| Médecin de garde en médecine générale | | គ្រូពេទ្យយាមខាងវេជ្ជវិជ្ជាទូទៅ |
| Bloc opératoire | | សល្យាការ |
| Attelle | *n. f.* | ព្រួលស្នប |
| Joncacées | *n. f.* | ប្រទាលជាតិ |
| Palmier | *n. m.* | តាលជាតិ |
| Nymphéacée | *n. f.* | បទុមជាតិ |
| Liliacée | *n. f.* | បលាណ្ឌជាតិ |
| Iridacée | *n. f.* | កេសរជាតិ |
| Orchidacée | *n. f.* | បិនសីថជាតិ |
| Apétales | *n. cl a* | អទលី |
| Dialypétales | *n. cl o* | វិយុត្តទលី |
| Gamopétales | *n. cl a.* | យុត្តទលី |
| Cupulifères | *n. cl. a.* | ចលកជាតិ |
| Urticacées | n. *f.* | កច្ឆជាតិ |
| Crucifères | *n. m.* | សោត្ថិកជាតិ |
| Moracées | *n. f.* | ឧទុម្ពរជាតិ |
| Ampélidacées | *n. f.* | ជិញ្ជកូល |
| légumineuses | *n. f* | សិម្ពិកូល |
| Rosacées | *n.* f. | គុលាពកូល (គុឡាព) |
| Ombellifère | *n. f.* | ឧច្ឆត្តកូល |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត.ខ្មែរ

*ព្រះមហា ប៉ាង - ខាត់ រៀបរៀង*

(តមក)

---

អតិភទ្រតា ស្ត្រី. ការនៃ . . . ចំរើនក្រៃលែង, ការនៃ . . . ប្រសើរក្រៃលែង ។

អតិភយ នបុំ. ភ័យក្រៃលែង; ភ័យធំ ។

*អតិភយាបក*, គុ. ដែលគួរស្បើមក្រៃលែង ។

អតិភរ បុំ. ភារៈក្រៃលែង, ភារៈធ្ងន់ ។

អតិភា ធាតុ. ភ្លឺក្រៃលែង, ភ្លឺព្រោងព្រាយ ។

អតិភានុ បុំ បុត្រានៃក្ឫស្ណ ។

អតិភារ បុំ. ភារៈក្រៃលែង, ភារៈធំ ។

អតិភារិ បុំ អតិភាព ។

អតិភីរុតា ស្ត្រី. ភាវនៃសេចក្ដីខ្លាចក្រៃពេក ។

អតិភីរុណ គុ. ដែលខ្លាចក្រៃពេក ។

អតិភុក្ត គុ. ដែលបរិភោគក្រៃពេក ។ នបុំ. កិរិយាបរិភោគក្រៃពេក។

អតិភូ ធាតុ កើតក្រៃលែង, កើតប្រសើរ ។

អតិភូ បុំ. ព្រះវិស្ណុ ។

(នៅមានត)

# ដើមកំណើតប្រាសាទអង្គរ

## លោក ល្វីហ្វីណូត៍ រៀបរៀង

ក្រមការ ជុំ-មៅ ប្រែជាភាសាខ្មែរ

លោក ញ៉ែម-ខឹម ពិនិត្យ

និងកែសម្រួលជាថ្មី

## សេចក្ដីបញ្ជាក់

យើងសូមបញ្ជាក់ថា រឿងដើមកំណើតប្រាសាទអង្គរនេះ លោក ល្វីហ្វីណូត៍ សាស្ត្រាចារ្យនៃអនុវិទ្យាល័យ ប្រទេសបារាំង និងជាអតីតចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស បានតែងជាភាសាបារាំង ហើយលោកក្រមការ ជុំ-មៅ បានប្រែមកជាភាសាខ្មែរ និងបានចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយាយើងកាលពីឆ្នាំ ១៩២៨ រួចម្ដងមកហើយ ។ ប៉ុន្តែ, ដោយកាលសម័យនោះ ប្រទេសកម្ពុជាយើង ស្ថិតនៅក្រោមអាណាព្យាបាលបរទេស, ប្រទេសនានាក្នុងសាកលលោក គេឥតស្គាល់ឈ្មោះប្រទេសយើងទេ គេស្គាល់តែឈ្មោះឥណ្ឌូចិន ។ ដូច្នេះប្រាសាទអង្គរយើង ដែលជាអច្ឆរិយវត្ថុមួយ ក្នុងបណ្ដាអច្ឆរិយវត្ថុឯទៀតនៅក្នុងសាកលលោកដែរ ក៏ត្រូវបាត់ឈ្មោះបាត់សំឡេងមកអស់ពេលជាយូរ ។

លុះមកដល់បច្ចុប្បន្នសម័យនេះ ដែលប្រទេសយើងបានទទួលឋានៈជាប្រទេសឯករាជ្យពេញបរិបូណ៌ឡើងវិញ ដោយសារស្នាព្រះហស្ដនៃសម្ដេចព្រះប្រមុខរដ្ឋ, ប្រាសាទអង្គរយើងក៏បានលេចព្រាវឡើងកេរ្ដិ៍ឈ្មោះពេញ

ទាំងសាកលលោក ។ ក្នុងមួយឆ្នាំ ៗ អ្នកទេសចរណ៍ជាច្រើនពាន់នាក់ បានមកទស្សនាប្រាសាទអង្គរយើង, ហើយបានពោលសរសើរពីបុរាណ-វត្ថុនេះ និងអំពីសិល្បករខ្មែរយើងពីសម័យបុរាណជាច្រើនក្រៃលែង ។

អាស្រ័យហេតុនេះ ខ្ញុំយល់ឃើញថា គួរយករឿងដើមកំណើតប្រាសាទអង្គរនេះ មកចុះផ្សាយម្តងទៀត ដើម្បីទុកជាទីពិចារណាដល់លោកអ្នកអានទូទៅ, ព្រោះយើងជាម្ចាស់ស្រុក ត្រូវស្គាល់ស្រុកយើងជាងជនបរទេស ដើម្បីទុកជាឯកសារដ៏សំខាន់សម្រាប់អ្នកប្រាជ្ញខ្មែរយើងខាងបុរាណវត្ថុ, ជាពិសេសសម្រាប់និស្សិតខ្មែរយើង ដែលត្រូវការសិក្សាពីប្រាសាទអង្គរយើងនេះ ។

ញ. ១.

## ដើមកំណើតប្រាសាទអង្គរ

តាមជំនឿដែលគេតែងមានជាប់ដល់មកសព្វថ្ងៃនេះថា អង្គរធំនឹងបាយ័ន គឺព្រះបាទយសោវរ្ម័នទ្រង់ព្រះនាមថា បរមសិវលោក ទ្រង់រាជ្យពីគ្រិស្តសករាជ ៨៧១ ទៅដល់ ៨៣២ បានកសាងក្នុងគ្រិស្តសករាជ ៨៨៩ ទៅ ៩១០ ។

## តើបានអ្វីនឹងបញ្ជាក់ក្នុងរឿងនេះ ?

កាលដើម ឈ្មោះចាស់របស់ទីក្រុងហៅថា យសោធរបុរៈ គឺក្រុងនៃយសោធរៈ ។ ក្នុងដំបន់អង្គរគេឃើញមានប្រាសាទជាច្រើន ដែល

មានឈ្មោះរបៀបតែមួយដូចជាឈ្មោះយសោធរតដាក ប្រែថា "ត្រពាំងនៃយសោធរៈ" ឯត្រពាំងនោះគឺបារាយណ៍ខាងកើត; យសោធរេស្វរ ប្រែថា "ឥសូរនៃយសោធរៈ" គឺភ្នំបាខែង; យសោធរាស្រម គឺអាស្រមនៃយសោធរៈឈ្មោះត្រង់នេះមិនប្រាកដទៅលើអ្វីឡើយ ព្រោះខាងក្រោយអាស្រមនេះមានកន្លែងមួយឈ្មោះយសោធរគិរី ប្រែថា ភ្នំនៃយសោធរៈ គឺជាភ្នំបាយ័ននោះឯង ។ ពាក្យយសោធរៈនេះ ប្រែថា "កាន់នូវជ័យជំនះ" ជាពាក្យបំបែករបស់ស្តេចយសោវរ្ម័នអំពីកប៉ាល់ជ័យមក ឯពាក្យយសោធរបុរៈគឺជាឈ្មោះទីក្រុងរបស់យសោវរ្ម័ននោះឯង ។

ម្យ៉ាងវិញទៀត មានប្រាសាទជាច្រើនផ្សេង ៗ ទៀត ដែលមានឈ្មោះថាយសោធរៈដែរ ហើយដែលព្រះបាទយសោវរ្ម័នបានសាង ក៏គួរតែសន្និដ្ឋានបានថា ពាក្យដែលថាទីក្រុងរបស់យសោវរ្ម័ននោះ គឺជាក្រុងដែលព្រះបាទយសោវរ្ម័នបានសាងវិញ ។

មកដល់ត្រង់នេះ យើងសូមដំណាលពីប្រវត្តិស្តេចអង្គនេះបន្តិចសិន ព្រោះរឿងរ៉ាវរបស់ព្រះអង្គនេះ មិនមែនឥតប្រយោជន៍ឡើយ ។ យើងបានដឹងខ្លះ ៗ ថា ព្រះអង្គជាព្រះរាជបុត្រព្រះបាទឥន្ទ្រវរ្ម័ន ទ្រង់បានកសាងប្រាសាទបាគោនិងបាគង ទ្រង់បានឡើងគ្រងរាជ្យតាំងពីកុមារ ហើយគ្រងរាជសម្បត្តិបាន ២០ ឆ្នាំ គិតតាំងពីគ្រិស្តសករាជ ៨១១ ។ ស្តេចយសោវរ្ម័នអង្គនេះ អាចចាត់ទុកជាពួកស្តេច ដែលមានឥទ្ធិឫទ្ធិ

ខាងផ្លូវចម្បាំងបាន ដ្បិតមានល្បីថា ទ្រង់ប្រសប់ខាងបាញ់ធ្នូដោយព្រះហស្តខាងណាក៏បាន ទ្រង់មានកំឡាំងអាចទប់ទល់នឹងដំរីសារជំសាហាវៗ ហើយអាចសំឡាប់ដំរីនោះតែ ១ ព្រះខ័នដោយព្រះហស្តទ្វេងផង, ទ្រង់អាចតយុទ្ធជាមួយនឹងអ្នកចម្បាប់ ១០ នាក់ ហើយផ្តួលបានទាំងអស់ដោយស្រួល ៗ តេជានុភាពរបស់ស្តេចអង្គនេះ បណ្តាលឲ្យអ្នកសរសើរហ៊ានប្រដូចថា ទ្រង់អាចកាប់ដៃកមូលឈើមួយវែងធំ ហើយរឹងតែ ១ ព្រះខ័នឲ្យដាច់ជា ៣ កំណាត់ ហាក់ដូចជាផ្តួនាដែកនោះមិនឲ្យមកប្រកួតប្រឡងនឹងព្រះបេស្តា មិនតែប៉ុណ្ណោះសោត មានសេចក្តីសរសើរខ្លះទៀតថា ស្តេចអង្គនេះទ្រង់ឆ្លៀវឆ្លាតខាងក្បួន ទ្រង់ជាគ្រូបាំយ៉ាងប៉ិនប្រសប់ ជាអ្នកប្រាជ្ញខាងបរមត្ថ ជាអ្នកនិពន្ធវេយ្យាករណ៍, នឹងសេចក្តីអធិប្បាយអំពីមហាភាស្យរបស់បតញ្ជលី ៗ

---

---

គេបានឃើញចម្ងាយ ២៥ គីឡូម៉ែត្រ ខាងទិសពាយ័ព្យនៃស្រុកស៊ីសុផុន នៅកន្លែងមួយដែលហៅថាស្តុកកក់ធំ, គោលថ្ម ១ ចារឹកជាពាក្យខ្មែរនឹងពាក្យសំស្ក្រឹត ដែលមានសេចក្តីប្លែកពីសិលាចារឹកទាំងឡាយក្នុងស្រុកខ្មែរ ហើយមានសេចក្តីល្អ ៗ ជាច្រើន ៗ គោលនេះបានចាប់ធ្វើក្រោយគ្រឹស្តសករាជ ៩៧៤ បន្តិច គឺក្នុងគ្រឹស្តសករាជ ១០៥២ មាន

ឈ្មោះសុខាសិវ ជាបរោហិតរបស់ស្តេចជាអ្នកសរសេរ បរោហិតនេះបានទទួលមុខងារបន្តពីបរោហិតមុន ហើយដែលបានកាន់កាប់មុខក្រសួងពីតផុតកម្តាយ គឺជាពង្សាវតារនៃពួកបរោហិតក្នុង ២៥០ ឆ្នាំ ពីគ្រិស្តសករាជ ៧២៤ ទៅដល់ ៩៧៤ ត្រូវនឹងគ្រិស្តសករាជ ៨០២ ទៅដល់ ១០៥២ ។ ពង្សាវតារនេះមានកត់ត្រាឈ្មោះបរោហិតធំ ៗ ទាំងអស់ដែលបានគោរពប្រតិបត្តិកិច្ចការរាជការ ព្រមទាំងព្រះនាមស្តេច ដែលបរោហិតមួយ ៗ នៅធ្វើរាជការគាល់បំរើ, ងារការនិងទ្រព្យរបស់ដែលបានទទួល, ភូមិនិងប្រាសាទដែលបានកសាង ។ សេចក្តីទាំងនេះសុទ្ធតែជាការពិតមិនគួរសង្ស័យឡើយ ព្រោះពង្សាវតារនេះមានកស្តុតាងដ៏ច្បាស់ណាស់ នេះហើយដែលយើងមើលឃើញក្នុងសិលាចារឹកខ្មែរ ចែងពីរឿងព្រះបាទយសោវរ្ម័ន ដែលក្រោយមកមានព្រះនាមថា បរមសិវលោក ។

សេចក្តីប្រែខាងក្រោមនេះ គ្រាន់តែជាការជួយណែអ្នកប្រែសិលាចារឹកនោះចេញពីថ្ម ។

មនវ្រះចាន បរមសិវលោក ចតនករស្រី យសោធរបុរ នាំកម្រតេង៍ជគតតរាជអំវី ហរិហរាលយ យកទុកនគរនោះមនវ្រះចាន បរមសិវលោក ស្ថាបនាវ្នំកណ្តាល កម្រតេង៍ សិវប្រម ស្ថាបនា ព្រះលិង្គអញ្

កណ្តាល ។

ប្រែថា ព្រះបាទបរមសិវលោកសាង (បត) ក្រុងយសោធរបុរៈ ហើយនាំនូវស្តេចទេវតា (គម្រតេងជគតតកជ) ចេញពីហរិហរាលយ ទៅដំកល់ទុកក្នុងក្រុងនោះ រួចពីនោះព្រះបាទបរមសិវលោកបានសាងភ្នំកណ្តាល (វ្នំកន្តាល) គឺព្រះតម្លៃងសិវស្រមយកព្រះលិង្គទៅដាក់ជាកណ្តាល ។

ឯភ្នំកណ្តាល ដែលពាក្យសំស្ក្រឹតហៅថាយសោធរគិរី គឺភ្នំយសោ-ធរៈនោះ គ្មានភ្នំឯណាក្រៅពីប្រាសាទបាយ័ននេះឡើយ ។ គេឲ្យឈ្មោះថាភ្នំប្រាសាទយ៉ាងនេះដោយភ្នំនេះសាងនៅកណ្តាលក្រុង ឬកណ្តាលទីក្រុងដើម្បីជាដំណាងភ្នំមេរុ ដែលជាភ្នំនៅកណ្តាលទ្វីប ។ តាមទំនានកុងក្សត្រវិជ្ជាផ្សេង ៗ ក្នុងស្រុកឥណ្ឌាថា គឺប្រាកដជាកន្លែងប្រាសាទបាយ័ននៅសព្វថ្ងៃនេះហើយ ដែលជាកន្លែងខ្សែបន្ទាត់ដឹកក្លូងដើងក្អែកពីជ្រុងទាំង ៤ មកជួបគ្នា ។

បើប្រែតាមអក្សរចារឹកនៅស្តុកកក់ធំ បានសេចក្តីថា ព្រះបាទយសោ-វរ្ម័នបានកសាងអង្គរធំនិងបាយ័ន ។

សួរថាចុះព្រះ ដែលព្រះអយ្យកោអយ្យិកាសទាសិវ ធ្លាប់គោរពប្រតិបត្តិនៅប្រាសាទបាយ័ននោះ តើជាព្រះអ្វី ? ឆ្លើយថាគឺជារូបលិង្គ ។ ត្រង់នេះយើងមិនបាច់ទៅស្រាវជ្រាវរកដើមហេតុឯណា ឲ្យវែងឆ្ងាយទេ ដែលជាការនាំឲ្យស្តុកស្តាញឥតប្រយោជន៍ ព្រោះលិង្គនេះយើញមានតំរូ

ជាច្រើនណាស់ក្នុងស្រុកចម្ប៉ាំនឹងស្រុកខ្មែរ ។ យើងត្រូវគត់ចំណាំដូច្នេះថា កាលពីយូរមកហើយនោះ មានកាន់សាសនាគោរពប្រតិបត្តិលិង្គជាបមក វេលានេះ មិនឃើញមានអ្វីជាទីតាំងនឹងសំអាងទាំងនេះឡើយ ។ ប៉ុន្តែ នៅមានកន្លែងមួយទៀត បើមិននាំឲ្យសង្ស័យក៏ហាក់ដូចជាប្លែកបន្តិច នោះដែរ គឺនៅលើសសរថែវបាយ័ន គេឃើញមានរូបព្រះពុទ្ធហើយមាន ថែមពុកចង្ការស្រួចដូចជាឥសី ។ ការណ៍ត្រង់នេះធ្វើឲ្យគេជឿបានថា ក្នុងវេលានោះ ស្តេចដែលសាងប្រាសាទបាយ័ន បានយកជាងដែលកាន់ ព្រះពុទ្ធសាសនាមកជួយសង់ប្រាសាទផង ហើយជាងទាំងនេះក៏បានរចនា នៅទីបន្ទាប់បន្សំនៃប្រាសាទនោះ ជារូបដែលខ្លួនគោរពបូជា ក៏ដូចជាស្តេច ដែលចូលចិត្តតុបតែងប្រាសាទព្រះអង្គ ជាបែបដែលព្រះអង្គបានគោរព នោះដែរ ។ លុះយូរក្រោយមក ព្រះច័យរបស់ស្តេចយសោវរ្ម័ន ដែល ធ្លាប់ប្រកបដោយអធ្យាស្រ័យ ក៏ផ្លាស់ទៅជាព្រះច័យចង់បំផ្លាញទៅវិញ ដោយព្រះអង្គទ្រង់សព្វព្រះច័យ តែនឹងរូបតំណាងសាសនាដែលព្រះអង្គ ចូលចិត្តហើយទ្រង់មិនចង់ឃើញមានរូបព្រះពុទ្ធជាប់នឹងប្រាសាទ ក៏តាំង ខំធ្វើបំបាត់រូបទាំងនោះចេញ ។ កន្លែងត្រង់នេះហាក់ដូចជាពិតត្រាន់បើ ។

ប៉ុន្តែក្នុងឆ្នាំ ១៩២៣ ក៏កើតមានរឿងមួយថ្មីទៀត ជាការថែមទម្ងន់ ទៅលើសេចក្តីសង្ស័យដែលមានស្រាប់មកនោះ ។ ប៉ុន្តែដើម្បីឲ្យងាយ យល់ដល់រឿងនោះ យើងត្រូវបរិយាយបន្តិចអំពីផែនទីប្រាសាទបាយ័ន ។

ប្រាសាទបាយ័នមានរាង ៤ ជ្រុង ធំក្រោមតូចលើ មាន ៣ ថ្នាក់ ថ្នាក់ ២ នៅខាងក្រោម ហើយថ្នាក់ ១ ដែលខ្ពស់ជាងគេនោះមានកំពូលបន្តទៅទៀត ដែលជាកន្លែងសម្រាប់ធ្វើសន្និបាត ៗ ប៉ុន្តែក៏កណ្តាលនេះ តាំងខាងក្រោមតាំងកំពូល មិនធ្វើឲ្យដូចជាផែនទីដំបូងនោះទេ, តាមផែនទីដើម ថែវនៃថ្នាក់ទី ២ នោះត្រូវសង់ព័ទ្ធជុំវិញគ្នាមួយកន្លែងជាជើងក្អែក ហើយត្រូវជាប់ទៅថ្នាក់ក្រោមនៃប្រាសាទនោះ ឯសន្និបាតកណ្តាលនោះ មានទំហំល្មម ៗ គ្រប់តាំងកំពូលថែវទាំងនោះ មានក្លោងទ្វារឆ្លាក់ក្បាច់ដំផ្ចិតផ្ចង់ នៅកន្លែងកាលទីងមានពន្លឺពេញ ៗ សព្វថ្ងៃនេះ ក្លោងទ្វារទាំងនោះមើលមិនឃើញឡើយ ៗ ចុះដោយហេតុអ្វីបានជាមើលមិនឃើញ គឺថាក្រោយមក ថ្នាក់ខាងលើបានបន្ថែមឲ្យខ្ពស់ ទីងពង្រីកឲ្យទូលាយឡើងទូលាយទៀបទីងប៉ះថែវខាងក្រោមមក គាំងទីងក្លោងទ្វារដែលចូលខាងក្រៅ ៗ ក្លោងទ្វារទាំងនេះបាត់អស់មើលមិនឃើញ ដោយអំណាចប៉ះផ្ចិតជាថ្មីទាំងអស់ ឯប៉ះនោះដូនកាលទុករបស់ពាស់ឲ្យនៅ ដូនកាលកាត់ខ្ទះចេញ តាមដោយរបស់តាំងនោះនៅគាបជាង ឬខ្ពស់ជាងបន្ទាត់ដែលគេប៉ះគ្នានេះ ៗ

កាលកន្លងឆ្នាំ ១៩២៣ គេបានដំឡើងកែវពីប្រាសាទបាយ័នតែប៉ុណ្ណោះលុះដល់លោក ប៉ារមង់ទេ ជាអ្នកពិនិត្យប្រាសាទបាយ័ន បង់មើលក្លោងទ្វារមួយឲ្យច្បាស់នឹងពន្លឺថ្ងៃ ក៏បានឲ្យគេគាស់ប៉ះពកៈដែលប៉ះនៅ

ថ្នាក់ខាងលើដែលបាំងនោះចេញ ហើយក៏បានឃើញទេវតា ១ អង្គឈរលើត្របកឈូក ដៃទាំង ៤ កាន់នូវផ្គាំ, សៀវភៅ, ផ្កាឈូក និងគ្រឿង ១ ទៀតបាក់ដាច់ប្រហែលដូចជាដប ១ នៅកំពូលមកុដខាងមុខមានព្រះពុទ្ធរូប ១ ។ រូបនេះគ្មានអ្វីធ្វើឲ្យមានការសង្ស័យទេ គឺជារូបពោធិសត្វលោកេស្វរៈ ឬអវលោកេតេស្វរៈ ជាអ្នកទ្រទ្រង់នូវមនុស្សជាតិនិងជាអ្នកធ្វើឲ្យជាជម្មី ។

សួរថាតើក្លោងទ្វារនេះ ឬកតែឯងពីក្លោងទ្វារឯទៀតនៅតជុំវិញកំពូលកណ្តាលនោះឬអ្វី ? ឆ្លើយថាមិនមែនដូច្នោះឡើយ ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៤

ឧកញ៉ាវិបុលរាជសេនា ង៉ួន-កាន ប្រែរៀបរៀង

( តមក )

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ឡេវហៀនក៏ទូលពាក្យថា ខ្ញុំបាទនឹងនាំបិតាមកជួបនឹងលោកជាប្រាកដ ខុងបេងក៏បើកលែងឲ្យឡេវហៀនចូលទៅក្នុងស្រុកវិញ ហើយក៏និយាយសេចក្តីឲ្យបិតាស្តាប់គ្រប់ប្រការ រួចថាឯចិត្តឡេវពីនឹងខុងបេងនេះជាមនុស្សល្អសុភាពរៀបរយគួរសមណាស់ ឡេវតៅបានស្តាប់សព្វគ្រប់ក៏យកទង់សលើកឡើងដោតលើសើនបន្ទាយសំគាល់ថា ស្រុកចំណុះ ហើយបើកទ្វារគ្រប់ទិសចំហ រួចក៏រៀបចំយកទ្រព្យរបស់ជាបណ្ណាការ នឹងគ្រឿងសម្រាប់ងារ នាំឡេវហៀនជាបុត្រនឹងបណ្តាពួកអ្នកស្រុកទាំងពួងចេញទៅគំនាប់ឡេវពី ខុងបេងក៏យកគ្រឿងសម្រាប់ងារបង្វិលឲ្យឡេវតៅ ហើយតាំងឡើងឲ្យអ្នកធ្វើជាចៅហ្វាយស្រុកនៅដដែល តែឡេវហៀនជាបុត្រ

នៅក្នុងសេចក្ដីយើងនឹងយកទៅស្រុកកេងដីវជាមួយ នឹងបានជួយធ្វើការតទៅ ខុនបេងក៏នាំឡៅពីនឹងទាហានទាំងពួងចូលទៅស្រុកឡេងឡេង ។

ឡៅពីក៏ប្រាស្រ័យប្រាប់ប្រោមរំលឹក ប្រដៅបណ្ដាពស្រ្តក្នុងស្រុកឲ្យនៅជាសុខតាមប្រក្រតី ហើយថាដែលយើងលើកទ័ពមកនេះក៏បានស្រុកឡេងឡេងហើយ ឯស្រុកហ៊ុយអៀងនោះនរណានឹងអាចយកអាសាចេញទៅវាយឲ្យបាន ជូឡុងក៏ឆ្លើយទទួលសុំអាសា ទៀវហ៊ុយក៏ថា សូមឲ្យលោកប្រើខ្ញុំបាទទៅវិញកុំឲ្យជូឡុងទៅឡើយ ជូឡុងថា ខ្ញុំសុំសរសេរសំបុត្រសញ្ញាទុកជូន នឹងសុំតែទាហាន ៣ ពាន់លើកទៅវាយយកស្រុកហ៊ុយអៀងឲ្យបាន បើមិនបានទេ សុំឲ្យលោកកាត់ក្បាលខ្ញុំបាទវិញចុះ និយាយហើយក៏សរសេរសំបុត្រសញ្ញាជូនទៅឲ្យខុនបេង ខុនបេងក៏ប្រគល់ទាហាន ៣ ពាន់ឲ្យជូឡុង ។

ទៀវហ៊ុយថា ឯសំបុត្រសញ្ញានោះ ខ្ញុំបាទក៏ហ៊ានធ្វើទុកជូនដែរ តែសុំឲ្យលោកប្រើខ្ញុំបាទទៅវិញចុះ បើមិនបានស្រុកហ៊ុយអៀងទេ ខ្ញុំបាទសុំឲ្យលោកសម្លាប់ខ្ញុំបាទចុះ ឡៅពីក៏ស្រែកគំហកឲ្យទៀវហ៊ុយថា កាលជូឡុងព្រមទទួលយកអាសាហើយ បានទាំងសរសេរសំបុត្រទុកជាស្រេច ហេតុម្ដេចក៏មកដែកដណ្ដើមគេដូច្នេះ ទៀវហ៊ុយក៏មិនឆ្លើយតបថាម្ដេច ជូឡុងក៏លាឡៅពី, ខុនបេងលើកទាហាន ៣ ពាន់ចេញទៅច្បាំងយកស្រុកហ៊ុយអៀង ឯបំរើសេះលុះឃើញកងទ័ពលើកមក ក៏នាំ

យកសេចក្ដីទៅប្រាប់ទៀវហាមចៅហ្វាយស្រុកហ៊ុយអៀនថា ឥឡូវជូឡុងទាហានឡៅពីលើកកងទ័ពមកនឹងចាប់យកស្រុកយើង ។

ទៀវហាមបានឮដូច្នោះ ក៏ប្រឹក្សានឹងទាហានទាំងពួងថា យើងនឹងគិតប្រការម្ដេច តាំងអេងនឹងចៅឡុងនាយទាហានឆ្លើយថា ដែលឡៅពីលើកទ័ពមកនេះ ខ្ញុំនឹងសុំយកអាសាលើកទាហានចេញទៅច្បាំងកំរិតទល់មិនឲ្យវាល់ដល់អន្តពាយស្រុកឡើយ ទៀវហាមតបថា អ្នកកុំអាលមើលងាយប្រមាថឡៅពីដូច្នោះ ព្រោះឡៅពីនោះជាពូជព្រះវង្សព្រះចៅហៀនតេ មានតម្រិះប្រាជ្ញាជាសុចរិតពិតត្រង់ល្អណាស់ ទាំងគួនអ៊ូ, ទៀវហ៊ុយ, ជូឡុងក៏មានថ្វីដៃខ្លាំងពូកែជាទាហានឯក, ឥឡូវឡៅពីប្រើជូឡុងឲ្យលើកកងទ័ពមកនឹងវាយយកស្រុកយើង ឯជូឡុងនោះក៏មានកំឡាំងខ្លាំងពូកណាស់ គ្រាប់ឆ្ងូលើកទាហានប្រមាណ ១០០ ម៉ឺនមកដល់ពលខៀនបានទៅ ជូឡុងបានតច្បាំងទំលាយកងទ័ពចូលចេញដោយស្រួលហាក់ស្បីដូចនៅកណ្ដាលពលគ្មានទាហានសោះ ដែលអស់អ្នកនឹងអាចហ៊ានចេញទៅតស៊ូនោះមុខជាមិនបាន ព្រោះទាហានយើងក៏តិចផង យើងត្រូវគិតគ្នាចេញទៅអង្វរលេនត្រូវសុំចុះចូល ទើបនឹងបានសេចក្ដីសុខតទៅ តាំងអេងឆ្លើយថា ខ្ញុំបាទនឹងសុំយកអាសាចេញទៅច្បាំងមើលម្ដងសិន បើតទល់មិនឈ្នះសឹមចេញទៅចំណុះចុះចូលជាក្រោយ ទៀវហាមតបតាមបណ្ដោយថា តាមចិត្តចុះ តាំងអេងក៏ចាត់ចែងទាហានលើកចេញទៅជិតបន្ទាយជូឡុង ។

ឯដូឡុងឃើញដូច្នោះ ក៏ជិះសេះកាន់លំពែងចេញទៅឃោះមុខទាហាន ហើយស្រែកថា ខ្លួនអញជាទាហានឡៅពី ៗ នោះជាពូជព្រះវង្ស ហើយក៏ជាប្អូនឡៅពៀវដែលទើបស្លាប់ គ្រានេះឡៅពីទំនុកបំរុងឡៅគីជាក្មួយ ហើយប្រើអញលើកកងទ័ពមកប្រាបប្រាមស្រុកហ៊ុយអៀងដែលត្រូវឡើងស្រុកកេងជីវ ហេតុម្តេចក៏ឯងចេញមកតស៊ូនឹងអញដែលមានថ្វីដៃនេះ ឯងមិនខ្លាចសេចក្តីស្លាប់ទេឬ ? ត័នអេងឆ្លើយតបថា ឯស្រុកហ៊ុយអៀងនេះត្រូវឡើងដល់ស្រុកកេងជីវក៏មែន តែឥឡូវឡៅពៀវក៏ស្លាប់ទៅហើយ ទៀវហមចៅហ្វាយអញទើបលើកស្រុកនេះទៅប្រគល់ឲ្យចូច ឯងកុំអួតថាមានថ្វីដៃនោះអញមិនកោតខ្លាចនឹងទៅចំណុះចុះចូលឡៅពីនោះទេ ដូឡុងឮដូច្នោះក៏ខឹងណាស់ បរសេះកាន់លំពែងចូលច្បាំងនឹងត័នអេងបាន ៥ ក្ជួន ត័នអេងទ្រាំកំឡាំងនឹងដូឡុងមិនបានក៏ញាក់សេះថយរត់ ដូឡុងក៏បំផាយសេះតាមទៅទាន់ចាប់ខ្លួនត័នអេងបាន ឲ្យទាហានចងទុក ឯទាហានត័នអេងរត់បែកខ្ញែកទៅអស់ ដូឡុងឲ្យស្រាយចំណងចេញ ហើយនិយាយនឹងត័នអេងថា យើងមិនសម្លាប់ជីវិតខ្លួនទេ យើងលែងឲ្យខ្លួនវិលទៅយក សេចក្តីចូលទៅប្រាប់ទៀវហមជាចៅហ្វាយស្រុក ឲ្យប្រញាប់ចេញមកអង្វរលន់តួចំណុះយើងដោយល្អចុះ បើរឹងទទឹងហើយ តែយើងចូល ទៅក្នុងស្រុកបានកាលណា យើងនឹងសម្លាប់ឲ្យអស់ទាំងបុត្រភរិយា ត័នអេងមានសេចក្តីត្រេកអរណាស់ ទទួលពាក្យ

ជូឡុងហើយក៏គំនាប់លាត្រឡប់ទៅវិញ ទើបយកសេចក្ដីនោះទៅអធិ-ប្បាយឲ្យទៀវហាមស្ដាប់ ទៀវហាមថា យើងបានហាមប្រាមហើយ អ្នកក៏មិនព្រមស្ដាប់ពាក្យយើង ចំតែចចេងនាំទាហានចេញទៅតស៊ូនឹងជូឡុង ទាល់តែបានសេចក្ដីដុនដាបអប្បយសដូច្នេះ ហើយទៀវហាមក៏រៀបចាត់វែងរបស់មាសប្រាក់ជាបណ្ណាការ នឹងគ្រាសម្រាប់ការឲ្យទាហានប្រមាណ ១៥ នាក់ នាំចេញទៅគំនាប់ជូឡុង ៗ ក៏ទទួលយករបស់នឹងគ្រាទុកហើយអញ្ជើញទៀវហាមឲ្យឡើងតុបរិភោគអាហារ ៗ

ខណៈកាលកំពុងបរិភោគផឹកស្រានោះ ទៀវហាមក៏និយាយថា លោកនឹងខ្ញុំជាសែជាមួយគ្នា ហើយក៏ជាអ្នកស្រុកជនគេងដូចគ្នា ដែលខ្ញុំបានធ្វើល្មើសខុសធ្ងន់ប៉ុណ្ណោះ សូមកុំប្រកាន់ទោសខ្ញុំឡើយ ខ្ញុំសូមលោកទុកជាបងប្អូននឹងគ្នាតាមសែតទៅ ជូឡុងមានសេចក្ដីត្រេកអរណាស់ ក៏សួរសាកខែឆ្នាំកំណើតនឹងអាយុ ជូឡុងក៏ឃើញថាចាស់ជាងទៀវហាម ៤ ខែ ទៀវហាមក៏ហៅជូឡុងថាបង លុះវេលាព្រឹកឡើង ទៀវហាមក៏នាំជូឡុងនឹងទាហានជូឡុងប្រមាណ ១០ នាក់ចូលទៅក្នុងស្រុក ជូឡុងនិយាយប្រាប់ប្រាមទូន្មានប្រដៅអស់បណ្ដាអ្នកស្រុក ឲ្យនៅជាសុខក្សេមក្សាន្តតាមប្រក្រតី ទៀវហាមក៏អញ្ជើញជូឡុងចូលទៅបរិភោគអាហារខាងល្វែងក្នុង ខណៈកាលកំពុងសេពសុរានោះទៀវហាមក៏ហៅបងថ្លៃស្រីចេញមកគំ-នាប់ជូឡុង ៗ ឃើញស្រីនោះមានរូបពងល្អ ក៏សួរថា នាងនេះឈ្មោះអ្វី?

ត្រូវជាម្ដេចនឹងអ្នក? ទៀវហាមឆ្លើយថា ស្រីនេះឈ្មោះនាងហួនស៊ីជាភរិយា ទៀវហ៊បបងខ្ញុំបាទ ឥឡូវបងខ្ញុំស្លាប់ហើយ ដូច្នេះជាបងថ្លៃអ្នកជាធំដែលនឹងឲ្យមកគំនាប់ខ្ញុំមិនគួរ ហើយដូច្នេះក៏និយាយឲ្យនាងហួនស៊ី វិលចូលទៅក្នុងវិញ នាងហួនស៊ីក៏លាចូលទៅវិញ ទៀវហាមក៏និយាយនឹងដូច្នេះថា ទៀវហ៊បបងខ្ញុំបាទស្លាប់ ៣ ឆ្នាំទៅហើយ ខ្ញុំបាទបាននិយាយប្រាប់នាងហួនស៊ីឲ្យមានប្ដី នាងហួនស៊ីថា បើមានអ្នកណារូបស្អាតល្អ ហើយមានតម្រិះប្រាជ្ញាប្រការ ១, មានថ្វីដៃខ្លាំងពូកែល្បីល្បាញប្រការ ១, ជាសែជាមួយនឹងខ្មោចស្វាមីមុនប្រការ ១, បើបានព្រមទាំង ៣ ប្រការនេះទើបនាងហួនស៊ីព្រមយកធ្វើជាស្វាមី ឥឡូវខ្ញុំបាទឃើញលោកមានលក្ខណៈព្រមទាំង ៣ ប្រការ ដូចសេចក្ដីប្រាថ្នានាងហួនស៊ីប្ដេជ្ញាទុកមកហើយ លោកក៏មិនទាន់មានភរិយា បានជាខ្ញុំបាទឲ្យចេញមកគំនាប់ប្រាថ្នានឹងលើកជូនជាភរិយានៃលោក ដូច្នេះក្ដីដូច្នោះក៏ខឹងណាស់ ក្រោកឡើងស្រែកគំហកហើយថា ខ្លួនអ្នកនឹងខ្ញុំរាប់អានគ្នាថាជាបងប្អូនព្រោះសែជាមួយ ឯនាងហួនស៊ីជាបងថ្លៃនៃអ្នកស្រាប់មកហើយ ក៏ដូចជាបងថ្លៃខ្ញុំដែរ ហេតុម្ដេចអ្នកមកគិតធ្វើដូច្នេះនឹងមិនខុសទម្លាប់ទំនៀមទេឬ? ទៀវហាមបានឮដូច្នោះក៏មានសេចក្ដីអៀនខ្មាសក្នុងចិត្តណាស់ ទើបញាក់មុខឲ្យទាហានដែលបំរើជិតខាងនោះគិតធ្វើអន្តរាយដល់ដូច្នេះ ១ ឃើញដូច្នោះក៏រឹតតែខឹងណាស់ទៅទៀត ស្ទុះទៅទាត់ទៀវហាមដួលសន្លប់ទៅ ហើយ

ជូឡុងក៏ចេញមកឡើងសេះនាំទាហានប្រមាណ១០នាក់ត្រឡប់មកបន្ទាយ
ទៀវហាមប្រឹក្សានឹងតន់អេង, ប៉ៅឡុង ថា ឥឡូវជូឡុងខឹងនឹងខ្ញុំ បើខ្ញុំ
នឹងលើកទាហានទៅតស៊ូជាសង្គ្រាម ជូឡុងក៏មានថ្វីដៃខ្លាំងពូកែណាស់
ឃើញថានឹងតស៊ូគេពុំបានទេ អ្នកទាំង ២ នឹងយល់ឃើញថាប្រការម្តេច?
តន់អេង, ប៉ៅឡុងថា ខ្ញុំបានសុំលើកទាហាន ៥០០ ធ្វើជាចូលទៅនៅ
នឹងជូឡុង របឲ្យលោកលើកទ័ពចេញទៅ បើជូឡុងនឹងលើកទ័ពមកច្បាំង
នឹងលោក ខ្ញុំបាទទាំង ២ នឹងចាប់ជូឡុងសម្លាប់ចេញ ទៀវហាមយល់
ឃើញត្រូវ តន់អេង, ប៉ៅឡុងក៏លើកទាហាន ៥០០ ទៅដល់បន្ទាយ ហើយ
ប្រាប់ទាហានជូឡុងថា យើងទាំង ២ នឹងសុំចូលទៅគំនាប់ជូឡុងទាហាន
ក៏ចូលទៅជំរាបជូឡុង ៗ ក្នុងពោះក៏គិតថា តន់អេង, នឹងប៉ៅឡុង
មកនេះ ប្រាថ្នាប្រុងបញ្ឆោតយើងតែត្រូវយើងឲ្យចូលមកចុះ សឹមយើង
រិះគិតចាប់ខ្លួនសម្លាប់ចេញឲ្យបាន ហើយជូឡុងឲ្យទាហានទៅហៅខ្លួន
តន់អេង, ប៉ៅឡុងចូលមក ឈ្មោះទាំង ២ ក៏ចូលទៅគំនាប់ជូឡុង ហើយ
ថាយើងទាំង ២ ឃើញទៀវហាមធ្វើសេចក្តីមិនគួរសមដល់លោក បើខ្ញុំ
បាទនឹងនៅស្ងៀមក្នុងស្រុកក៏ឃើញថាស្លាប់ជាមួយគ្នា បានជាខ្ញុំនាំគ្នា
ចេញមកគំនាប់លោក ប្រាថ្នានឹងនៅពឹងបុណ្យធ្វើជាបាវលោកតទៅ
ជូឡុងឮហើយធ្វើជាត្រេកអរពេកក្រៃ យកសំពត់ព្រែ១អាវឲ្យតន់អេងនឹង
ប៉ៅឡុងជាបំណាច់ ហើយឲ្យតែងតុលៀងអាហារផឹកស្រា ខណៈនោះ

តន់អេង, ចៅឡុងជាមនុស្សមិនសូវចេះគិត ផឹកស្រាស្រវឹងហួសលើសកំឡាំងដេកលក់ទៅ ជូឡុងក៏ឲ្យទាហានចាប់ចងទាំងពីរនាក់ ហើយឲ្យចាប់ពួកទាហានទាំង ៥០០ ចង ហើយកំហែងសួរថា ដែលនាយឯងទាំងពីរនាក់ចូលមករកអញវេលានេះថាមកដោយជា ឬកាច វៀច ឬត្រង់ ប្រការម្តេច ឲ្យឯងឆ្លើយឲ្យត្រង់ បើកុហកអញ ។ នឹងសម្លាប់ទាំងអស់គ្នា ទាហានទាំងអស់ភ័យខ្លាចក៏ឆ្លើយថាជាកលឧបាយវៀចទេ ។

ជូឡុងឮដូច្នោះ ក៏ឲ្យយកខ្លួនតន់អេង, ចៅឡុងទៅប្រហារជីវិត ហើយឲ្យស្រាយចំណងពួកទាហានទាំងអស់ចេញ ទុកឲ្យនៅធ្វើការជាមួយ ហើយនិយាយថា ដែលតន់អេង, ចៅឡុងមកប៉ងនឹងប្រទូសរ៉ាយយើង ។ ក៏ឲ្យសម្លាប់ចេញហើយ តែអ្នកពល់គ្នាជាអ្នកតូច តាមមកដោយស្តាប់បង្គាប់គេ យើងក៏ទុកជីវិតឲ្យរស់, ត្រូវវិលទៅកាន់បុត្រភរិយាវិញចុះ បើអ្នកពល់គ្នាវៀចនឹងយើង។ ឲ្យសម្លាប់ចេញទាំងអស់ ពេលយប់នេះយើងលើកពួលទៅលុកយកស្រុកហ៊ុយអៀង ត្រូវអ្នកពល់គ្នាចេញទៅជាទ័ពស្រួច ហៅអ្នកចាំទ្វារឲ្យបើកទទួលជាបានឬទេ? ពួកទាហានទាំងនោះក៏ត្រេកអរសាទរនាំគ្នាទទួលតាមពាក្យជូឡុង លុះពេលកណ្តាលយប់ ជូឡុងក៏លើកទាហានចូលទៅជិតជើងកំផែងស្រុកហ៊ុយអេង ឯពួកទាហានទាំង ៥០០ ក៏នាំគ្នាស្រែកហៅអ្នកចាំទ្វារថា តន់អេង, ចៅឡុងចាប់ជូឡុងបានសម្លាប់ទៅហើយ ឲ្យប្រញាប់បើកទ្វារនឹងចូលទៅវិញ ដើម្បីនឹង

យកសេចក្តីទៅជំរាបទៀវហោមឲ្យជ្រាប ។

ឯទាហានលើសេនបន្ទាយ បានឮសំឡេងច្បាស់ ក៏បំភ្លឺភ្លើងមើលមុខឃើញថា ជាពួកទាហានខាងខ្លួនដែលចេញទៅជាមួយនឹងតាន់អេង, ប៉ៅឡុង ក៏មានចិត្តត្រេកអរព្រោះមិនដឹងកលដូឡុង ក៏នាំគ្នាទៅជំរាបទៀវហោម ។ ឮដូច្នោះក៏នាំទាហានចេញទៅទទួលតន់អេង, ប៉ៅឡុង ដូឡុងក្រឡេកឃើញក៏បរសេះចូលទៅចាប់ខ្លួនទៀវហោមបាន ឲ្យទាហានចងបំណងទុកហើយលើកចូលទៅប្រកាសប្រាប់បណ្តាពស្រ្តក្នុងស្រុក កុំឲ្យកិតភ័យថាយើងមិនបានធ្វើអ្វីឲ្យអន្តរាយទេ លុះវេលាព្រឹកឡើង ដូឡុងក៏ឲ្យធ្វើសំបុត្របកប្តឹងទៅដល់ឡៅតី, ខុងបេង ។ ដឹងក្នុងសំបុត្រសព្វគ្រប់ ក៏ត្រេកអរណាស់ ចាត់ចែងទាហានហើយក៏លើកទៅឯស្រុកហ៊ុយអេង ដូឡុងក៏ចេញមកទទួលឡៅតី ខុងបេងចូលទៅក្នុងស្រុក ហើយឲ្យនាំខ្លួនទៀវហោមមកជូនឡៅតី ។

(នៅមានត)

# រឿងមនុស្សចិត្តប្រែប្រួល

## ឃុនបណ្ណាគារក្យ ប៊ូ-ប៉ូ រៀបរៀង

(តមក)

---

អ្នកតាកើត– *អើ!* ឪអរតែឯងមិនយកប្រពន្ធ, ប៉ុន្តែក្រែងដូចពាក្យចាស់លោកថា ស្វាស្លាប់ព្រោះធ្លាក់ពីចុងឈើ ក្រពើស្លាប់ព្រោះលង់ទឹក យ៉ាងនេះដែរ? មួយទៀតកាលអញនៅបួសនៅឡើយ អញបានមើលរឿងមួយក្នុងគម្ពីរនិបាតជាតកបាលី និយាយពីប្រុសស្អប់ស្រី មិនព្រមឲ្យស្រីណាប៉ះពាល់ដល់សាច់សោះ កាលនៅពីក្មេងតូច សូម្បីតែម្ដាយបីពក៏មិនបានដែរ ស្រាប់តែខាងក្រោយប្រែចិត្តស្រឡាញ់ស្រីវិញ ស្រឡាញ់ខ្លាំងណាស់ ទាល់តែវង្វេងស្មារតី បើឯងចង់ស្ដាប់រឿងនេះ អញដំណាលឲ្យស្ដាប់តាមចាំមក ។

ដីប្រែ– បាទ! ខ្ញុំចង់ស្ដាប់ដែរ ឪដំណាលទៅចុះ ។

អ្នកតាកើត– ចាប់និយាយអំពី ៖

## ២– រឿងប្រុសស្អប់ស្រី

កាលកន្លងរំលងទៅជាយូរអង្វែងហើយ មានព្រះមហាក្សត្រាធិរាជមួយអង្គ ព្រះនាមព្រះបាទព្រហ្មទត្តគ្រប់គ្រងនគរពារាណសី ព្រះអង្គគ្មានព្រះរាជបុត្រាបុត្រីមួយអង្គតព្រះរាជវង្សសោះ ទើបទ្រង់ត្រាស់ប្រាប់ព្រះអគ្គមហេសីនឹងស្រីស្នំក្រមការផងទាំងពួង ឲ្យរៀបគ្រឿងសក្ការបូជាពីការបួងសួងទេវតាសុំបុត្រ ។ ព្រះអគ្គមហេសីនឹងស្រីស្នំទាំងអស់ មាន

សេចក្តីកេកយណាស់ ព្រោះសុទ្ធតែចង់បានបុត្រដូចគ្នា ក៏ចាត់ចែងពីការបួងសួងទេវតាសុំបុត្រ ។

គ្រានោះ ព្រះបរមពោធិសត្វច្យុតពីព្រហ្មលោកមកចាប់បដិសន្ធិក្នុងផ្ទៃព្រះអគ្គមហេសី លុះគ្រប់ទសមាសហើយ ប្រសូតមកជាបុរស កាលលាងទឹកដុសសំអាតមន្ទិលរួចស្រេច ស្រីស្នំក្រុមការទទួលយកទៅបំបមថ្នមរក្សា ។ ព្រះរាជកុមារទ្រង់ព្រះកន្សែងយ៉ាងខ្លាំង សូម្បីព្រះវរមាតាយកទៅបំ ក៏រឹតតែស្រែកខ្លាំងឡើងទៀត ស្រីណាបំក៏មិនស្ងៀមសោះ ទាល់តែប្រគល់ឲ្យពួកអាមាត្យប្រុស ៗ បីវិញទើបស្ងៀម ។ ព្រះវរបិតាទ្រង់ជ្រាបច្បាស់ថា កុមារនេះមិនព្រមឲ្យស្រីចាប់ពាល់ដល់សាច់ខ្លួនទេ សូម្បីតែម្តាយខ្លួនក៏បីមិនបានដែរ បានជាចេះតែស្រែកយំលួងមិនស្ងៀមសោះ ទាល់តែឲ្យទៅពួកប្រុស ៗ បីទើបស្ងៀមឈឹង ទ្រង់យល់យ៉ាងនេះហើយ ទើបសន្មតនាមព្រះរាជបុត្រថា អនិត្ថិគន្ធកុមារ បានសេចក្តីថា កុមារមិនចង់ឲ្យធុំក្លិនស្ត្រី ឬថាកុមារស្អប់ស្រី ៗ ចាប់តាំងពីថ្ងៃនោះមក ទ្រង់ប្រគល់ព្រះរាជបុត្រឲ្យពួកបរិវារប្រុស ៗ បីបមថ្នមរក្សា ពួកប្រុស ៗ នោះប្រញាប់យកទឹកដោះពីស្រី ៗ មកបញ្ចុកព្រះរាជកុមារខ្វះ, យកសំពត់គ្របបិទដោះឲ្យជិត ទុកបន្តិចតែចុងដោះបន្តិច ឲ្យព្រះរាជកុមារបៅខ្វះ, ចោះប្រហោងកំនននហើយ ឲ្យស្រីនៅក្នុងកំនននបន្តិចតែចុងដោះតាមប្រហោង ឲ្យព្រះរាជកុមារជញ្ជក់ខ្វះ ។ លុះព្រះរាជ

កុមារកាន់តែចំរើនវ័យធំឡើង ព្រះរាជបិតាឲ្យសង់ដំណាក់មួយនៅទីរាលស្ងាត់ដាច់ពីផ្ទះអ្នកទាំងពួង ហើយទ្រង់ហាមប្រាមមិនឲ្យស្រី ៗ ចូលទៅក្នុងដំណាក់នោះសោះ ឲ្យសុទ្ធតែបរិវារប្រុស ៗ នៅជាមួយនាំក្រសាលទាំងថ្ងៃទាំងយប់ ។

លុះចំណេរចីរកាលយូរមក ព្រះរាជកុមារចំរើនវ័យធំឡើង បានព្រះជន្ម ១៦ ឆ្នាំគ្រប់ការហើយ ព្រះវរបិតាទ្រង់នឹកព្រួយព្រះទ័យថា អញមានបុត្រតែមួយគត់គ្មានបុត្រឯណាទៀតសោះ ឥឡូវបុត្រតែ ១ នេះបានអាយុ ១៦ ឆ្នាំ ល្មមឲ្យសោយរាជ្យជួសខ្លួនអញហើយ ប៉ុន្តែធ្វើម្តេចកូននេះព្រមទទួលសោយរាជ្យ បើគ្រាន់តែឃើញស្រីមិនបានផង បើដូច្នេះ អញនឹងឲ្យពួកស្រីក្រមុំ ៗ ចូលទៅប្រលោមលួងលោមកូនអញល្បងមើលក្រែងប្រែចិត្តចេះស្រឡាញ់ស្រីវិញ លុះទ្រង់ព្រះចិន្តាដូច្នេះហើយ ត្រាស់បង្គាប់រាជអាមាត្យឲ្យស្រាវជ្រាវរើសរកស្រីក្រមុំរូបល្អ ៗ ចូលទៅលួងលោមព្រះរាជកុមារ ។ អាមាត្យទាំងនោះទទួលព្រះរាជឱង្ការហើយ ក៏ស្រាវជ្រាវរកស្រីក្រមុំរូបល្អ ៗ អាយុ ១៥ ឬ ១៦ ឆ្នាំ ប្រាប់ឲ្យឪពុកម្តាយស្អិតស្អាងកូនហើយជូនមកឯដំណាក់ព្រះរាជបុត្រ ។ ឯនាងក្រមុំទាំងនោះសុទ្ធតែល្អ ៗ ទ្រង់ទ្រាយសក្តិសមហាក់ដូចរូបគំនូរដែលជាងគូរ៉េស នាងខ្លះរាងស្តើងខ្ពស់ ចង្កេះរៀវស្តួចមូលក្លំ សមនឹងទ្រគាករីកសាយ ភ្លៅមូលសត្រសូលដូចបណ្តូលចេក ដោះក្បំដូចផ្លែទន្សាមផ្កាប់នឹងទុក មុខមូល

ក្រឡន់ដូចវង់ព្រះចន្ទ្រា ថ្ពាល់ពេញកំពុងសមទឹងប្រមុះ សក់ខ្មៅស្រិល បំពៀមមូលខ្លួនដូចដងធ្នូ បបូរមាត់ក្រហមដូចផិតស្លា ប្រុសណាឃើញស្មើរវង្វេងបាត់ស្មារតី នាងខ្វះពងជាត់ទាបទ្រទាប់ សម្បុរសណ្តែកបាយ មុខជ្រុងថ្ពាល់ពេញប្រមុះស្រួច ម្រាមដៃដូចបន្ទាក្រូច កំភួនជើងតូចរៀវដូចត្រយូងចេក ចង្កេះអែនងស្ដួត ទ្រូងតើង ដោះធំថ្គោល ប្រុសឃើញគួរឲ្យស្រើបស្រាលចិត្ត ៗ នាងខត្តិយនារីទាំងអស់នោះប្រាថ្នាចង់បានព្រះរាជកុមារធ្វើជាស្វាមីគ្រប់ ៗ អង្គ ខំតាក់តែងស្អិតស្អាងកាយយ៉ាងផិតផ្ចង់ ស្លៀកពាក់សំពត់អាវលើបលន់ស្តើង ៗ មើលសាច់ឃើញ បើមើលពីចម្ងាយហាក់ដូចជាលែងខ្លួនទទេ ៗ

គ្រានោះ ពួករាជអាមាត្យនាំនាងកញ្ញាដែលល្អឆើតឆាយជាប់គេ ចូលទៅក្នុងប្រាសាទមុនកញ្ញាឯទៀត អង្គុយចាំព្រះរាជកុមារនៅល្វែងខាងមុខ មួយស្របក់ស្រាប់តែទ្វារបន្ទប់របើកចេញ លេចព្រះរាជកុមារផ្ដោមក អ្នកបំរើប្រុសកំឡោះ ៗ ទាំងអស់នាំគ្នាក្រោកឈរស្រេក ៗ ក្នុងចំណោមប្រុសនោះ មានតែស្រីក្រមុំម្នាក់ក្រោកឈរតាមគេដែរ នាងងើបមើលទៅចំព្រះភក្ត្រព្រះរាជកុមារហើយនាងញញឹមពព្រាយ ៗ ឯព្រះរាជកុមារទតឃើញច្បាស់ជាស្រីហើយ មិនត្រាស់ថាអ្វីសោះ យកព្រះហស្តទាំងពីរខ្ទប់ព្រះភក្ត្រវិលចូលក្នុងបន្ទប់វិញភ្លាម ហើយប្រើបំរើម្នាក់ឲ្យមកនាំនាងកញ្ញានោះចេញទៅខាងក្រៅមួយរំពេច ៗ រាជអាមាត្យយករឿងនេះទៅ

ក្រាបទូលព្រះមហាក្សត្រិយ៍ ព្រះអង្គរឹតតែព្រួយព្រះទ័យខ្លាំង ។

ក្នុងនគរនោះ មានស្រីរបាំម្នាក់នៅក្រមុំអាយុ ១៦ ឆ្នាំ ជាតិជារាស្ត្រធម្មតា រូបឆោមលោមពណ៌ល្អឆើតឆាយ ចេះរាំចេះច្រៀងយ៉ាងស្ទាត់ ទាំងសំឡេងក៏ពីរោះ នាងឮគេដំណាលពីព្រះរាជកុមារថាស្អប់ស្រីណាស់ក៏គិតថា អញនឹងផ្ចាញ់ផ្ចាលព្រះរាជកុមារយកធ្វើជាស្វាមីឲ្យបាន ទើបនាងចូលទៅរកពួកអាមាត្យ ឲ្យនាំនាងចូលទៅគាល់ព្រះមហាក្សត្រិយ៍ ក្រាបទូលថា សូមព្រះអង្គកុំព្រួយព្រះទ័យ ខ្ញុំម្ចាស់ធានាធ្វើឲ្យព្រះរាជកុមារស្រឡាញ់ស្រីបាន សូមព្រះអង្គអនុញ្ញាតឲ្យខ្ញុំម្ចាស់ចូលទៅធ្វើចុះ ។

នាងឯងគិតធ្វើដូចម្តេច បើស្រីក្រមុំមុន ៗ រូបល្អជាងនាងឯងទៅទៀត ម៉េចក៏នៅតែរាជកុមារមិនស្រឡាញ់សោះ ឲ្យគេបណ្តេញចេញអស់ ។

ក្រាបទូល ! មកពីនាងមុន ៗ នោះ មិនយល់ចិត្តប្រុស មិនចេះធ្វើកិច្ចកលមាយាឲ្យប្រុសស្រើបស្រាល ឲ្យស្គាល់នូវជារសសេវនកិច្ច(១) បើស្គាល់ហើយមុខជាជាប់ជក់ព្រះទ័យស្រឡាញ់ស្រីលែងស្អប់សោះ ។

បើដូច្នោះ នាងឯងទៅធ្វើតាមដំរិះប្រាជ្ញាចុះ បើរាជបុត្រព្រមស្រឡាញ់នាងឯង យើងនឹងតាំងនាងឲ្យធ្វើជាអគ្គមហេសីអភិសេករាជបុត្រឲ្យសោយរាជសម្បត្តិស្នងខ្លួនយើង ។

នាងនាដឮដូច្នោះត្រេកអរណាស់ ថ្វាយបង្គំលាថយចេញមកក្រៅ

---

១-ន ម អានថា សេ-វៈ-នៈ-កិច្ច ការរួមដំណេកគ្នា ។

គិតថា អញមុខជាបានធ្វើអគ្គមហេសីព្រះរាជកុមារមិនខាន ទើបនាងចូលទៅនិយាយផ្ដែផ្ដាំប្រុសកំឡោះ ៗ អ្នកបំរើព្រះរាជកុមារថា យប់នេះដល់វេលាជិតភ្លឺ ខ្ញុំនឹងមកច្រៀងនៅរបៀងក្រៅប្រាសាទក្បែរក្រឡាបន្ទំព្រះរាជបុត្រ បើព្រះរាជបុត្រឮខ្ញុំច្រៀងហើយខ្ញាល់ប្រើគេឲ្យបណ្ដេញខ្ញុំ ៗ ក៏រត់គេចចេញទៅ បើព្រះអង្គសព្វព្រះទ័យទ្រង់ព្រះសណ្ដាប់ចម្រៀងខ្ញុំ សូមអ្នកពល់គ្នាប្រាប់ខ្ញុំឲ្យដឹងសេចក្ដីផង ផ្ដាំរួចហើយលាគេទៅផ្ទះខ្លួនវិញ ។ នាងនាដជាស្រីក្រមុំអ្នករបាំមែន ប៉ុន្តែជាស្រីល្អបរិសុទ្ធណាស់ មិនដែលមានប្រុសណាប៉ះពាល់ដល់ខ្លួននាងទេ បានជានាងហ៊ានទទួលយកអាសាចូលទៅប្រលោមលួងលោមព្រះរាជកុមារនោះ ព្រោះនាងចេះស្ទាត់ខាងកិច្ចកលមាយាស្រីអាចធ្វើចិត្តប្រុសឲ្យស្រើបស្រាល ដោយសារសំឡេងឬក្បាច់ភ្លេងរបស់នាង ។ ពេលយប់នោះ ជិតភ្លឺព្រឹកព្រាងស្វាងព្រះសុរិយា នាងនាដចូលទៅអង្គុយនៅរបៀងក្រៅប្រាសាទក្បែរក្រឡាបន្ទំព្រះរាជកុមារ ចាប់ដេញពិណតាំងស្រែកច្រៀងជាបទបំពេថា -

ស្រណោះយប់ស្ងាត់ មនុស្សសត្វដេកស្ងួត បងអង្វែល
អូន ដោយចិត្តស្នេហា ។ ខ្ញើយមួយពីរនាក់ ពន្លាក់កាយា
បង្កើតអស្ចារ្យ ភ្លៀងផ្គររងំ ។ នាគរាជលេងទឹក បោកបាបជ្រុំ
ព្យុះស្ទើររលំ រលើងគ្រឹះស្ពាន ។ កុំថាតែមនុស្ស ទោះសត្វ
តិរច្ឆាន គង់តែបង់បាន រួមរសនឹងញី ។

ព្រះរាជកុមារឮចម្រៀងនាងនាដលន្ទន់លន្ទោច សំឡេងស្រួយស្រេះស្របនឹងសំឡេងពិណ ក៏កើតព្រះទ័យព្រឺព្រួចស្រងេះស្រងោច នឹកធ្ងល់ថាប្រុសស្រីស្រឡាញ់គ្នាធ្វើអ្វី ក៏ខំផ្ទៀងស្ដាប់ទាល់តែភ្លឺច្បាស់ នាងនាដឈប់ច្រៀងទៅផ្ទះវិញ ៗ លុះព្រឹកឡើងព្រះរាជកុមារសាកសួរជ្រាបរឿងនោះហើយត្រាស់ផ្ដាំអ្នកបំរើថាយប់នេះឲ្យនាងនោះមកច្រៀងក្នុងប្រាសាទទៀត ៗ អ្នកបំរើទៅប្រាប់នាងនាដ ៗ ត្រេកអរណាស់នឹកថា បានការហើយអញ ៗ ឯព្រះមហាក្សត្រិយ៍បានជ្រាបដំណឹងនេះ ក៏រីករាយព្រះទ័យយ៉ាងខ្លាំង ៗ លុះដល់ពេលយប់ពាក់កណ្ដាលអធ្រាត្រ ព្រះរាជកុមារឈប់ក្រសាលចូលផ្ទំហើយ នាងនាដចូលទៅក្នុងប្រាសាទ អង្គុយនៅល្វែងក្រៅខាងមុខ តាំងដេញពិណស្រែកច្រៀងជាបទបន្ទោលកាកថា ៖

ខ្ញុំជាស្រី ស្វែងរកស្វាមីរួមប្រាណ ឲ្យកើតសុខសាន្ត
ទើបបានហៅពេញជាស្រី ។ ឯប្រុសទាំងឡាយ ត្រូវតែខ្វល់
ខ្វាយមេត្រី រួមរសបេតី ជាមួយនឹងស្រីទើបសុខ ។ កើតកាល
ភិលគម្ព ត្រជាក់ត្រជំស្រណោក គ្មានអ្វីឲ្យស្ដុក - ស្ដម្ភលើសរូប
ស្រីទៀតទេ ។ សប្បាយភ្លេចស្លាប់ ហ៊ានដល់សម្លាប់ប្ដីគេ
ជាប់ចិត្តស្និតទេ បេះតែរីកធំរាល់ថ្ងៃ ។ ចិត្តប្រុសគ្រប់គ្នា គិត
គិតជ្ញាក្បីណាក្បួយ គិតតែអាល័យ រលឹកដល់ស្រីសម្លាញ់ ។

ស្អិតដួបតាំងម៉ែ ចាប់ចិត្តស្និទ្ធស្នេហ៍ត្របាញ់ នឹកដល់រសឆ្ងាញ់
រឹតតែស្រឡាញ់ខ្លាំងណាស់ ៗ រឹតក្នុងលោក មានច្រើនគ
គោកឥតខ្ចះ ប៉ុន្តែមិនច្បាស់ ដូចរូបស្រីផងទាំងពួង ៗ

ព្រះរាជកុមារទ្រង់ព្រះសណ្តាប់ចម្រៀងដល់ត្រឹមនេះត្រិះរិះថា ខ្លួនអញសព្វថ្ងៃនេះសប្បាយលើសប្រុស ៗ ទាំងអស់ ព្រោះក្នុងប្រាសាទអញល្បែងរបាំគ្រឿងប្រគំតូរ្យតន្ត្រីគ្រប់មុខឥតខ្វះកន្ទះអ្វីទេ គ្រាន់តែគ្មានស្រីចូលលាយឡំមានតែប្រុស ៗ ប៉ុណ្ណោះ ទាំងម្ហូបចំណីក៏សុទ្ធតែជារបស់ឆ្ងាញ់ណាស់ ឥឡូវនាងនេះមកច្រៀងថា ប្រុសស្រឡាញ់ស្រីសប្បាយខ្លាំងណាស់ទាល់តែភ្លេចស្លាប់ តើសប្បាយយ៉ាងណាទៅទៀតអេះ អញចង់ដឹងណាស់ ទ្រង់ព្រះចិន្តាយ៉ាងនេះហើយ យាងមកឈរក្បែរទ្វារបន្ទប់ទតមើលរូបនាងនាដដែលកំពុងតែដេញពិណច្រៀងខាងក្រៅ ប៉ុន្តែគ្មានព្រះទ័យចាប់ប្រតិព័ទ្ធស្នេហាស្រឡាញ់នាងបន្តិចសោះ គ្រាន់តែនឹកថា នាងនេះរូបល្អណាស់ ហើយយាងចូលទៅក្នុងវិញ ហៅអ្នកបម្រើមកប្រាប់ឲ្យនាងឈប់ច្រៀងវិលទៅផ្ទះវិញចុះ ព្រោះដល់ពេលដេកហើយ ចាំយប់ស្អែកសឹមឲ្យមកច្រៀងទៀត ចាប់តាំងពីព្រលប់ ហើយឲ្យនាងអង្គុយច្រៀងក្បែរទ្វារបន្ទប់ខ្ញុំនេះ ៗ នាងឮអ្នកបម្រើប្រាប់ដូច្នោះអរព្រួចព្រឺខ្លួននឹកថាយប់ស្អែកមុខជាបានសម្រេចដូចបំណងអញមិនខាន ៗ ដំណឹងនេះជ្រាបដល់ព្រះមហាក្សត្រិយ៍ ទ្រង់សោមនស្សយ៉ាងក្រៃលែង ៗ

លុះដល់រាត្រីជាគំរប់បី នាងនាដតែងខ្លួនជាស្រីល្មានស្លៀកពាក់ព្រៃស្បៃយ៉ាងស្តើងរលោងរលើប មើលសាច់ឃើញច្បាស់ លាបម្សៅរមៀតឡើងស្រស់បំព្រង ពាក់មាសពេជ្រត្បូងប្រាលរន្ទាល ប្រុស ៗ ឃើញសំឡឹងមើលទាល់តែភ្លេចខ្លួនដើរចំពប់ជើងស្ទើរដួលស្លាប់ ៗ នាងនាដចូលទៅអង្គុយលើកម្រាលដែលគេក្រាលទុកឲ្យ ក្បែរទ្វារបន្ទប់ព្រះរាជកុមារតាំងពីពេលព្រលប់ធំ មានស្រីក្រមុំល្អ ៗ ពីរនាក់ទៀតជូននាងទៅផង លុះដល់អង្គុយស៊ប់ហើយ ចាប់តែខ្សែពិណឲ្យស្រួលបួលតាំងស្រែកច្រៀងរាយទំនុកជាបទពាក្យរសាត់ថា ៖

( បទពាក្យ ៧ )

ស្រណោះដើមឆ្នាំភ្លៀងផ្កាកម្លង ឈើស្មៅវល្លិផងលាស់ស្រស់ខ្ចី ស្លឹកខៀវស្រងាត់គួរបេតី ផែនដីត្រជាក់ដោយធារា ៗ ហ្វូងសត្វបក្សាផងទាំងឡាយ ហើរលេងសប្បាយលើវេហាស៍ យាសយំផ្ដើយផ្លងរកគ្នា នៅតាព្រៃក្បាសប្បាយណាស់ ៗ ឯមនុស្សប្រុសស្រីក្នុងភូមិឋាន លេងសើចកំសាន្តទាំងក្មេងចាស់ មានប្ដីប្រពន្ធឥតដែលខ្វះ ព្រោះសប្បាយណាស់គ្មានអ្វីប្រៀប ៗ

ព្រះរាជកុមារទ្រង់ព្រះសណ្ដាប់ដល់ត្រឹមនេះ ទំព្រាំសម្ងំស្ដាប់តទៅ

ទៀតមិនបាន ព្រោះត្រូវត្រង់រឿងដែលធ្លាប់រួចមកហើយថា ប្រុសស្រឡាញ់ស្រីនោះតើសប្បាយយ៉ាងណាទៅអេះ ទើបយាងចេញមកអើតនៅមាត់ទ្វារស្រែកហៅថា : នែនាងដែលច្រៀង ! នាងចូលមកឯនេះសិន ៗ នាងនាងត្រូវព្រាស់ត្រេកអរណាស់ ហាក់ដូចជាបានមាសប៉ុនដូនទុំដាក់ពិណាចេញពីដៃភ្លាម ក្រោកឡើងបណ្ដើរចាក់ក្បាច់បណ្ដើរ រាំពេនលំនាំកន្ទេរបេះផ្កា ហើយស្រែកច្រៀងសម្ដែងគ្រលួចថា ៖

( បទពាក្យ ៧ )

ព្រះអង្គហៅខ្ញុំមានហេតុអ្វី ខ្លួនខ្ញុំជាស្រីមិនមែនប្រុស បើទ្រង់ពង់ជ្រាបការត្រូវខុស ខ្ញុំម្ចាស់មិនតុះទាល់គំនិត ៗ ក្រាបទូលឲ្យជ្រាបសព្វកលកិច្ច អំពីល្បងល្បិចនៃស្រីពិត ហេតុអ្វីទើបប្រុសចង់ជួបជិត ទោះក្ស័យជីវិតលែងគិតស្ដាយ ៗ រឿងនេះទូលបានតែពេលស្ងាត់ ទីកំបាំងបាត់ភ្នែកទាំងឡាយ គេមើលមិនឃើញទោះជិតឆ្ងាយ ទើបថ្វាយសេចក្ដីឲ្យជ្រាបបាន ៗ

ព្រះរាជកុមារឈរទតនាងនាងរាំកាំងស្មារតី លែងដាក់ព្រះនេត្រដោយដក់ព្រះទ័យនឹងក្បាច់របាំចម្លែកផង ដោយសារត្រូវសម្ដែងនាងស្រួយស្រិបដែលមិនធ្លាប់ត្រូវផង ប៉ុន្តែគ្មានព្រះទ័យនឹកស្រឡាញ់នាងនាងបន្តិចសោះ ៗ នាងនាងរាំបណ្ដើរច្រៀងបណ្ដើរចូលសន្សឹម ៗ ទៅឧបព្រះរាជ-

កុមារ ។ គេចផុតមិនឲ្យនាងចាប់បានទ្រង់ចេះតែថយក្រោយរហូតទាល់តែដល់ទៅខាងក្នុងបន្ទប់ស៊ប់ ។ នាងនាដឃើញបានឱកាសស្រួលហើយក៏ចាប់ឱបព្រះរាជកុមារកៀកយកទៅដាក់ឲ្យផ្ទំលើគ្រែ ហើយនាងអង្គុយជាមួយប្រដាប់ព្រះបាទ ។ ឯព្រះរាជកុមារចេះតែលើកព្រះបាទចេញមិនព្រមឲ្យនាងនាដចាប់ពាល់ប្រដាប់ព្រះបាទបានសោះ ត្រាស់សួរនាងនាដថា ចុះប្រុសស្រឡាញ់ស្រីនោះតើវាសប្បាយយ៉ាងណាទៅ? ចូរនាងប្រាប់ខ្ញុំផង ដ្បិតខ្ញុំមិនដែលដឹងសោះ ចេះតែនឹកឆ្ងល់ខ្លាំងណាស់ តាំងពីស្តាប់ចម្រៀងនាងមក ។

នាងនាដទូលថា បើព្រះអង្គចង់ជ្រាបរឿងនេះ លុះតែទ្រង់ផ្ទំឲ្យស្ងៀមកុំបម្រះ បណ្តោយឲ្យខ្ញុំម្ចាស់ធ្វើតាមអំពើចិត្ត ទើបខ្ញុំម្ចាស់ទូលពីរឿងប្រុសស្រឡាញ់ស្រីឲ្យទ្រង់ជ្រាបសព្វគ្រប់បាន ។

ព្រះរាជកុមារគ្មានព្រះទ័យប្រតិព័ទ្ធស្នេហា នឹងនាងនាដបន្តិចបន្តួចសោះទេ ប៉ុន្តែដោយហេតុចង់ជ្រាបពីរឿងប្រុសស្រឡាញ់ស្រីណាស់ បានជាខំអត់ទ្រាំសម្ងំផ្ទំស្ងៀម បណ្តោយឲ្យនាងនាដធ្វើតាមចិត្ត ទ្រង់ចេះតែខំចាំសង្កេតចំណាំ ។ នាងនាដដឹងថាបានកណ្តាប់ដៃខ្លួនស៊ប់ហើយក្នុងបន្ទប់ស្ងាត់ជិតឈឹងតែពីរនាក់ គ្មានគិតក្រែងរអែងអ្នកណាសោះ ក៏តាំងបញ្ចេញកលមាយាស្រីជាច្រើនប្រការ ។

(នៅមានត)

# រឿងព្រេងប្រទេសស៊ីរី

# រឿងដែលប្រព្រឹត្តទៅមិនបាន

ភិក្ខុ ម៉ែង-វៀម

និស្សិតពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែចាកភាសាអង់គ្លេស

---

ដំណឹងរំដើបរំជួលបានលេចឮរន្ធឺ ចូលមកក្នុងព្រះកាណ៌នៃព្រះបាទកាលិប (១) ថា នៅក្នុងទីក្រុងមានអ្នកនិយាយរឿងម្នាក់ ជាអ្នកប៉ុនប៉ាវជាទីបំផុត អាចនិយាយរឿងមិនចេះចប់ ហើយមិនចេះញញើតញញើមផង ៗ ដំណឹងរំដើបរំជួលនេះបានឲ្យដឹងទៀតថា បុរសនេះអាចនិយាយរឿងផ្សេងព្រេង តាំងពីពេលព្រះអាទិត្យលិច រហូតដល់ព្រហាមស្រាង ៗ រួចតាប់និយាយដោយឥតឈប់ឈរ តាំងពីព្រះអាទិត្យរះរហូតដល់យប់ទៀត ហើយមិនចេះនិយាយរឿងដដែល ១ ពីរដងឡើយ ៗ

ព្រះបាទកាលិប បានបញ្ជាក្រុមតុលាការរបស់ព្រះអង្គ ទៅស៊ើបរកបុរសនោះ, ហើយកាលដែលគេនាំបុរសអ្នកនិយាយរឿងនោះ មកឈរចំពោះព្រះភក្ត្រព្រះអង្គ ទ្រង់ក៏ពោល ថា : " វាមានការរំដើបរំ-ជួលថា អ្នកឯងជាអ្នកចេះនិយាយរឿងយ៉ាងឆ្នើមបំផុតនៅលើដែនដីនេះ,

---

(១) ព្រះបាទកាលិបនេះ ជាមហាកដនៃក្រុង បាក់ដាដ ( bagbab ) ពីជំនាន់បុរាណ, ព្រះអង្គរាយទុកព្រះមស្សុវែងស្រអូម. ជាទីស្នេហានៃប្រជារាស្ត្ររបស់ព្រះអង្គ (ល) ។

មើបក៏ខ្ញុំមិនដែលឮពីអ្នក?" ។ បុរសទូលថា: "ខ្ញុំព្រះអង្គ គ្មានសិទ្ធិតាមតារចំពោះភាពដ៏ធ្ងើមបំផុតនោះទេ, ទូលព្រះបង្គំ គ្រាន់តែនិយាយរឿងពីរោះ ៗ នៅតៀមកាហ្វេ ដើម្បីពក់ទាក់រកសំឡាញ់ទូលព្រះបង្គំប៉ុណ្ណោះ" ។ ទ្រង់ពោលថា: "មក, ចូរមក! ចូរយើងកុំនិយាយពីសេចក្ដីសុភាពរាបសាប្រាសចាកកិត្តិយស, គេនិយាយពីអ្នកថា អ្នកឯងអាចនិយាយរឿងគ្រប់បែបបាន ហើយអាចបន្ទាយរឿងទាំងនោះដរាបតាលតែអ្នកស្ដាប់ស្រែកឲ្យបញ្ចប់; ឥឡូវកាលណាអ្នកឯងបរិភោគភោជនរួច, ខ្ញុំនឹងចាំស្ដាប់រឿងប្រឌិតមួយរបស់អ្នកឯង" ។

ក្រមតុលាការ បានដុបលៀងអ្នកនិយាយរឿង រួចគេនាំគាត់មកអង្គុយពីមុខ ព្រះបាទកាលិបម្ដងទៀត ។

ទ្រង់ពោលថា: "អ្នកឯង អាចនិយាយរឿងណាមួយ បានតាមចិត្ត ឲ្យតែរឿងនោះចប់នៅពេលព្រលឹមស្រាង ៗ; ហើយខ្ញុំជឿជាក់ថាអ្នកឯងអាចនិយាយរឿងដែលមានផ្លូវសេចក្ដីពិត ៗ បាន បើប្រសិនណាជាខ្ញុំត្រូវការចំពោះរឿងបែបនេះ, តែរឿងដូច្នេះ មិនមែនជាការពិសោធន៍ជាក់ស្ដែងទេ ព្រោះអ្នកនិយាយរឿងដទៃ ៗ ទៀត ក៏អាចនិយាយបាន; រឿងដែលខ្ញុំត្រូវការឲ្យអ្នកនិយាយគឺរឿងខ្ញុំ ប៉ុន្តែគួរសេចក្ដីផ្ទៃរឿងត្រូវតែជាពាក្យកុហកទាំងស្រុង; បើប្រសិនណាជាខ្ញុំកត់សំគាល់នូវពាក្យសូម្បីមួយម៉ាត់ក្នុងរឿងអ្នកឯងនោះ ថាជាពាក្យពិតបាន ខ្ញុំនឹងយកអ្នក

ឯងធ្វើជាទាសៈរបស់ខ្ញុំ, ឥឡូវ ចូរនិយាយចុះ!" ។

កាលដែលអ្នកនិយាយរឿង បានឮព្រះរាជបញ្ញាដូច្នោះ គាត់ក៏រុញ្ញាក, ពីព្រោះថា ការនិយាយអស់ពេលវេលាដ៏វែង ដោយចៀសវាងកុំពោលពាក្យពិតឲ្យសោះដូច្នេះ ជាការមួយលំបាកណាស់, ប៉ុន្តែគាត់កាត់សាញ រួចចាប់និយាយរឿងដូចតទៅនេះ ៖

បពិត្រព្រះអង្គដ៏ទ្រទ្រង់នូវឥស្សរភាព! ខ្ញុំព្រះអង្គនេះត្រូវជាបងប្អូននៃឪពុកខ្ញុំ ។ កាលឪពុកខ្ញុំកើត ខ្ញុំមានអាយុ ៨ ឆ្នាំហើយ ។ ជីតារបស់ខ្ញុំបានយកឪពុកខ្ញុំនោះមកដាក់ក្នុងដៃខ្ញុំ ហើយបង្គាប់ខ្ញុំឲ្យមើលថែរក្សាល្អងគាត់កុំឲ្យយំ ។ ប៉ុន្តែគ្មានអ្វី ដែលអាចធ្វើឲ្យឪពុកខ្ញុំគាត់សប្បាយចិត្តសោះ, ម្ល៉ោះហើយគាត់ប្រាប់ខ្ញុំឲ្យពគាត់ទៅហាងផ្សារនៅក្នុងទីផ្សារ គាត់ដូចជាសប្បាយចិត្តដោយហេតុគាត់បានពិភាក្សា ជាមួយនឹងអ្នកដទៃទៀត នូវបំណាចដ៏ល្អ ៗ ខ្លះនៃគម្ពីរគូរ៉ាន(១) ។ មុនដែលយើងនឹងចាកចេញពីហាងផ្សារ, គាត់ទទូចឲ្យខ្ញុំទិញពងមាន់ឆៅមួយ ប៉ុន្តែ មិនយូរឆ្ងាយប៉ុន្មានពីពេលដែលទិញ ពងនោះក៏ស្រាប់តែញាស់ឡើង ។ ដោយហេតុតែកូនមាន់នោះធំសម្បើមពេក ហើយត្រូវនឹងយើងទាំងពីរនាក់កំពុងតែអស់កំឡាំងផងនោះ យើងបានជិះកូនមាន់បរត្រឡប់មកផ្ទះវិញ ។ នៅពេលមកដល់ផ្ទះ កូនមាន់កែទំហំធំ ប៉ុនអូដ្ឋ ។ ម្ល៉ោះហើយ ខ្ញុំ

(១) គូរ៉ាន ជាឈ្មោះគម្ពីរដ៏ស័ក្តិសិទ្ធិមួយ របស់មោហាម៉េដ ។

ត្រូវតែលើកឪពុកខ្ញុំដាក់ឲ្យទៅជីតាខ្ញុំ ដែលត្រូវជាឪពុកខ្ញុំដែរ ពីព្រោះឪពុកខ្ញុំត្រូវជាប្អូនបង្កើតរបស់ខ្ញុំ ! ។

មកដល់ត្រឹមនេះ ព្រះបាទកាលិបបានលាន់ព្រះឱស្ឋ នឹងការកុហកដ៏អស្ចារ្យនៃអ្នកនិយាយរឿង ។

គាត់ចាប់និយាយតទៅទៀតថា :

កូនមាន់នោះ ស៊ីច្រើនសម្បើមណាស់ដែលក្នុងយូរមកអាចធ្វើឲ្យយើងឋិតនៅក្បែរគែមនៃទុរភិក្សភាព ហើយយើងក៏បានសំរេចចិត្តប្រើវាឲ្យធ្វើការ ។ តាំងតែពីកូនមាន់បានមកជាកម្មសិទ្ធិនៃឪពុកខ្ញុំ គាត់តែងបរាបចេញទៅក្រៅរាល់ព្រឹក ហើយផ្ទុកឱសលើខ្នងៈ ត្រឡប់មកវិញ, ធ្វើយ៉ាងនេះដរាបដល់យើងមានគំនរឱសយ៉ាងខ្ពស់នៅលើទីធ្លាផ្ទះ ។ ប៉ុន្តែការកកិតឱសនៅលើខ្នងមាន់ ធ្វើឲ្យរបួសដាច់ស្បែក, ដូច្នេះកូនមាន់ក៏ឈឺចាប់ ។ ជីតាខ្ញុំទៅជារវល់រវក់ ហើយគាត់ពិចារណានឹងយាយទួតខ្ញុំថា តើត្រូវធ្វើដូចម្ដេច ? ។ យាយទួតខ្ញុំប្រាប់គាត់ឲ្យយកគ្រាប់ស្វាមកធ្វើថ្នាំបំពោក រួចយកទៅបិទលើខ្នងកូនមាន់ត្រង់កន្លែងរបួសនោះ ។ ជីតាខ្ញុំក៏បានធ្វើតាម ។ ព្រឹកឡើង ពេលដែលយើងភ្ញាក់កូនមាន់ក៏បានជាសះស្បើយឡើងវិញ, ប៉ុន្តែស្រាប់តែមានដើមស្វាដុះចេញពីខ្នងកូនមាន់មក ។ ចំនួនជា ៣ ថ្ងៃប៉ុណ្ណោះកូនស្វា ក្លាយទៅជាមេដើមស្វាមួយយ៉ាងធំអស្ចារ្យ ដែលចេះតែជាប់តាមកូនមាន់ ទៅគ្រប់ទីកន្លែងដែលកូន

មាន់ដើរទៅ ៗ មួយអាទិត្យក្រោយមក, ផ្លែស្វាក៏ផ្លែរយោនរយោន ពេញមែកទាំងអស់ ៗ ពេលនោះ មនុស្ស ១២ នាក់ បានត្រូវគេឲ្យឡើងបេះផ្លែស្វានោះ, បេះតាំងពីថ្ងៃសៅរ៍រហូតថ្ងៃអង្គារទើបអស់ ៗ ធាងស្វាទាំងនោះ លូតឆ្ងាយ ៗ ពីគ្នាណាស់គឺថាបើអ្នកបេះស្វា ដើរស្ទួពីចំណែកខាងកំដៅព្រះអាទិត្យ ទៅចំណែកខាងម្លប់នៃដើមឈើ អាចឃើញព្រះអាទិត្យលិចមុនពេលដែលទៅដល់ ៗ ដល់ត្រឹមនេះ, ព្រះបាទកាលិបទ្រង់គ្រវីព្រះសិររួចដកដង្ហើមធំយូ! យូ! ៗ

កាលគេបេះស្វារួចអស់ហើយ (គាត់ចាប់និយាយត) ខ្ញុំបាទដើរក្រឡឹងជុំវិញដើមស្វា ដើម្បីពិនិត្យមើលឲ្យដឹងថា តើគេប្រមូលផ្លែស្វាអស់ឬនៅ ៗ គ្រាន់តែដើរព័ទ្ធដើមនេះអស់មួយថ្ងៃគត់ ៗ ហើយកាលដែលខ្ញុំរៀបនឹងត្រឡប់ទៅផ្ទះវិញ ស្រាប់តែក្រឡេកទៅឃើញកូនមាន់ឥតុកខ្ញុំទំលើធាងស្វា, វាដេកលក់ក្នុងវេលាយប់ស្រេចទៅហើយ ៗ ខ្ញុំរើសយកដីមួយដុំ រួចចោលសំដៅទៅវា ៗ ដុំដីនោះ បានហើរទៅលើដើមស្វា ប៉ុន្តែវាមិនធ្លាក់មកវិញសោះ វាទៅជារីកទំហំធំឡើងៗ ដរាបដល់គ្របដណ្តប់ពីលើដើមស្វា ហើយខ្ញុំហៅសែនសប្បាយចិត្តដោយបានដី ៤០ អារ សុទ្ធតែជាដីចំការយ៉ាងថ្មីនៅលើអាកាស ៗ

យើងយកសត្វពាហនៈ ទៅដាក់ឲ្យស៊ីស្មៅនៅទីនោះ ហើយកាលដែលរដូវភ្ជួររាស់មកដល់ យើងបានយកដីថ្មីនោះ សំរាប់ដាំដំណាំ ៗ

ជីតាខ្ញុំហើយនឹងខ្ញុំ បានយកគ្រាប់ល្ងទៅដាំ , មួយខែក្រោយមក យើង គ្មានឃើញអ្វីដុះចេញមកសោះ ៗ ជីតាខ្ញុំ បានសួរអ្នកជិតខាងពីហេតុនេះ, គេបន្ទោសគាត់ថា គាត់ជាមនុស្សល្ងីល្ងើទៅដាំងដើមល្ងវិញ ហើយគេថា នៅលើដីដែលមានស្មៅល្អិតទន់ល្មើយដូច្នេះ មានតែឪឡឹកទេ ទើបដាំដុះ ៗ ម្ល៉ោះហើយជីតាខ្ញុំគាត់ប្រើខ្ញុំ នឹងប្អូនប្រុសខ្ញុំដែលត្រូវជាប្អូននៃឪពុកខ្ញុំនោះ ទៅប្រមូលយកគ្រាប់ល្ងទាំងអស់ ដែលយើងសាបពីមុននោះមកទុកវិញ ៗ

គ្រាន់តែប្រមូលនេះអស់មួយម៉ោង ពីព្រោះគ្រាប់ល្ងទាំងអស់មានប្រហែល ៨ ប៊ុសស្ហែល(១) ប៉ុន្តែកាលដែលយើងដើរវិលទៅផ្ទះវិញ ខ្ញុំសំគាល់ដឹងថា បាត់គ្រាប់ល្ងមួយគ្រាប់ ៗ ពេលនោះខ្ញុំត្រឡប់ទៅត្រង់ទីដី ៤០ អាកនោះវិញ ដើម្បីរកមើលគ្រាប់ល្ងដែលបាត់នោះ ៗ ខ្ញុំរៀបតែឈប់លែងរកវាទៅហើយ ស្រាប់តែក្រឡេកទៅឃើញស្រមោចតូចមួយកំពុងតែទាញគ្រាប់ល្ងនោះឆ្ពោះទៅសំបុកវា ៗ ឃើញដូច្នោះ ខ្ញុំស្ទុះទៅទាញយកគ្រាប់នោះពីស្រមោច តែវាមិនព្រមលែងសោះ ជាហេតុនាំឲ្យយើងមានការទាញព្រ័ត្រសង្គ្រាមមួយយ៉ាងឃោរឃៅជាមួយនឹងស្រមោច, ប៉ុន្តែគ្មានអ្នកណាឈ្នះអ្នកណាសោះ ៗ ក្នុងកំដៅនៃការប្រយុទ្ធ, គ្រាប់ល្ង

(១) ប៊ុសស្ហែលនេះ ជារង្វាល់មួយ. មួយប៊ុសស្ហែល មានចំនួនប្រហែល ៣២,៥ លីត្រ. ។ ដូច្នេះ ៨ ប៊ុសស្ហែល ២៦០ លីត្រ ។

ក៏ជាប់ជា ២ កំណាត់ ហើយស្រាប់តែហូរប្រេងចេញលាន់ពីគ្រាប់ល្ង មួយគ្រាប់នោះយ៉ាងអស្ចារ្យ កើតបានទៅជាទន្លេមួយ ជាហេតុនាំឲ្យអ្នកស្រុកអុំទូកដឹកនាំផលានុផលរបស់គេ ទៅលក់ឯទីក្រុងយ៉ាងស្រួល ៗ មកដល់ត្រង់នេះ ព្រះបាទកាលិបទ្រង់ដកដង្ហើមធំយូ! យូ! ម្តងទៀត ៗ

ពេលនោះ ( គាត់ចាប់និយាយត ) កាលដែលឪពុក ជីតាខ្ញុំហើយនឹងខ្ញុំកំពុងតែដាំឪឡឹក ណោតែមានមហាព្យុះកំណាចមួយបក់ក្តួចមក ៗ ដោយហេតុតែគ្មានជម្រកបែបណាមួយលើដី ៤០ អារនោះ យើងក៏មិនដឹងជាទៅជ្រកឯណា ៗ ម្ល៉ោះហើយ ជីតាខ្ញុំនឹងខ្ញុំក៏លោតចូលទៅក្នុងប្រហោងឆ្អេញរបស់ឪពុកខ្ញុំ ៗ ឯឪពុកខ្ញុំ ក្រោយដែលក្រឡេកនាយអាយជុំវិញខ្លួនគាត់ ជាទីបំផុត គាត់បានលោតចូលទៅក្នុងចៀមមួយ ដែលគាត់បីតាមក្រោយយើង ៗ ព្យុះសង្ឃរាបានបោកបក់អស់រយៈពេល៤៧ថ្ងៃ ហើយកុំតែបានចៀមដែលឪពុកខ្ញុំ យកមកតាមជាមួយគាត់នោះ ខ្ញុំប្រហែលអត់បាយក្រហាយទឹកនៅក្នុងប្រហោងឆ្អេញនោះរហូត ៗ

ទីបំផុត យើងខំសំឡឹងមើលមកក្រៅ ហើយបានឃើញព្រះអាទិត្យកំពុងតែចែងចាំងរស្មី ប៉ុន្តែនៅពេលដែលយើងខំវារចេញពីរន្ធឆ្អេញចេញមក ក៏ស្រាប់តែបាត់ដី ៤០ អារនោះអស់រលីង ដោយសារភ្លៀងរំលាយ, ម្ល៉ោះហើយ យើងក៏ជាប់នៅលើអាកាសនោះ តែលតោលៗ តែម្តង ៗ ដោយភ័ព្វសំណាងមាន, ឪពុកខ្ញុំ ដែលជាមនុស្សចេះគិតអនាគត បាន

នាំខ្សែមួយទៅដាប់នឹងខ្លួនគាត់ ។ យើងបង់ខ្សែនោះ ដោយឥតព្រួយបារម្ភ រួចហើយយើងនាំគ្នាសម្រុតចុះតាមខ្សែនោះម្នាក់ម្តង ៗ ដកបដល់រូបខ្លួនផុតពីទុក្ខរឿងមក ។

ព្រះបាទកាលិប ដោយទ្រង់ឃើញថា អ្នកនិយាយរឿងបានបញ្ចប់រឿងខ្លួនហើយ ក៏ទ្រង់ពោលថា: "នេះគឺជារឿងផ្សេងព្រេងមួយ គួរឲ្យចង់ចាំដែលអ្នកបានពណ៌នា; ខ្ញុំបង់សួរអ្នកឯងតែមួយម៉ាត់ថា តើរឿងហ្នឹងពិត ឬកុហក ?" ។ អ្នកនិយាយរឿងឆ្លើយថា: "បពិត្រព្រះអង្គ ! រឿងនេះជារឿងពិត តាំងពីដើមរហូតចប់ ។ -បើប្រសិនណាជាពិតមែន (ព្រះបាទកាលិបពោល) អ្នកឯងឈ្មោះថា មិនធ្វើតាមពាក្យខ្ញុំ ព្រោះខ្ញុំបានបង្គាប់អ្នក ឲ្យនិយាយតែពីរឿងកុហកកុំឲ្យមានពាក្យសច្ចៈ កន្លែងរឿងឲ្យសោះ" ។ -នុព្រះអង្គ, (គាត់និយាយដោយញញឹម) ទូលព្រះបង្គំធ្វើតាមព្រះរាជបញ្ជាព្រះអង្គគ្រប់ម៉ាត់ ពីព្រោះដែលខ្ញុំព្រះអង្គទូលថា "រឿងនេះជារឿងពិត គឺគ្រាន់តែបន្ថែមពាក្យកុហកទៅលើផ្លូវរឿងកុហកចាស់ដែលបាននិយាយរួចមកហើយប៉ុណ្ណោះឯង ក្រាបទូល! ។ ទ្រង់ពោលតបថា: "យ៉ាងហ្នឹងមែនហើយ ! ដំណើររំដើបរំជួលដែលខ្ញុំបានឮពីប្រាជ្ញារបស់អ្នក ឥឡូវឃើញច្បាស់ហើយ !" ។

ពេលនោះ ទ្រង់ព្រះរាជទានដល់អ្នកនិយាយរឿងនូវដុំមាសមួយកំបង់ ហើយបញ្ជូនគាត់ឲ្យត្រឡប់ទៅផ្ទះគាត់វិញហោង ។

---

# រឿងមាណពមិនចេះដេកប្រជ្រៀត

លោក ញុង·សឿង នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

មានសេចក្ដីដំណាលថា កាលពីសម័យបុរាណ មានមាណពម្នាក់ ជាមនុស្សនោតល្ងង់ហើយអៀនខ្មាសណាស់ បើមានញាតិមិត្តប្រុសស្រី ជួបជុំលេងសើចសប្បាយត្រង់កន្លែងណា មិនហ៊ានចូលទៅកាន់ទីនោះទេ ព្រោះគេចេះតែចំអែចំអន់លើកទុកលើកដាក់លើនាងនេះនាងនោះ ៗ ពេលប្រជុំធំ ៗ ដូចជាពេលបុណ្យទាននៅវត្ត ឬមង្គលការជាដើម កំបុរសនេះមិនសូវអើពើទៅលេងកំសាន្តដូចអ្នកដទៃទាំងពួងឡើយ គឺជាមនុស្សមុខខ្វរ អឹមអៀមអៀនប្រៀនមិនចុះដំនុំចំណោមទីងគេសោះ ៗ ឯឈ្មោះដើមដំបូងរបស់មាណពនេះ គេមិនបានចាំប្រាកដថាឈ្មោះអ្វីទេ, តែដោយហេតុតាមានការអៀនខ្មាសច្រើនដូច្នេះ ទើបនាំឲ្យអ្នកស្រុកភូមិគេនាំគ្នាហៅថា "អាខ្វរ ៗ" ជាប់ដរាបមក ៗ សូម្បីតែឪពុកម្ដាយបង្កើតរបស់មាណពនេះ កំហៅថា "អាខ្វរ ៗ" ស្រលមាត់តាមគេដូច្នោះដែរ ៗ

ចំណែកកិច្ចការស្រែចំការជាដើម អ្នកកំឡោះយកចិត្តទុកដាក់ធ្វើហ៊ឹងម៉ឹងម៉ាត់ជាទីបំផុត ជាហេតុនាំឲ្យឪពុកម្ដាយស្រឡាញ់ពេញចិត្តណាស់ ទោះទាំងញាតិមិត្តជិតឆ្ងាយកំសរសើរខ្វរគ្រប់មាត់ដែរ ៗ មានគេចង់លើកកូនក្រមុំឲ្យមាណពនេះជាច្រើននាក់, តែបុរសឥតត្រូវការនឹកនាពីរឿងប្រពន្ធកូនសោះ ៗ រីឯឪពុកម្ដាយ ចេះតែព្រួយបារម្ភ ព្រួយត្រង់

កូនមិនព្រមយកប្រពន្ធនេះឯង ណាមួយទៀតខ្លួនមានអាយុកាន់តែច្រើនផង គឺជិត ៣០ ឆ្នាំទៅហើយ ។ តមកក្រោយ, ឪពុកម្តាយនិងញាតិមិត្តនិយាយលួងលោមអង្វរសម្រុះសម្រួលខ្លះ បង្ខំខ្លះ ពន្យល់ហេតុផលផ្សេងៗខ្លះ អំពីរឿងប្រពន្ធនេះ, ខ្លួនក៏យល់ព្រមទាំងប្រថុយ ។ គ្រានោះឪពុកម្តាយមានចិត្តត្រេកអរណាស់ បានទៅដណ្តឹងកូនក្រមុំគេម្នាក់ដែលខ្លួនពេញចិត្តហើយដែលនៅភូមិឆ្ងាយបន្តិច ។ ខាងស្រីក៏មានសេចក្តីអបអរសាទរណាស់ទៅទៀត ព្រោះគេចង់លើកឲ្យតាំងពីយូរណាស់មកហើយដែរ ។ បន្ទាប់ពីនោះមកមិនយូរប៉ុន្មាន, មាតាបិតាទាំងសងខាងបានរៀបចំមង្គលការយ៉ាងអឹកធឹកតាមគន្លងប្រពៃណី ។ ក្នុងថ្ងៃចូលរោងខ្លួនឥតញញឹមរីករាយអ្វីបន្តិចសោះ បេះតែក្រៀមក្រំជានិច្ច ព្រោះទើបនឹងបានជួបប្រទះនូវទីជុំនុំចំណោមគ្រានេះជាលើកដំបូងបង្អស់ ហើយជាការផ្ទាល់ខ្លួនឯងតែម្តង ។ ទទួលពេលនោះ មានទាំងមិត្តភក្តិកំឡោះជាច្រើននាក់ គេមកចោមរោមបំអកចំអន់សើចលេងគឹល ៗ ផង ជាហេតុឲ្យខ្លួនរឹងរឹតតែអៀនខ្មាសណាស់ថែមឡើងទៀត ។ ពល់តែពេលធ្វើពិធីផ្សេង ៗ ដូចជាកាត់សក់, ក្រាបសំពះស្តាប់លោកសូត្រមន្តនិងសែនបងដៃជាដើម, មាណពមានទឹកមុខស្លុតស្រពោនជាដរាប ទោះបីគេសុំឲ្យញញឹមយ៉ាងណាក៏ដោយ ។ ថ្ងៃស្អែកឡើងព្រលឹមស្រាង ៗ ដល់កំណត់ពេលហើយ, អាចារ្យកាន់វេលាការ ក៏បាននាំសាមីខ្លួនឡើងទៅរង់ចាំ

ត្រង់កន្ទែងសំពះផ្ទឹម ៗ គ្រានោះ ក្មេងបានប្រគំកំដរតាមទំនៀមយ៉ាងពីរោះ លន្លង់លន្លោចគួរឲ្យស្រងេះស្រងោចពេកក្រៃ នាំឲ្យពួកអ្នកមានគូស្រករ រួចហើយនឹកព្រឺព្រួចចង់រៀបមង្គលការខ្លួនម្ដងទៀត ៗ គ្រានោះ ខ្សរទៀន ទឹកមុខខ្មៅជាំ ភ័យបុកពោះផ្អក ៗ បែកញើសជោកទាំងព្រឹកព្រហាម ព្រោះពេលសំពះផ្ទឹមនេះជាមង្គលធំផ្ដាច់ព្រ័ត្រ ៗ លុះគេរៀបចំឲ្យអង្គុយបត់ជើងស្រួលបួលហើយ, អាចារ្យបង្គាប់ឲ្យខ្សរប៉ាយហូតស្លាម្លូ ៣ ដែលគេដាក់លើខ្នើយសម្រាប់ក្រាបសំពះផ្ទឹម, ខ្សរភ័យញ័រទទ្រាក់ទទ្រើក ស្រាប់តែដាក់ដៃច្រប់សង្រួបទៅលើខ្នើយនោះ ដូចឆ្មាលោតច្រប់កណ្ដុរ ជ្រុះស្លាម្លូប៉ិនគេពយ ៗ គេនាំគ្នាសើចគិលឡើងលាន់ឮពេញទាំងផ្ទះ ៗ ពួកកំឡោះៗដើងវិលខ្ទះ ក៏រអិលមាត់ក្ដាត់ក្លយពាក្យថា ថប់ណាស់វ៉ុយ! បើលេងតែប្រើស្នៀតលោតសង្រុបយ៉ាងនេះ ដល់ពេលផ្សំដំណេកហើយក្នុងពេលយប់នេះ មើលទៅមុខជារង្គើគោករង្គើហិងផ្អើលគេផ្អើលឯងមិនខានទេវ៉ុយកនយើង! ៗ គេនិយាយចំអន់លេងដូច្នេះមិនទាន់ទាំងផុតមាត់ផង ស្រាប់តែឮស្នូរសំឡេងពីក្រោមគូថពៅខ្សរមកទៀត " ប៉េត ៗ - ប៉ា-រេត - ប៉េត ៗ !" ៗ សាមីខ្លួនធ្វើហាក់មិនដឹងខ្លួន ៗ ពួកអ្នកអង្គុយនៅឆ្ងាយមិនបានឮសំឡេងនេះទេ ព្រោះវាថ្ងន់តែនឹងស្នូរស័ព្ទក្មេង, តែបំណែកពួកកំឡោះ ៗ ជាគូកនដែលអង្គុយកំដរជិត ៗ ខ្សរទាំងប៉ុន្មាន សឹងបានឮជាក់ប្រាកដណាស់ ទើបគេនាំគ្នាសើចគិលឡើងមួយសាទៀត ព្រមទាំង

អ្នកខ្លះបានបន្ថែមសំដីតិចៗ ថា អាខ្ញ! ក្មេងគេមិនស្លូវពីកេះ ប្ដុយ៉ាងណា បានជាអាឯងចាំបន្ថែមស្រឡៃប៉ុពកអី ៗ មកទៀត? អ្នកខ្លះខ្សឹប ៗ ថា អាខ្ញ! បើអាឯងលេងតែផ្គរទេទេ មិនជាការអ៊ីប៉ុន្មានទេ នៅមានផ្ទរគ្រាន់ទប់ទល់ខ្លះ តែបើមានតាំងក្មៀងដោយមកជាមួយផងនុ៎ះ ពួកយើងមុខជាល្មំងចោលឥឡូវហ្នឹងហើយ ឥតបាននៅជួយកំដរគេទៅទៀតទេរ៉ុយ ៗ គ្រានោះ មាណពរឹងរឹតតែអៀនខ្មាសទ្វេត្រួតឡើងយ៉ាងហួសប្រមាណៈស្ទើរបាត់ស្មារតី ទឹកមួយមៅក្ដៅក្រហាយឥតឧបមាពិចារណាតែក្នុងចិត្តថា "ពេលនេះថ្ងៃសំការធំហើយអញ! គិតទៅរឿងការប្រពន្ធនេះហៅចំជាពិបាកមែន! សោតឯអាផែងផោមនេះទៀត បើឯងកំពុងតែខ្មាសគេជិតដាច់ខ្យល់ស្លាប់យ៉ាងនេះ ពបន្ថិបញ្ចេញសំឡេងយកមុខមាត់ពតគ្រេតគ្រេតកណ្ដាលបំណោម ធ្វើឲ្យឯងរឹតតែបាត់ព្រលឹងទៅទៀត, ម៉ែហើយនឹងឪគាត់ធ្វើឲ្យឯងវង្វេងកម្មអាម៉ាសមុខស្ទើរតែស្លាប់ខ្លួនតែម្ដងហើយជាន់នេះ ៗ បុរសគិតម្ដងថា នឹងក្រោកបោលទំលាយទីប្រជុំជនរត់ឲ្យបាត់ស្រឡះទៅ គិតម្ដងថា ណ្ហើយកុំ... ស៊ូទ្រាំបន្តិចទៅទៀតចុះ ៗ លុះអ្នកក្មេងម្នាក់បានរៀងរាំបើកវាំងននរួចហើយ គេក៏នាំកូនស្រីចេញមកសំពះផ្ទឹមជាមួយ ៗ មួយសន្ទុះធំមកទៀត ការសំពះផ្ទឹម ក៏បានចប់សព្វគ្រប់ត្រឹមកិច្ចដែលអាចារ្យសូត្រធម៌ឲ្យពរសព្ទសាធុការតាមទំនៀម ៗ ចៅខ្លះហាក់បានធូរចិត្តបន្តិចដូចគេដកបន្លាពីដើមទ្រូង ទឹកស្មានថាបានរួចខ្លួនហើយជាន់នេះ ៗ ពេល

ក្រោកពីសំពះផ្ទឹមគ្នា ចាស់ ៗ បង្គាប់ខ្ទរឲ្យគេរានជាយស្បៃប្រពន្ធចូលទៅក្នុងបន្ទប់ ។ ប៉ុរសគោនជាយស្បៃបណ្តើរងាកមើលក្រោយបណ្តើរឥតឃើញគេជូនជួយកំដរទៅជាមួយផងសោះ ក៏នឹកព្រួយបារម្ភមួយលើកទៀត ព្រោះមិនដឹងជាមានរឿងអ្វីខ្លះទៅទៀតក្នុងបន្ទប់នោះ, ណាមួយរាស្រពន់ដើងខ្លាំងផង ឈានដើងដើរស្ទើរពុំរួច, ដល់មាត់ទ្វារបន្ទប់ស្រាប់តែខ្ទរមិនព្រមចូលតាមប្រពន្ធ នៅប្រទាញប្រទង់គ្នាយឺតចុះយឺតឡើង នាំឲ្យគេសើចលាន់ទ្រហឹងអឺងកងពេញទាំងផ្ទះ ទាល់តែចាស់ទុំខ្លះជួយរុញច្រានបង្ខំខ្លាំង ទើបខ្ទរព្រមចូលទៅក្នុងបន្ទប់ទាំងនុនមុខក្លុលផង ។ រឿងអៀនខ្មាសនេះ មិនមែនមានចំពោះតែលើរូបសាមីខ្លួនខ្ទរប៉ុណ្ណោះទេ, ទោះទាំងឪពុកម្តាយបងប្អូនមាមីងទាំងប៉ុន្មានរបស់ខ្ទរ ក៏ត្រូវទទួលការអាម៉ាស់មុខស្ទើរតែងើបមុខមិនរួចដែរ, តែមិនដឹងធ្វើដូចម្តេច បើការនេះរាជ្រុលហួសអស់ទៅហើយ ។

លុះរួចកិច្ចមង្គលនេះហើយ, ឪពុកខ្ទរក៏ជំកបលាជនូងត្រឡប់ទៅផ្ទះវិញ ដោយមានធុរៈម្តាយគាត់ចាស់ជកឈឺជាទមុន គាត់ទុកតែប្រពន្ធគាត់ឲ្យនៅកំដរនៅទីនោះសិន ។ មុខនឹងលាទៅ ឪពុកខ្ទរ បាននិយាយផ្តាំផ្ញើប្រគល់កូនប្រុសគាត់ថា " អ្នកជនូងអើយ ! សូមអ្នកអត់ទោសផងចុះ កូនខ្ញុំនេះរាអៀនខ្មាសធ្ងាំធ្ងងច្រើនណាស់ ដូចអ្នកបានឃើញស្រាប់ហើយ តែចំណែកខាងរបៀបធ្វើកិច្ចការសព្វសារពើនោះ គឺរាគ្រាន់បើដែរ, ឥឡូវនេះ រាបានមកជាកូនរបស់អ្នកហើយ ស្រេចតែអ្នកជេរស្តីប្រដៅប្រដៅរា

ឲ្យបានស្រួលបួលផងចុះ " ។

ជនូងតប: " មិនអីទេអ្នក ! ការនាំគ្នាផងបន្តិចបន្តួចនេះ យើងអាចលៃលកកែសម្រួលទៅថ្ងៃក្រោយបានដែរ, សូមអ្នកអញ្ជើញចុះ, ឯរឿងយាយម្ដាយអ្នកដែលឈឺខ្លាំងនោះ បើយ៉ាងណា ៗ សូមអ្នកឲ្យដំណឹងខ្ញុំវិញប្រញាប់ផងកុំខាន " ។ ឪពុកខ្វះដឹកបណាជនូងរួច ក៏ទឹមរទេះបរចេញដំណើរយ៉ាងរួសរាន់ទៅទាំងព្រឹកនោះឯង ។

លុះដល់ពេលយប់ប្រហែលម៉ោង ៧ ជាពេលត្រូវផ្សំដំណេក, ដូនចាស់ ២ នាក់ ( យាយអ៊ូនិងយាយច័ន្ទ ) ហៅគូស្រករថ្មីឲ្យមកអង្គុយទល់មុខគ្នាក្នុងបន្ទប់នោះដែលមានចំអាប ១ ចាស នំបន្ថែម ១ ចាស ព្រមទាំងទឹកដូង នំបេកកុំជាដើមតាមទំនៀម ។ ចៅខ្ទីបែកញើសម្ដងទៀតអង្គុយខ្ទុនមុខជ្រប់គិតថា " ស្អីទៀតហើយអេះ ? ឯងស្មានថាចប់អស់ហើយ, យីអើ ! គិតទៅរឿងការប្រពន្ធនេះនាំឲ្យបែកញើសច្រើនណាស់តើ!" ។ បន្ទាប់ពីការធ្វើពិធីសែនព្រេនបន្តិចបន្តួចរួចហើយ, យាយអ៊ូបង្គាប់នាងប្រពន្ធឲ្យជួសទឹកដូងបញ្ចុកប្ដី ៣ ស្លាបព្រា ហើយឲ្យប្ដីជួសបញ្ចុកប្រពន្ធវិញ ៣ ស្លាបព្រាដែរ ព្រមទាំងប្រាប់ទៀតថាត្រូវលេបឲ្យអស់កុំឲ្យខ្ជាក់ចោល, អ្នកទាំងពីរក៏បានធ្វើតាម ។ រួចពីនេះទៅ យាយច័ន្ទបង្គាប់នាងប្រពន្ធឲ្យយកបេក ៣ ដុំ ( មួយដុំម្ដង ៗ ) បញ្ចុកប្ដីដែលក្រអឹមក្រអៀមស្ទើរតែមិនចង់ហារមាត់ទទួលផង ។ លុះបានបេកដល់

ក្ទងមាត់ហើយ , ចៅខ្បរមិនព្រមលេបសោះ នៅបៀមគ្រលរទូញមាត់ ដូចស្វាបៀមផ្លែឈើ ។ ដល់វេលាត្រូវខ្ពុនបញ្ចុកប្រពន្ធវិញ , ខ្បរបញ្ចុកចូលមាត់គេបានតែបេក ២ ដុំ កាន់តែទឹកអៀនឡើង ។ ឆុនមុខជ្រប់លែងហ៊ានមើលចំមុខប្រពន្ធ ដល់បញ្ចុក ១ ដុំទៀត លូកដៃស្ទាន ។ មិនប៉ះឯមាត់ ទៅពារលើឯច្រមុះគេវិញ , ពេលនោះប្រពន្ធមិនទាន់ទាំងទំពារលេបបេក ២ ដុំមុននោះអស់ផង ស្រាប់តែសើចហឹក-ប្ដីសើចឃុះ ប៉ុនគេព្រុសព្រូសបេកដាក់មុខគ្នាទៅវិញទៅមក ប្រម្សាក់មុខស្រមាមទាំងពីរនាក់ ។ យាយតាស់ ។ អ្នកផ្សំដំណេក សើចរឹងជំបារពោះអស់ ។ យាយទាំងពីរបានយកទឹកឲ្យប្ដីប្រពន្ធលុបលាងមុខមាត់ឲ្យជ្រះស្អាតហើយក៏ឲ្យមកអង្គុយកន្ទួងដដែលវិញ ទើបគាត់ប្រាប់អ្នកទាំងពីរថា ចៅប្រុសត្រូវដេកខាងស្ដាំ ឯចៅស្រីត្រូវដេកខាងឆ្វេង ហើយខ្សឹបខ្សៀវប្រាប់អំពីកិច្ចរមដំណេក . . . តាមប្រពៃណី ។ ដល់រៀបចេញពីបន្ទប់មកក្រៅ , យាយច័ន្ទខ្សិបប្រាប់នាងប្រពន្ធថា ប្ដីនាងអៀនខ្មាសច្រើនណាស់ ដូចនាងបានដឹងស្រាប់ហើយ , បើនាងសំកុកចាំតែមើលដំណើរទំនងប្ដីនោះ មើលទៅមុខជាមិនបានការអ្វីទេ , ដូច្នេះត្រូវនាងឯងដៃដល់បន្តិចទើបកើតការ . . . ។ លុះរួចកិច្ចសព្វគ្រប់ហើយ ដូនទាំងពីរក៏លើកថាសទឹងអំភ៊ីនកំប៉ុកកំប៉ុកចេញមកក្រៅរួចបង្គាប់នាងប្រពន្ធឲ្យបិទទ្វារ ហើយឲ្យខ្ទាស់ទុកឲ្យជាប់ ។ ចំណែកខ្បរ លុះគេចេញផុតមកក្រៅអស់ហើយ

នៅតែពីរនាក់ប្ដីប្រពន្ធ ក៏តាំងប្រះដេកយកដៃគងថ្ងាស តប់ប្រមល់ក្នុងចិត្តឥតឧបមា បេះតែទឹកព្រួយបារម្ភក៏យំផ្អក ៗ : “ ចប់អស់យ៉ាងហើយអញ! មើលទៅរបៀបការប្រពន្ធនេះមិនងាយចប់ឆាប់ទេ ពីរថ្ងៃកន្លងមកហើយនេះឃើញថាមានកិច្ចការរជាក់រដុបច្រើនណាស់ហើយសុទ្ធតែជាការនាំបណ្ដាលឲ្យកើតសេចក្ដីអៀនខ្មាសស្ទើរតែគ្រប់អន្ទើ , ពីម្សិលមិញបន្តិចថាកាត់សក់, បន្តិចថានេះ បន្តិចថានោះ មិនបេះអស់មិនបេះហើយសោះ, ព្រឹកមិញ គេឲ្យក្រាបសំពះផ្ទឹមគ្នា ឯងខំប្រឹងទប់ខ្លួនបែកញើសជោកទាល់តែលេចជោមកណ្ដាលជំនុំចំណោម . . . គេគិតតែនាំគ្នាសើចគឹលៗ..., ដល់មកល្ងាចនេះ គេឲ្យបញ្ចុកបេកព្រួសដាក់មុខគ្នា, យប់នេះទៀត មិនដឹងជាមានរឿងហេតុយ៉ាងណា យ៉ាងណីទៀតទេ បើយាយ ៗ ទាំងពីរនាក់នោះ បន្តិចមកខ្សិបខាងណេះបន្តិចទៅខ្សិបខាងណោះ . . . ឱអញអើយអញ! នៅសុខ ៗ មិនគួរបើមកខកខ្លួនដល់ម្ល៉េះសោះ ” ។ វេលានោះប្ដីប្រពន្ធទាំងពីរនាក់ ឥតមានពាក្យនិយាយគ្នាទៅវិញទៅមកថាដូច្នេះដូច្នោះទេ នៅតែស្ងៀមស្ងាត់រៀង ៗ ខ្លួន ៗ រំលងមកមួយស្របក់, នាងប្រពន្ធពន្លត់ចង្កៀងងងឹតឈឹងសូន្យ ។ ប្ដីក្រោកឡើងស្ទាបរកឈើគូសចង់អុជចង្កៀងវិញ តែរកមិនឃើញក៏ប្រះដេកទៅវិញទៅ ។

វេលារាត្រីនោះ ប្រហែលម៉ោង ៩ ជិតក្ដី ស្រាប់តែនាយខ្បរទៅ

ដល់ផ្ទះ គោះទ្វារប៉ុក ៗ ហៅឪពុក មានទាំងហិបខ្មៅ(១) មួយស្ពាយប្រឆាំងនៅស្មាផង : “ ឪអើយ ! អឺឪ ! បើកទ្វារឲ្យខ្ញុំចូលផង ” ។

—អាណាហ្នឹងគោះទ្វារទាំងយប់អធ្រាត្រ ?

— ខ្ញុំណាឪ ។

— អាណាខ្ញុំ ៗ ហ្នឹង អាខ្វរ ឬ ?

— បាទ ខ្ញុំហ្នឹងហើយ ។ ឪពុកស្ទុះទៅបើកទ្វារឲ្យដោយភ័យផ្អុក ៗ ផង “ យីអើ ! ខ្មោចអាចោរអន្តរធាន ! ម៉េចក៏រត់មកទាំងយប់អធ្រាត្រដូច្នេះ មានរឿងរ៉ាវយ៉ាងម៉េច ? ។ ខ្វរចូលទៅក្នុងផ្ទះ ដាក់ហិបព្រួសក្បែរគៀនជញ្ជាំង ហើយឈរសៀមបែបអេះអុញ មួយស្របក់ទើបនិយាយ “ រឿងស្រីនុ៎ងណ៎ា ...” ។

— ចុះនាងនុ៎ងវ៉ាយ៉ាងម៉េច វ៉ាមិនព្រមព្រៀង ឬ ក៏ឈ្លោះទាស់ទែងគ្នាយ៉ាងណា ? អាឯងប្រាប់អញឲ្យអស់រឿងហូរហែមកមើល ។

— ខ្ញុំអៀនមាត់ណាស់ មិនចង់និយាយទេឪ ! ណ្ហើយ ! ឪឯងកុំដេញដោលសួរធ្វើអី ។

---

១– នៅស្រុកយើង ពាស់ពីដើម ច្រើនប្រើហិបខ្មៅដែលអ្នកខ្លះហៅថាហិបអាភៀន ។ ហិបនោះ គេធ្វើពីឈើស្រស់យ៉ាងស្រាល, លាបថ្នាំខ្មៅរលោង ទំហំតូចល្មម មានត្រចៀកដែកទាំងសងខាងសម្រាប់ចាប់ លើកឬចងខ្សែស្ពាយឲ្យបានស្រួល; គំរបវិមានសណ្ឋានអូលល្អ ដូចគំរបក្តារមឈូសបិន, គេប្រើដាក់អាភៀននាំចូលមកលក់ក្នុងស្រុកយើង, កាលណាគេលក់អាភៀនអស់ទៅ បងប្អូនយើងជំនាន់នោះ ចូលចិត្តទិញហិបនេះយកប្រើសម្រាប់ដាក់ខោអាវ ។

-ទេ, បើអាឯងមិនប្រាប់រឿងអញៗ សំពងក្បាលអាឯងឥឡូវហ្នឹងៗ

-ចុះឲ្យខ្ញុំនៅដេកជាមួយឯណាផងបាន បើ . . . បើ . . . ។

-បើ : . . អី ? ។

-បើ... បើ... អត់អៀនអត់ខ្មាសអីសោះ លេងតែពន្លត់ចង្កៀង ហើយដេកប្រជ្រៀត, ខ្ញុំខិតទៅទើសជប់កៀនជញ្ជាំងហើយ ក៏នៅតែតាមប្រជ្រៀតទៀត ហើយដៃនាងនោះនៅមិនស្ងៀមទេផងអើយ បេះតែលូកកាវឲ្យរើក បន្តិចស្ទាបត្រង់ណោះបន្តិចស្ទាបត្រង់ណោះ រកតែដេកមិនបាន, តាំងពីក្បាលល្ងាចមកខ្ញុំឥតបានធ្មេចមួយប្រិមសោះ ។

ឪពុកវិតដើមទ្រូងគ្រឹត ១ ទៅជាហួសចិត្ត ត្រឡប់ជាសើចផ្អើលគេផ្អើលឯងទាំងយប់ " អើ ! នេះបានចំជាកូនឪ ! អញខំរកប្រពន្ធការឲ្យអាឯង ពីព្រោះតែរឿងដេកប្រជ្រៀតហ្នឹងហើយ ឥឡូវ ត្រឡប់ទៅជាកំសាកញីចោលម្សៀតទៅវិញ ! ហ៊ុះ ! អញចង់តែធាក់អាឯងបំបាក់កឥឡូវហ្នឹង ធ្វើឲ្យអញខ្មាសគេពេញទាំងស្រុក ។

- ទេ ឪឯងទេតើដែលធ្វើឲ្យខ្ញុំខ្មាសគេ, តាមចិត្តដែលខ្ញុំនឹកមួម៉ៅក្តៅក្រហាយ ខ្ញុំចង់វត់ចោលតាំងពីកំពុងសំពះផ្ទឹមៈនោះម៉្លេះ តែនឹកសព្វ ១ ទៅឃើញថាណ្ហើយ ! គួរទុកមុខមាត់ឲ្យឪឯងបន្តិចទៅចុះ ទើបខ្ញុំស៊ូទ្រាំបង្អង់ទៅវិញសិន, រឿងប្រពន្ធនេះ ខ្ញុំបានប្រកែកតាំងពីដំបូងថាទេ ។ តែឪឯងហើយនឹងម៉ែចេះតែបង្ខំខ្ញុំ ។ ក៏ព្រមទាំងប្រចុយទៅ ។

– ឪពុកបែបទាល់ជើង ទើបត្រឡប់សួរសាដើម “ ចុះកាលអាឯងចុះចេញពីផ្ទះមកនោះ ប្រពន្ធអាឯងបានដឹងទេ ? ” ។

– ឥតដឹងទេ គេកំពុងដេកលក់ ។

– ចុះម្ដាយអាឯង ហើយនិងឪពុកម្ដាយក្មេកតើគេបានដឹងដែរឬទេ ?

– ឥតដឹងទាំងអស់ ព្រោះគេដេកលក់ស្កាត់សូន្យគ្មានសល់ម្នាក់ ។

– ណ្ហើយ ! ឥឡូវនេះ ត្រូវអាឯងត្រឡប់ទៅវិញជាមួយអញ ។

– ទេ ខ្លាចគេណាស់ ! ខ្ញុំបានគិតស្រេចហើយថា មកនេះគឺឥតត្រឡប់ទៅវិញទេ ។

– ប្រាកដជាមិនទៅវិញមែនឬ អាខ្វរ?

– បាទ ប្រាកដហើយ ។

ឪពុកស្ទុះចូលទៅក្នុងផ្ទះបាយ កន្ត្រាក់បានអង្រែបុកគ្រឿង ។ ខ្វរឃើញដូច្នោះក៏អង្វរ “ កុំអាលឪ... កុំអាលវ៉ៃខ្ញុំ... សុំឪអត់ទោស , ណ្ហើយចុះ រឿងត្រឡប់ទៅវិញនោះ មិនជាការធ្ងន់ស្រាលអីប៉ុន្មានទេ ខ្ញុំប្រថុយទៅវិញក៏បានដែរ, តែថាសុំឲ្យឪឯងទៅនិយាយសម្រុះសម្រួលនឹងនាងនោះសិនថា តទៅកុំឲ្យលេងតែដេកប្រជ្រៀតដូចយប់មិញនេះទៀត ទើបខ្ញុំព្រម ។

– ទេ! អញមិនឆ្កួតដូចអាឯងទេ ! ណ្ហើយ ! ខ្ជិលនិយាយដដែលៗ ឥឡូវបើអាឯងមិនចេះដេកប្រជ្រៀតជាមួយប្រពន្ធទេ យើងគិតប្រជ្រៀត

ជាមួយអង្រែបុកគ្រឿងនេះសាកល្បងមើលម្ដង ៗ ថាតែប៉ុណ្ណោះ ឪស្អុះ ក្អែក, ក្អួទគេបង្អួចលោតព្រួសដល់ដី រត់រហូតក្រៅរបងផ្ទះ ៗ គ្រានោះ ឪពុកនាយខ្វរស្លៀកពាក់ខោអាវប្រញិកប្រញាប់ ហើយក៏ស្រូតរូតទៅផ្ទះជន្ទង់ទាំងព្រឹកព្រហាម ដើម្បីឲ្យដំណឹងនឹងពិគ្រោះសម្រេចពីរឿងនេះ ៗ

យើងនឹងឆាកទៅមើលឯផ្ទះខាងស្រីឯណោះម្ដង តើមានហេតុការណ៍យ៉ាងណាខ្លះ ៗ ពេលព្រឹកនោះ នាងសាមីខ្លួនភ្ញាក់ឡើង ស្រាប់តែរកប្ដីមិនឃើញ ទាំងហិបនឹងខោអាវរបស់ប្ដីក៏បាត់អស់រលីង ៗ កាលបានដឹងដូច្នោះហើយ នាងក៏យំបុកពោះផ្អឹក ៗ បានស្ទុះស្ទាទៅប្រាប់ឪពុកម្ដាយនឹងម្ដាយក្មេកតាមដំណើរ ៗ អ្នកទាំងអស់គ្នា ផ្អើលជ្រួលច្របល់ ខ្លះឡឹបខ្សឹបថាដូច្នេះ ខ្លះថាដូច្នោះ ខ្លះថាគេបានសង្កេតឃើញទឹកមុខកូនប្រុសតាំងពីល្ងាចម្ល៉េះ គេស្មើរតែហ៊ានទាយទុកថា មុខជារត់ចោលប្រពន្ធពុំខានទេ ឥឡូវរត់បាត់មែន ៗ ម្ដាយបង្កើតរបស់នាយខ្វរ ឡើងទឹកមុខក្រៀមស្ញតបែស បាត់មាត់បាត់កហានិយាយដូចម្ដេចក៏មិនកើត ៗ ពេលនោះគេបានហៅយាយច័ន្ទដែលជួយផ្សំដំណេកពីល្ងាចនោះ មកឲ្យជួយអង្កេតសាកសួរនាងប្រពន្ធយ៉ាងសម្ងាត់ ដើម្បីឲ្យបានដឹងជាក់ប្រាកដថា តើមានហេតុភេទដូចម្ដេចខ្លះក្នុងពេលយប់មិញ បានជានាយខ្វររត់បាត់ដូច្នេះ ៗ យាយក៏បានចូលទៅក្នុងបន្ទប់ស្ងាត់តែពីរនាក់នឹងសាមីខ្លួន ហើយផ្ដើមសួរ " នាង ! សុំនាងប្រាប់យាយឲ្យត្រង់មកមើល តើយប់មិញមានរឿង

ហេតុដូចម្តេចខ្លះ បានជាប្តីនាងរត់បាត់ទាំងយប់ដូច្នេះ ។

— ចាស ! គ្មានរឿងអីជាធំដុំទេ ក្រោយពីពន្លត់ចង្កៀងមួយសន្ទុះធំ ខ្ញុំគ្រាន់តែធ្វើតាមបណ្តាំយាយឯងប៉ុណ្ណោះ ព្រោះយាយបានប្រាប់ថា តោងដៃដល់បន្តិច—ខ្ញុំនឹកឡើងចង់តែសើច—ដំបូង ខ្ញុំលូកដៃស្ទាប ៗ ទៅ ស្រាប់តែប៉ះចំចង្កេះ គេភ្ញាក់ព្រើត បែរសើចខ្ទាំង រួចគេចិតរមូតដល់កៀនជញ្ជាំង ។ យាយច័ន្ទសើចញញឹម : " ចប់ណាស់អញ ! ចប់តែមិនមែនប៉ះចំចង្កេះ ក្រែងប៉ះចំត្រង់កន្លែងក្រោមចង្កេះទេដឹង ?

នាងសើចទើបតបប្រាប់: " អត់ទេ, ប៉ះចង្កេះមែន ខ្ញុំមិនកុហកទេ ។

— រួចយ៉ាងម៉េចទៅទៀត ?

— មួយស្របក់ ខ្ញុំប្រថុយចិតទៅតាម ហើយលូកដៃករសាកល្បងមើលទៀត ព្រោះខ្ញុំគិតឃើញថាបើទើសនឹងជញ្ជាំងទៅហើយ តើគេស្ទុះទៅខាងណាទៀត, លូកស្ទាបម្តងណោះ លេងពារចំត្រង់កន្លែងក្រោមចង្កេះមែន, ស្រាប់តែគេប្រឡោតខ្លួន ដូចគោស្ទាវត្រូវមួយជន្ទាញអីចឹង រួចទៅទង្គិចនឹងជញ្ជាំងឮស្នូរគ្រាំង ។

— យាយសើចក្អាក ៗ : " អុញ្ញុះ ! អញថាមែន ៗ អីចាះ ! អញថាមុខជាមានបើប៉ះពារចំកន្លែងអី ៗ នុងមិនខានទេ, ឥឡូវមែន . . . គិតទៅមង្គលការយើងនេះ មានរឿងចំឡែកនាំឲ្យបានសើចសប្បាយច្រើនណាស់ ដូចកាលពីក្បាលព្រលប់ពេលផ្សំដំណេកម្សិលមិញដែលគេមកពាក

បេកមកប៉ះបំប្រមុះទៅឯង ហើយព្រួសបេកដាក់មុខគ្នានោះ យាយសើច អើយសើច យាយទៅដល់ផ្ទះចូលដំណេកហើយក៏នៅតែសើចម្នាក់ឯងទៀត ឥឡូវនេះទៅឯងលេងលូកដៃស្ទាបទាល់តែប៉ះចំអីវ៉ាន់របស់គេវិញ, តែចំណែកគេ ៗ បានប៉ះតែគ្រឿងលើរបស់យើង ឯយើងលេងពារបំគ្រឿងក្រោមសំខាន់របស់គេតែម្តង, គិតទៅទុកជាបានស៊ីសងរួចគ្នាដែរ... នៃទៅ! ហើយរួចពីនេះយ៉ាងម៉េចទៅទៀត ?

— ចាស ! តពីនេះទៅ គេស្ទុះក្រោកក្រេសទៅអង្គុយចុងជើង ដកដង្ហើមយូ ៗ បែបតឹងទ្រូងខ្លាំង, ចំណែកខ្ញុំ ៗ អស់កំឡាំងហើយផ្ងុយដេកផង ខ្ញុំក៏ដេកលក់ទៅ, ភ្ញាក់ព្រលឹមឡើងស្រាប់តែបាត់គេតែម្តង មិនដឹងជាគេទៅពីថ្មើរម៉ាន ហើយទៅឯណានោះ ខ្ញុំឥតបានដឹងសោះ, រឿងរ៉ាវពីយប់មិញ មានតែប៉ុណ្ណេះ សូមយាយជ្រាប ។

— អូ! បើដូច្នោះ យប់មិញនេះគ្មានបានសម្រេចការអីម្យ៉ាងៗ ជាធំដុំសោះទេ, រូបរួមសេចក្តីទៅឃើញថា គ្រាន់តែខាងគេឯណោះបានប៉ះប្រមុះយើង ហើយខាងយើងឯណោះបាន ស្ទាបប៉ះចំអីវ៉ាន់គេតែប៉ុណ្ណោះឯង, ដូច្នេះ រឿងនេះគឺនៅបរិសុទ្ធស្អាតទាំងអស់គ្នា, ណ្ហើយ ! យាយបានដឹងរឿងរ៉ាវតែប៉ុណ្ណឹងបានហើយ យាយសុំអរគុណទៅ! ។ និយាយដូច្នេះហើយ យាយច័ន្ទក៏ចេញពីក្នុងបន្ទប់មកក្រៅ បានទៅជួបជុំខ្សិបខ្សៀវរៀបរាប់ប្រាប់ឪពុកម្តាយទីងម្តាយក្មេកនាងសាម៉ីខ្ទួន តាមដំណើរហូរហែដូចបានសាស័ព្ទខាងដើមមកហើយនេះឯង ។ អ្នកទាំងអស់ ទៅជានាំ

គ្នាសើចក្អាកក្អាយពេញទាំងផ្ទះ ។

ក្នុងពេលកំពុងជួបជុំសន្ទនាគ្នានោះ ស្រាប់តែលេចឪពុកខ្វរឡើងភ្លែតទៅដល់លើផ្ទះ ។ ឪពុកខាងស្រី ស្រែកភ្លាមដោយសេចក្ដីត្រេកអរ " អូ! និ! អ្នកជន្លងអញ្ជើញមកដល់ហើយតើ, អញ្ជើញអង្គុយ ! ខ្ញុំកំពុងគិតប្រើអ្នកណាម្នាក់ឲ្យទៅជំរាបសួរអ្នកឯណោះ កុំអីជ្រួសគ្នា, ឥឡូវបានអ្នកអញ្ជើញមកស្រួលហើយ ម៉េចទៅមានឃើញវាទៅឯផ្ទះឯណោះដែរឬទេ ? ៗ ឪពុកខ្វរ ដាក់គូថអង្គុយ មិនតបភ្លាមទេ ព្រោះគាត់កំពុងហត់ខ្លាំង, មួយស្របក់ទើបឆ្លើយ " បាទ, ឃើញ! ប្រហែលម៉ោង ៥ ជិតភ្លឺវាទៅដល់, រឿងនេះ ខ្ញុំក្ដៅក្រហាយណាស់អ្នកអើយ, នឹកឡើងវាខ្មាសអ្នកជន្លងហើយនឹងញាតិមិត្រទាំងអស់ ហួសពីខ្មាសទៅទៀតហើយក្នុងគ្រានេះ, តែមិនដឹងធ្វើដូចម្ដេច បើរឿងនេះវាហួសជ្រុលអស់ទៅហើយ " ៗ បន្ទាប់មក បុរសក៏រៀបរាប់អំពីពាក្យឆ្លើយឆ្លងរបស់ខ្លួននឹងកូនហូរហែតាមដំណើរសព្វគ្រប់ រហូតដល់គាត់ដេញសំពនវា ៗ លោតធ្លាក់ពីលើផ្ទះរត់បាត់ទៅទាំងព្រឹកនោះឯង ។ អ្នកទាំងអស់គ្នា បានស្ដាប់ហើយ ក៏ទៅជានាំគ្នាសើចសប្បាយទៅវិញ ព្រោះបានផ្បរផ្គងធៀបមើលរឿងខាងណោះនឹងខាងណេះទៅ ឃើញថាវាត្រូវដំណើរទំនងស៊ីគ្នាឥតល្អៀងសោះ ។ ទីបំផុត ជន្លងខាងប្រុសផ្ដើមនិយាយ : " ខ្ញុំសុំជំរាបស្មើដល់អ្នកជន្លង, តាមតែអ្នកអត់ទោសផងចុះ! ឥឡូវរឿងកូនយើងទាំងពីរនេះ ឃើញថាវាមិនបានជាប់គ្នាជាប្ដីប្រពន្ធទេ ព្រោះ

ហេតុមកពីកូនប្រុសខ្ញុំវាអៀនខ្មាសគោតល្ងង់ណាស់ ដូចអ្នកបានដឹងរឿងហូរហែរួចមកហើយ, កាលពីមុនខ្ញុំមិនស្មានថាវាជាមនុស្សពោលម្សៀតដល់ម្ល៉ឹងសោះ, ចំណែកខាងខ្ញុំ ការបង់ខាតរណ្ដាប់រណ្ដាជំនូនជូនដាក់ទាំងប៉ុន្មានក្នុងមង្គលការនេះ គឺវាជ្រុលហួសអស់ទៅហើយ, ឯខាងអ្នកឯណោះក៏មានបង់ខាតខ្លះដែរ គិតទៅទុកជាបង់អភ័ព្វទាំងអស់គ្នាទៅចុះ, រីឯកូនស្រីអ្នក ក៏ឃើញថានៅបរិសុទ្ធស្អាតដូចជានៅក្រមុំដដែលទេ, ឥឡូវយើងនឹងគិតលៃលកយ៉ាងណា ក៏គ្មានផ្លូវកែខៃដែរ ព្រោះអាពោលម្សៀតកូនប្រុសខ្ញុំនោះវាបានដាក់ ១ សន្យាដូចខ្ញុំបានជំរាបអ្នកអម្បាញ់មិញនេះរួចហើយថា ទាល់តែកុំឲ្យដេកប្រជ្រៀតគ្នា ទើបវាព្រមត្រឡប់មកជួបជុំគ្នាវិញ, សូមអ្នកជួយស្ដាប់ហើយពិចារណាមើលចុះ ពាក្យនេះគឺវានិយាយបំផុតដើមយើងតែម្ដង, ពេលនេះ ខ្ញុំសូមជូនពាក្យសំដីព្រមទាំងសូមជូនកូនស្រីដល់អ្នកវិញចុះ បើមានគេមកគិតគូរស្ដីដណ្ដឹងទៅថ្ងៃក្រោយ សូមអ្នកលៃលកយ៉ាងណា ក៏សម្រេចតាមអធ្យាស្រ័យអ្នកចុះ កុំឲ្យទាក់ទាមមកខាងខ្ញុំទៀត, តែចំណែកការរាប់អានគ្នា យើងត្រូវតែមានក្ដីស្មោះសរទៅវិញទៅមកទាក់ទងជាញាតិមិត្តតរៀងទៅ សូមអ្នកកុំអាក់អន់ស្រពន់ចិត្តអី . . ., ពាក្យដែលខ្ញុំជំរាបស្នើមកប៉ុណ្ណោះ តើអ្នកយល់ដូចម្ដេច ?

— ឪពុកកូនស្រីតប " បាទ, ចំណែកប៉ែកខាងខ្ញុំឯណោះ ឥតមានយោបល់យល់ទាស់អ្វីទេអ្នក បើបានជួបជុំគ្នាវិញក៏អរ តែឥឡូវបើ

មិនបានជួបជុំគ្នាទេ ក៏មិនជាការអ្វីប៉ុន្មានដែរ, ឯសេចក្ដីស្នើរបស់អ្នកនេះល្មមគួរសមហើយ ដូច្នេះ យើងត្រូវតែបញ្ចប់រឿងហ្នឹងត្រឹមនេះទៅចុះកុំឲ្យរាំរៃឆ្ងាយតទៅទៀត ធ្វើម្ដេចបើកូនប្រុសអ្នក គេមិនចេះដេកប្រជ្រៀត”។

គ្រានោះ, ឪពុកម្ដាយនាយខ្ពរ ក៏បានដំរាបលាជូនវិលត្រឡប់ទៅផ្ទះវិញដោយសេចក្ដីក្រៀមក្រំ ។ ក្នុងរយៈពេលកំពុងធ្វើដំណើរទៅនោះ ប្ដីប្រពន្ធទាំងពីរនាក់ ចេះតែពិគ្រោះគ្នាអ៊ូតាមផ្លូវអំពីរឿងនេះ ៗ ដល់ទីបំផុត, ប្ដីនិយាយថា អាខ្ពរវាបន្ទោសថាយើងធ្វើឲ្យវាខ្មាសគេ, ចំណែកយើង ៗ ក៏ថាវាធ្វើឲ្យយើងខ្មាសគេដែរ ចូរឯងគិតមើលចុះរឿងហ្នឹង, តែបើតាមអញដេញដោលរកឫសគល់ឲ្យជ្រៅឆ្ងាយទៅទៀត ឃើញថាទាស់ខុសមកពីយើងច្រើនដែរ ព្រោះរឿងប្រពន្ធនេះយើងចេះតែបង្ខំវាហើយ កំហុសធំម្យ៉ាងទៀតគឺតាំងពីវានៅតូចនៅឡើយនោះ យើងមិនបានពត់បង្ហាត់ទម្លាប់បណ្ដើរ ៗ ឲ្យវាចេះពុះពារ ឲ្យវាចេះក្លាហាន ឲ្យវាចេះប្រស្រ័យទាក់ទង ឲ្យវាចេះចូលជំនុំចំណោមនឹងគេសោះ យើងបានជំរុញវាឲ្យធ្វើតែត្រឹមកិច្ចការកាប់គាស់ដីធ្វើស្រែចំការតែប៉ុណ្ណោះ ម្ល៉ោះហើយវាទៅជាមនុស្សកុយមុយមុខខ្ពរខ្ចបអស់ ដល់វាមកជួបប្រទះផ្ទាល់ខ្លួនលើពេលជំនុំចំណោមធំ ៗ ដូចជាមង្គលការខ្លួនវានេះក៏ស្រាប់តែអន្ដរធានទាំងវាទាំងឯងតែម្ដងទៅ, ណ្ហើយយើងជាន់នេះ ដាក់ធុរៈចិត្តថាទុកដូចជាចាក់អាប៉ោងខុសមួយចានទៅចុះ ។

# ផ្នែកកំណត់ដំណឹងប្រវត្តិការណ៍

## បុណ្យនមស្ការព្រះសក្យមុនីចេតិយ

## និងវិសាខបូជា

លោក ស្តើង-ឡូ រៀបរៀង

ដូចអស់លោក-អ្នក បានជ្រាបស្រាប់មកហើយថា: បុណ្យនមស្ការព្រះសក្យមុនីចេតិយជាបុណ្យជាតិមួយ ផ្នែកខាងព្រះពុទ្ធសាសនា ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះនរោត្តមសុរាមរិត ព្រះចៅប្រទេសកម្ពុជា ជាទីគោរពនឹងជាទីស្នេហាស្មើដោយជីវិតនៃប្រជាជាតិខ្មែរ, កាលដែលព្រះអង្គទ្រង់គង់នៅ ក្នុងសិរីរាជសម្បត្តិនៅឡើយ ព្រះអង្គទ្រង់បានឡាយព្រះហស្ដលេខាលើព្រះរាជក្រឹត្យលេខ ៧៣ ន.ស. ចុះថ្ងៃទី ២៤ មករា ១៩៥៨ កំណត់ឲ្យធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយនេះ នៅថ្ងៃ ១៥ កើតនឹង ថ្ងៃ ១ រោចខែពិសាខ ជាដរាបរៀងរាល់ឆ្នាំតទៅៗ តាំងពីពេលនោះមក, រាល់ថ្ងៃ ១៥ កើតនឹងថ្ងៃ ១ រោចខែពិសាខ នៅមុខព្រះសក្យមុនីចេតិយ ខាងកើតស្ថានីយរាជអយស្មយាន ប្រទេសកម្ពុជា មានរៀបពិធីដ៏ឧឡារិកអធិកអធម ដើម្បីធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយ នឹងវិសាខបូជា ។ ឆ្នាំនេះ ជាឆ្នាំខួបទី ៤ នៃពិធីបុណ្យនេះ ព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ក៏បានរៀបធ្វើពិធីនេះដូចពីឆ្នាំមុន ៗ ដែរ ។

ថ្ងៃ ១៤ កើតខែពិសាខ ( ២៩ មេសា ១៩៦១ )

ម៉ោង ១៧ និង ៣០ នាទី ជួបជុំព្រះសង្ឃ ៨០ អង្គ, ព្រះរាជវង្សានុវង្ស, សមាជិកនៅសែនកុសល ហៅឈ្មោះ ប្រធានរដ្ឋសភា ព្រមទាំងសមាជិក; អ្នកអង្គម្ចាស់នរោត្តម-កន្តុល ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងសមាជិក, សមាជិកពរដ្ឋាភិបាល, ប្រធាននៃតុលាការកំពូលទាំង ៣ មន្ត្រីគ្រប់ដំណែង ទាំងទាហាន-ទាំងស៊ីវិល លោកស្រី, ឧបាសក, ឧបាសិកា បាននិមន្ត - ស្តេចយាង - អញ្ជើញដល់ ។

ម៉ោង ១៨ គត់ សម្តេចក្រុមព្រះស៊ីសុវត្ថិ-មុនីរ៉េត ប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ជាព្រះរាជតំណាង ដោយមានសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងព្រះរាជបរិពារតាមហែ បានស្តេចយាងដល់ព្រះពន្លា ដែលនៅពេលនោះទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរភូមិន្ទ ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យធ្វើគារវកិច្ចតាមទំនៀម ។

ក្រោយដែលសម្តេចព្រះរាជតំណាង បានទទួលនូវគារវកិច្ចអំពីកូនចៅព្រះអង្គហើយ ព្រះអង្គទ្រង់ប្រថាប់លើព្រះសុវណ្ណកោច្ឆៈនាព្រះពន្លា ។ ពេលនោះ, ពិធីបង្ហូតទង់ជាតិ បន្ទំដោយបទនគររាជ; បង្ហូតទង់សាសនា បន្ទំដោយបទសរភេញ តាមស្ករស័ព្ទនៃសំឡេងសិស្សប្រុស-ស្រីយ៉ាងគ្រលួច ក៏បានប្រារព្ធឡើងក្នុងបរិយាកាសដ៏ស្ងប់ស្ងាត់ និងអនុស្សាវរីយ៍

ដ៏ជ្រៅឆ្ងាយ ៗ ព្រះសង្ឃ-គ្រហស្ថក្រោកឈរ បែរព្រះភក្ត្រ-មុខគោរព ចំពោះព្រះសក្យមុនីចេតិយ ៗ

បន្ទាប់មក សហជីវិន ស៊ុន - ប៊ុប្ផកោ រដ្ឋលេខាធិការក្រសួងធម្មការ ក្នុងនាមនៃព្រះរាជរដ្ឋាភិបាល បានថ្លែងនូវសុន្ទរកថាមួយមានសេចក្តីដើម ដូចតទៅនេះ ៖

សូមព្រះតេជះតំកល់លើត្បូង

សូមព្រះរាជនាងក្រាបបង្គំទូល សម្តេចក្រុមព្រះ ជាព្រះរាជតំណាងនៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង

សូមទ្រង់ជ្រាបក្រោមលម្អងធូលីព្រះបាទ ៗ

ក្នុងនាមនៃព្រះរាជរដ្ឋាភិបាល និងក្នុងនាមនៃទូលព្រះបង្គំជាខ្ញុំ ជារដ្ឋលេខាធិការក្រសួងធម្មការ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាតសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាធិគុណនៃលម្អងធូលីព្រះបាទ ដែលបានស្តេចយាងជាព្រះរាជាធិបតី ក្នុងពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ នាថ្ងៃនេះ ៗ

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះរាជឱកាសសម្តេចជាអម្ចាស់ ដើម្បីថ្លែងនូវប្រវត្តិនៃព្រះបរមសារីរិកធាតុ និងសេចក្តីគោរព ចំពោះព្រះសក្យមុនីចេតិយនេះ ៗ

សូមទ្រង់ព្រះមេត្តាប្រោស !

ព្រះបរមសារីរិកធាតុ ដែលដំកល់នៅលើកំពូលព្រះសក្យមុនីចេតិយនេះ គឺជាកស្តុតាននៃស្នាព្រះហស្តសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋព្រះអង្គទ្រង់បានទទួលផ្ទាល់អំពីលោកអ្នកថែរក្សាព្រះបរមសារីរិកធាតុ នៅក្រុងកុលម្ពី ប្រទេសសិរីលង្កា ដែលបានថ្វាយចំពោះព្រះអង្គ ។

នៅឱកាសដែលប្រទេសកម្ពុជា ធ្វើពិធីបុណ្យពុទ្ធសករាជ ២៥០០ ដែលពុទ្ធបរិស័ទនិយមហៅថា ជាបុណ្យពាក់កណ្តាលព្រះសាសនា ព្រះអង្គទ្រង់ព្រះតំរិះដោយព្រះវិចារណញ្ញាណយល់ថា ការដែលព្រះអង្គបានទទួលព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធបរមគ្រូ ជាភ័ព្វព-សនាដ៏ឧត្តមនៃព្រះអង្គ ទើបព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យប្រកបដោយនូវសេចក្តីជ្រះថ្លាជាតិយោភាព ទ្រង់ប្រោសព្រះរាជទានឲ្យមានធ្វើពិធីដង្ហែព្រះបរមសារីរិកធាតុមកដំកល់ទុក នៅលើកំពូលព្រះសក្យមុនីចេតិយ ដែលប្រកបដោយទស្សនីយភាពរុងរឿងក្នុងឱកាសដ៏ឧឡារិកនេះ ដើម្បីជាទីគោរពសក្ការៈបូជានៃប្រជាជាតិទូទៅ នាកាលថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ១៩៥៧ ។

បន្ទាប់មក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម-សុរាម្រឹត ដែលជាទីគោរពនៃប្រជាជាតិ កាលព្រះអង្គទ្រង់គង់នៅក្នុងសិរីរាជសម្បត្តិនៅឡើយ ព្រះអង្គទ្រង់បានឡាយព្រះហស្តលេខា

លើព្រះរាជក្រឹត្យលេខ ៧៣ ន.ស. ចុះថ្ងៃទី ២៤ មករា គ.ស. ១៩៥៨ កំណត់ឱ្យធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយនេះ នៅថ្ងៃ ១៥ កើត និង ថ្ងៃ ១ រោច ខែពិសាខ ជារៀងរាល់ឆ្នាំតមក, ដោយទុកពិធីបុណ្យ នេះជាបុណ្យជាតិផ្នែកខាងព្រះពុទ្ធសាសនា ។

ក្រសួងធម្មការ ដោយអនុវត្តន៍តាមព្រះរាជក្រឹត្យខាងលើនេះ បាន ប្រួមជាមួយនឹងទីស្តីការរដ្ឋមន្ត្រីនានា ព្រមទាំងសាលាក្រុង ចាត់ការធ្វើ ពិធីបុណ្យនេះចំនួន ៣ ឆ្នាំកន្លងមកហើយ ឃើញថាពិធីនេះ មានអាយុ បាន ៤ ឆ្នាំ បើរាប់ទាំងឆ្នាំ ១៩៦១ នេះផង ។

សូមទ្រង់ព្រះមេត្តាប្រោស,

បន្ទាប់ពីនេះទៅ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះវរោកាស សម្តេចជាអម្ចាស់ ថ្លែងនូវសេចក្តីគោរពចំពោះព្រះបរមសារីរិកធាតុ ដែល ទ្រង់ប្រតិស្ឋាននៅក្នុងព្រះសក្យមុនីចេតិយ តាមន័យដូចតទៅនេះ ៖

សូមនមស្ការព្រះសមណគោតមបរមសម្ពុទ្ធជាម្ចាស់ ថ្ងៃនេះជាថ្ងៃ- ១៥ កើត ខែពិសាខ ដែលព្រះអង្គទ្រង់ប្រសូត ទ្រង់ត្រាស់ដឹងនូវព្រះអ- នុត្តរសម្មាសម្ពោធិញ្ញាណ និងទ្រង់ចូលព្រះបរមនិព្វានជានក្ខត្តឫក្សប្រកប ដោយសុភមង្គលយ៉ាងឧឡារិក ហើយដែលពុទ្ធបរិស័ទបានចងចាំទុកជា និច្ចកង្វល់ចិត្តរៀងរាល់ខួប ពុំភ្លេចសោះឡើយ ។

បពិត្រព្រះបរមគ្រូជាម្ចាស់ ពិតមែនតែព្រះអង្គទ្រង់ចូលកាន់ព្រះបរម

និព្វានទៅ ២៥០៤ ឆ្នាំ ហើយ ក៏ប៉ុន្តែ ព្រះសាសនធម៌ដែលជាទុកទ នៃព្រះអង្គ នឹងព្រះបរមសារីរិកធាតុដែលជាព្រះសរីរកាយរបស់ព្រះអង្គ ព្រមទាំងព្រះពុទ្ធបដិមាករដែលជាទេទ្ធសកចេតិយស្នងព្រះអង្គ បានឋិត ថេរគង់វង់នៅទាំងអស់ ឥតមានរលុបរលាយសូន្យទៅឡើយ ។

ព្រះសាសនធម៌របស់ព្រះអង្គនេះ បានមកប្រតិស្ឋាននៅក្នុងប្រទេស កម្ពុជាតាំងពីសតវត្សរ៍ទី ១០ នៃពុទ្ធសករាជ គិតទៅ ១.០០០ ជាយឆ្នាំ ហើយ តែជំនឿនឹងការគោរពពប់អានយ៉ាងមោះមុត របស់ប្រជាជាតិខ្មែរ ដែលមានព្រះមហាក្សត្ររបស់ខ្លួនជាទីគោរព បានរក្សាទុកនូវព្រះពុទ្ធោ- វាទរបស់ព្រះអង្គឲ្យមានថេរភាពនឹងវឌ្ឍនភាពរុងរឿងជានិច្ច ហាក់ដូច កាលព្រះអង្គទ្រង់គង់ព្រះជន្មាយុនៅឡើយ ។

បពិត្រព្រះគតវន្តមុនី,

ថ្ងៃនេះជាអភិលក្ខិតកាលប្រកបដោយសិរីសួស្តី ជ័យមង្គលដ៏ប្រ- សើរ ប្រជាជាតិខ្មែរទាំងមូល មានសម្តេចក្រុមព្រះ ជាព្រះពជាធិបតី បានស្តេចយាងមកជួបជុំក្នុងទីនេះ ដើម្បីធ្វើពិធីអស្ចារជាទឡ្ហីករំឭក ចំពោះព្រះមហាករុណាទិគុណដ៏ថ្លៃថ្លានៃព្រះអង្គ ដែលមានព្រះបរមសារី- រិកធាតុរបស់ព្រះអង្គ ប្រតិស្ឋាននៅនាព្រះសក្យមុនីចេតិយនេះ ដោយ គ្រឿងសក្ការៈបូជាមានទៀន-ធូប-ផ្កាភ្ញីជាដើម ។ កាលគង់ព្រះជន្មនៅ ឡើយ ព្រះអង្គធ្លាប់តែមានទឹកព្រះពជហឫទ័យ ស្រោចស្រប់ទៅលើសត្វ-

លោកទាំងមូលជាអនន្តគុណ ដោយបានប្រតិស្ឋានព្រះពុទ្ធសាសនាឲ្យសព្វសត្វទាំងអស់ បានក្រេបផឹកនូវពោលគឺគោរពប្រតិបត្តិតាមមករហូតដល់សព្វថ្ងៃនេះ ។

នៅទីអវសាន ក្នុងនាមព្រះរាជរដ្ឋាភិបាល រដ្ឋសភា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មន្ត្រីគ្រប់តំណែង ទាំងទាហានទាំងស៊ីវិល ព្រមទាំងប្រជាជាតិទាំងមូល ខ្ញុំព្រះករុណាទាំងឡាយ សូមបួងសួងចំពោះគុណព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយបីបាច់ថែរក្សាសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គទ្រង់បានប្រកបដោយនូវសេចក្តីសុខចំរើន និងសិរីសួស្តីជ័យមង្គល មានព្រះជន្មាយុយឺនយូរអស់រយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ដល់ប្រជានិករក្នុងព្រះរាជអាណាចក្រទាំងមូល ។

មួយវិញទៀត សូមប្រមូលកុសលរាសីទាំងអស់ដែលកើតមកពី ពិធីបុណ្យនេះ ក្រាបបង្គំទូលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃព្រះមហាការុញនរោត្តម និងអតីតព្រះមហាក្សត្រទាំងអស់ ដែលបានគ្រប់គ្រងកម្ពុជរដ្ឋប្រកបដោយនូវទសពិធរាជធម៌ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ទទួលនូវឥដ្ឋមនុញ្ញផលវិបុលសុខ ដោយព្រះរាជហឫទ័យប្រកបដោយសោមនស្សរីករាយ ។ ចំពោះសមាជិកសភាទាំង ២ សមាជិករាជរដ្ឋាភិបាល និងនាម៉ឺនសព្វមុខមន្ត្រីទាំងទាហាន - ទាំងស៊ីវិល និងពុទ្ធបរិស័ទទាំងអស់

កំសូមឲ្យបានប្រកបដោយនូវសេចក្តីសុខចំរើនគ្រប់ប្រការ នឹងសូមឲ្យសាមគ្គីធម៌រវាងគ្នានឹងគ្នា បានគង់វង់នៅជាដរាបតទៅ ដើម្បីធ្វើការបំរើប្រទេសជាតិតាមសមត្ថកិច្ចរៀង ៗ ខ្លួន នឹងតាមគម្រោយព្រះមាគ៌ានយោបាយដែលអង្គសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គមគ្គុទ្ទេសក៍ទ្រង់បានត្រួសត្រាយឲ្យយើងៈដើរតាមក្រោយព្រះអង្គ ។

ទោះទីបំផុត សូមព្រះរតនត្រ័យ ជួយប្រោះព្រំពិភពលោកទាំងមូលឲ្យបានឋិតនៅក្នុងសន្តិភាពជានិរន្តរ៍តរៀងទៅ ។

ជយោ ព្រះពុទ្ធសាសនា

ជយោ ប្រទេសកម្ពុជា

ជៈយោ ព្រះរាជបល្ល័ង្ក

លុះចប់សុន្ទរកថា នៃសហជីវិនរដ្ឋលេខាធិការក្រសួងធម្មការហើយ, មានធ្វើពិធីនមស្ការព្រះបរមសារីរិកធាតុ ដោយលោក ឈឹម - សុមន៍ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត នាំពុទ្ធបរិស័ទឲ្យថាតាមមានសេចក្តីដូចតទៅនេះ ៖

៣. ពាក្យនមស្ការព្រះបរមសារីរិកធាតុ

ក្នុងឱកាសបុណ្យនមស្ការព្រះសក្យមុនីចេតិយ

អាយុវស្សានិ សម្ពុទ្ធោ កតកាយោ តថាគតោ

សមសីត្យាយុកកាលេ បរិនិព្វាយិ សោ មុនិ

តស្ស សារីរិកា ធាតុ អម្ហាកំ បមុខេ ឋិតា
ឥធាគតោ ច សោ សត្ថា ធរមានោវ តិដ្ឋតិ
សក្ការេហាភិបូជេម តំ នមស្សាម សាទរំ
សាធុ នោ ភគវា នាថោ សព្វញ្ញូ សន្តិនាយកោ
ឥមេ ទស្សិតសក្ការេ អនុកម្បាយ គណ្ហាតុ
ទីឃរត្តំ ហិតាយេវ សុខាយម្ហាក សព្វទា ។

" ព្រះតថាគត ភគវន្តមុនី អង្គណា ទ្រង់បានត្រាស់ហើយ (ឋិតនៅ) អស់កាល ៤៥ ឆ្នាំ, ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនីទ្រង់បរិនិព្វានហើយ ក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ ឆ្នាំគត់; (ឥឡូវ) ព្រះបរមសារីរិកធាតុនៃព្រះអង្គមកប្រតិស្ឋាន ក្នុងទីចំពោះមុខនៃយើងខ្ញុំព្រះអង្គ ហាក់ដូចជាព្រះបរមសាស្តាអង្គនោះទ្រង់គង់ព្រះធរមាននៅឡើយ ស្តេចយាងមកគង់ក្នុងទីនេះ យើងខ្ញុំ សូមបូជាចំពោះព្រះអង្គ ដោយគ្រឿងសក្ការៈទាំងឡាយ សូមនមស្ការព្រះអង្គ ដោយគោរព; សូមព្រះភគវន្តមុនី សព្វញ្ញូពុទ្ធ បរមលោកនាថ ដែលតែងតែប្រោសប្រ-ទានសន្តិសុខដល់សត្វលោកទ្រង់ព្រះមេត្តាប្រោសទទួលនូវគ្រឿងសក្ការៈទាំងឡាយរបស់យើងខ្ញុំព្រះអង្គ ដែលជាសក្ការៈបូជារបស់អ្នកកំសត់ទុគ៌តនេះ ដើម្បីអនុគ្រោះយើងខ្ញុំព្រះអង្គឲ្យបានហិតប្រយោជន៍និងសេចក្តីសុខ

សព្ទកាលវេលាយូរអង្វែងទៀតទៅហោង" ។

( ក្រាបថ្វាយបង្គំ ៣ ដង )

លំដាប់មក សម្ដេចព្រះរាជតំណាង ព្រមទាំងរាជឧបាសក-សិកាទាំងអស់ បានស្ដេចយាង នឹងអញ្ជើញហែប្រទក្សិណព្រះសក្យមុនីចេតិយបីជុំ ហើយទ្រង់បូជាកម្រងមាលា ។ ចំណែកព្រះសង្ឃ-និងពុទ្ធបរិស័ទដែលពុំបានហែ បានក្រោកឈរគោរពចំពោះព្រះសក្យមុនីចេតិយ ។ លុះចប់បូជនីយកិច្ចនេះហើយ, សម្ដេចព្រះរាជតំណាង ស្ដេចយាងគង់ប្រថាប់ក្នុងព្រះពន្លាវិញ ទ្រង់ព្រះសណ្ដាប់ព្រះសង្ឃ ៨០ អង្គដែលគង់កៅអីចំរើនពុទ្ធជយមង្គលគាថា រួចស្ដេចយាងត្រឡប់វិញដោយមានព្រះរាជបរិពារដែលតាមហែ ។

បន្ទាប់នោះ ពុទ្ធបរិស័ទគ្រប់ឋានៈ បូលធ្វើសក្ការបូជាព្រះសក្យមុនីចេតិយ ដោយទៀន ធូប ភ្ញី ផ្កា នឹងបច្ច័យ រហូតដល់ម៉ោង ២០ ។ ចាប់ពីម៉ោង ២០ នឹង ៣០ នាទីទៅ មានធ្វើពិធីវិសាខបូជាដោយព្រះភិក្ខុសង្ឃនឹងព្រះធម្មទេសនា ដោយសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ; វិសាខបូជា ដោយព្រះភិក្ខុសង្ឃ នឹងធម្មទេសនាដោយព្រះសមាធិធម្ម មាស-គន់ ជាតំណាងសម្ដេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិកនិកាយ បានប្រព្រឹត្តទៅក្រោមកិច្ចចាត់ចែងនៃពុទ្ធិកសមាគមទាំង ៣ ក្នុងការឧបត្ថម្ភនៃក្រសួងធម្មការ រហូតដល់

ម៉ោង ១ និង ៣០ នាទី ទើបបប់សព្វគ្រប់ ។

ថ្ងៃ ១ កើតខែពិសាខ ( ៣០ មេសា ១៩៦១ ) វេលាម៉ោង ៨ និង ៣០ នាទី មានការជួបជុំដូចកាលពីល្ងាចថ្ងៃដំបូង ។ ដល់ម៉ោង ៨ និង ៤៥ នាទី សម្តេចក្រុមព្រះ ជាព្រះរាជតំណាងដោយមានព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែ បានស្តេចយាងមកដល់ ដែលមានទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរកុមារ ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យធ្វើគារវកិច្ចតាមទំនៀមរួចហើយ ទ្រង់ប្រថាប់ក្នុងព្រះពន្លាសមាទាននិច្ចសីល ។

បន្ទាប់មក ទ្រង់រាប់បាត្រព្រះសង្ឃ ៨០ អង្គ ហើយទ្រង់ប្រថាប់លើព្រះសុវណ្ណកោច្ឆៈដដែលវិញ ។ ឯព្រះសង្ឃ ក្រោយពេលដែលបានទទួលបង្អាប់រួចហើយក៏និមន្តត្រឡប់មកគង់លើកៅអីវិញ ស្វាធ្យាយកត្តានុមោទនា បត្តិទានគាថា រួចមានពិធីដាក់ទង់ជាតិ-ទង់សាសនា ដោយបន្ទឹបទនគររាជ-បទសរគញ តាមសំឡេងសិស្សប្រុស-ស្រី ។ ពេលនោះព្រះសង្ឃ-គ្រហស្ថក្រោកឈរគោរព បំពោះព្រះសក្យមុនីចេតិយ ។

ម៉ោង ១០ សម្តេចក្រុមព្រះជាព្រះរាជតំណាង ស្តេចយាងត្រឡប់វិញ ដោយមានព្រះរាជបរិពារដដែលតាមហែ ។ តមក ពុទ្ធបរិស័ទបានដាក់បាត្រព្រះសង្ឃយ៉ាងហូរហៃ ។ ពិធីនេះ ក៏បានចប់សព្វគ្រប់នៅពេលដាក់បាត្ររួច ។

---